សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ការលក់ទិញអចលនវត្ថុនៅកម្ពុជាបច្ចុប្បន្ន

ស្រាវជ្រាវពីថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៦ ដល់ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៦

តាក់តែងឡើងដោយ
និស្សិតឈ្មោះ **យាន តាត្រា**
**អ៊ុក តុលា**

សាស្ត្រាចារ្យណែនាំ
លោក **អម សុផាណារ៉ាត**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី ១៦

ឆ្នាំចូលសិក្សា ២០១២
ឆ្នាំសរសេរសារណា ២០១៦

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទលោក **យាន ឥន្ត្រា** និង លោក **អ៊ុក គុណា** ជានិស្សិតបរិញ្ញាបត្រនីតិសាស្ត្រ ជំនាន់ទី១៦ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ សូមថ្លែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅជាទីបំផុតជូនចំពោះ ៖

– **លោកឪពុក អ្នកម្តាយ** របស់យើងខ្ញុំ ដែលបានផ្តល់កំណើតដល់កូនដោយសេចក្តីស្រឡាញ់ អាណិត និងតស៊ូចិញ្ចឹមបីបាច់ថែរក្សា អប់រំកូនឲ្យក្លាយទៅជាកូនល្អ ពលរដ្ឋល្អ សិស្សល្អ ព្រមទាំងបានឧបត្ថម្ភ និងជួយជាកំលាំងចិត្តជម្រុញឲ្យកូនបានសិក្សា តាំងពីនៅបឋមសិក្សារហូតមកដល់មហាវិទ្យាល័យ និងមកដល់សព្វថ្ងៃនេះ។

– **ឯកឧត្តមសាកលវិទ្យាធិការ និងសាកលវិទ្យាធិការរង និងគណៈគ្រប់គ្រងទាំងអស់** នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលផ្តល់ការអនុញ្ញាតឲ្យយើងខ្ញុំបានសិក្សាដើម្បីទទួលបានចំណេះដឹង និងបទពិសោធន៍ជាច្រើនអំពីការសិក្សារបស់យើងខ្ញុំ។

– លោកសាស្ត្រាចារ្យ **អម សុផាណារ៉ាត** ដែលលោក គឺជាសាស្ត្រាចារ្យដឹកនាំក្នុងការសរសេរសារណាបញ្ចប់ការសិក្សានេះ ដែលលោកបានជួយធ្វើការពន្យល់ណែនាំ កែតម្រូវ និងមានទឹកចិត្តខិតខំបង្ហាត់បង្រៀនដោយមិនខ្លាចនឹងការណឿយហត់ឡើយដើម្បីឲ្យយើងខ្ញុំទទួលបានចំណេះដឹង។

– **លោក លោកស្រី សាស្ត្រាចារ្យទាំងអស់** នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានខិតខំបង្ហាត់បង្រៀន ដើម្បីឲ្យយើងខ្ញុំទទួលបានចំណេះដឹង និងបទពិសោធន៍យ៉ាងច្រើន ដើម្បីធ្វើជាស្ពានឈានទៅដល់ថ្ងៃអនាគតដ៏ភ្លឺស្វាង។

– **មិត្តភក្តិ និងរាមច្បងទាំងអស់** ដែលបានជួយផ្តល់យោបល់ណែនាំ លើកទឹកចិត្តឲ្យខំប្រឹង និង ផ្តល់ជាឯកសារ ព្រមទាំងជួយកែតម្រូវអក្ខរាវារុទ្ធនៅក្នុងសារណានេះឲ្យបានត្រឹមត្រូវ។

ជាទីបញ្ចប់ យើងខ្ញុំសូមគោរពជូនពរដល់ លោកឪពុក អ្នកម្តាយជាទីស្រឡាញ់ និងអស់លោក លោកស្រី អ្នកនាង កញ្ញាទាំងអស់ សូមបានជួបប្រទះនូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀង ឃ្លាតឡើយ សូមអរគុណ។

# អារម្ភកថា

សៀវភៅសារណាស្តីពី **"ការលក់ទិញអចលនវត្ថុនៅកម្ពុជាបច្ចុប្បន្ន"** គាក់តែងឡើងដើម្បីជាជំនួយដល់ការសិក្សា ស្រាវជ្រាវរបស់សិស្ស និស្សិត និងដល់ប្រជាពលរដ្ឋទាំងអស់ ដែលចង់ចេះ ចង់ដឹង និងយកទៅអនុវត្តទាក់ទងនឹងការលក់ទិញអចលនវត្ថុនេះ ពីព្រោះថាវាជាប់ពាក់ព័ន្ធយ៉ាងជិតស្និទ្ធជាមួយនឹងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋសព្វថ្ងៃ។ ហើយមួយវិញទៀតនោះ សៀវភៅសារណានេះ គឺយើងខ្ញុំបានស្វះស្វែងរកឯកសារជាច្រើនដែលជាប់ទាក់ទងនឹងការលក់ទិញអចលនវត្ថុដើម្បីបញ្ចូលនៅក្នុងខ្លឹមសារនៃសារណានេះ និងបានបញ្ចូលនូវខ្លឹមសារនៃបទបញ្ញត្តិច្បាប់ថ្មីៗ និងបទដ្ឋានគតិយុត្តជាច្រើន ដែលជាប់ទាក់ទងនឹងការគ្រប់គ្រង និងប្រើប្រាស់អចលនវត្ថុ ដែលបានចូលជាធរមាន និងកំពុងតែអនុវត្តនៅសព្វថ្ងៃនេះ ដើម្បីឲ្យមិត្តអ្នកអានទាំងអស់បានយល់កាន់តែច្បាស់ ខាងផ្លូវច្បាប់ទាក់ទងនឹងការលក់ទិញអចលនវត្ថុ ។

សៀវភៅសារណានេះ គឺជាសមិទ្ធិផលដំបូងរបស់យើងខ្ញុំ ដែលកើតចេញមកពីការខិតខំរៀនសូត្ររបស់យើងខ្ញុំ អស់រយៈពេល៤ឆ្នាំ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ទើបធ្វើឲ្យយើងខ្ញុំមានសមត្ថភាពអាចសរសេរសៀវភៅសារណានេះលេចជារូបរាងឡើងដូច្នេះ។ ទោះបីជាសៀវភៅសារណានេះ បានលេចរូបរាងជាស្ថាពរក៏ដោយ ក៏យើងខ្ញុំដឹងថាសៀវភៅសារណានេះប្រហែលនៅមានកំហុស និងចំណុច ខ្វះខាតជាច្រើន ពីព្រោះតែយើងខ្ញុំគ្រាន់តែជានិស្សិតបរិញ្ញាបត្រគ្មានចំណេះដឹងខ្លាំងខ្លា គ្មានបទពិសោធន៍ក្នុងការតាក់តែងសៀវភៅសារណាបែបនេះពីមុនមក និងគ្មានបទពិសោធន៍ក្នុងការធ្វើការងារ ឬ បានអនុវត្តផ្ទាល់នៅក្នុងការលក់ទិញអចលនវត្ថុនេះដោយផ្ទាល់ឡើយ។ ដូច្នេះហើយ សូមបណ្តាអ្នកអាន និងមិត្តនិស្សិតទាំងអស់មានការ ខន្តី អធ្យាស្រ័យដល់កំហុសឆ្គងដោយអចេតនាទាំងឡាយរបស់យើងខ្ញុំ ដែលបានប្រព្រឹត្តខុសដោយប្រការណាមួយ។

ជាចុងក្រោយយើងខ្ញុំទាំងពីរនាក់ សូមស្វាគមន៍ដោយចិត្តស្មោះនូវមតិរិះគន់ដើម្បីស្ថាបនាកែលំអរ ពីមិត្តអ្នកអានទាំងអស់គ្នា និងសូមអរគុណទឹកចិត្តអ្នកទាំងអស់គ្នា ដែលបានអានសៀវភៅសារណារបស់យើងខ្ញុំយ៉ាងយកចិត្តទុកដាក់។

# មាតិកា


សេចក្ដីផ្ដើម ...................................................................................... ១

ជំពូកទី១ ៖ ដំណាក់កាលមុនការចុះកិច្ចសន្យាលក់ទិញអចលនវត្ថុ ............................ ៤

ផ្នែកទី១ ៖ ការសាកសួរព័ត៌មាន និងការចរចា ................................................. ៤

កថាខណ្ឌទី១ ៖ ការសាកសួរព័ត៌មាននិងការស្វែងយល់សិទ្ធិ និងករណីយកិច្ចរបស់ភាគី ...... ៤

១.១. ការសាកសួរព័ត៌មានទូទៅអំពីអចលនវត្ថុ ................................................ ៤

១.២. សិទ្ធិ និងករណីយកិច្ចរបស់អ្នកលក់ និងអ្នកទិញ ....................................... ៦

កថាខណ្ឌទី២ ៖ ការចរចានៅក្នុងការលក់ទិញអចលនវត្ថុ ...................................... ១៣

២.១. ការចរចាពីតម្លៃ ................................................................................ ១៣

២.២. ការចរចារពីប្រាក់កក់ ......................................................................... ១៤

២.៣. ការចរចាអំពីករណីបង់រំលស់ ................................................................ ១៥

ផ្នែកទី២ ៖ ការត្រួតពិនិត្យអចលនវត្ថុ ............................................................. ១៦

កថាខណ្ឌទី១ ៖ ការត្រួតពិនិត្យប្រភេទឯកសារដែលពាក់ព័ន្ធនឹងអចលនវត្ថុ .................. ១៧

១.១. អចលនវត្ថុមានប័ណ្ណកម្មសិទ្ធិ .............................................................. ១៧

១.២. អចលនវត្ថុគ្មានប័ណ្ណកម្មសិទ្ធិ ............................................................... ១៩

១.៣. ការត្រួតពិនិត្យបន្ទុកនៅលើអចលនវត្ថុ ................................................... ២១

កថាខណ្ឌទី២ ៖ ការត្រួតពិនិត្យស្ថានភាពជុំវិញអចលនវត្ថុ .................................... ២២

២.១. ការត្រួតពិនិត្យទំហំ និងព្រំដី ................................................................ ២២

២.២. ការត្រួតពិនិត្យអគារសហកម្មសិទ្ធិ ......................................................... ២៤

២.៣. ការត្រួតពិនិត្យដីចំណីផ្លូវ និងចំណីផ្លូវរថភ្លើង ......................................... ២៤

ជំពូកទី២ ៖ ដំណាក់កាលចុះកិច្ចសន្យាលក់ទិញអចលនវត្ថុ ................................... ២៦

ផ្នែកទី១ ៖ ការបង្កើតកិច្ចសន្យាលក់ទិញអចលនវត្ថុ ............................................ ២៦

កថាខណ្ឌទី១ ៖ លក្ខខណ្ឌគ្រឹះ ........ ២៦
១.១. ការព្រមព្រៀង ........ ២៦
១.២. សមត្ថភាព ........ ៣៩
១.៣. កម្មវត្ថុ ........ ៤៥
កថាខណ្ឌទី២ ៖ លក្ខខណ្ឌទម្រង់ ........ ៤៧
២.១. លិខិតឯកជន ........ ៤៧
២.២. លិខិតយថាភូត ........ ៤៨
២.៣. ការចុះបញ្ជី ........ ៤៨
ផ្នែកទី២ ៖ ការអនុវត្តកិច្ចសន្យាលក់ទិញអចលនវត្ថុ ........ ៤៨
កថាខណ្ឌទី១ ៖ អានុភាពនៃកិច្ចសន្យា ........ ៤៩
១.១. អានុភាពកិច្ចសន្យារវាងគូភាគី ........ ៤៩
១.២. អានុភាពនៃកិច្ចសន្យាចំពោះតតិយជន ........ ៥០
កថាខណ្ឌទី២ ៖ អានុភាពនៃសិទ្ធិផ្សេងៗនៅក្នុងកិច្ចសន្យាលក់ទិញអចលនវត្ថុ ........ ៥១
២.១. ការចុះកិច្ចសន្យាតាមរយៈអ្នកតំណាង ........ ៥១
២.២. ការចុះកិច្ចសន្យាដោយអាណត្តិ ........ ៥៣
កថាខណ្ឌទី៣ ៖ ការតម្កល់ប្រាក់ និងការទទួលប្រាក់កក់ថ្លៃអចលនវត្ថុ ........ ៥៤
៣.១. ការតម្កល់ប្រាក់នៅធនាគារ ........ ៥៤
៣.២. ការប្រគល់ និងទទួលប្រាក់កក់ ........ ៥៥
ជំពូកទី៣ ៖ ដំណាក់កាលផ្ទេរអចលនវត្ថុ (ដោយការលក់ទិញ) ........ ៥៦
ផ្នែកទី១ ៖ ការផ្ទេរដីធ្លី ........ ៥៦
កាថាខណ្ឌទី១ ៖ ការផ្ទេរដីកម្មសិទ្ធិ ........ ៥៦
១.១. បុគ្គលដែលដាក់ពាក្យសុំចុះបញ្ជី ........ ៥៧

១.២. ពាក្យសុំចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិ ..................................................... ៥៨

១.៣. អាជ្ញាធរមូលដ្ឋាន ..................................................... ៥៩

១.៤. ស្ថាប័នមានសមត្ថកិច្ចក្នុងការចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិ ..................................................... ៦០

កថាខណ្ឌទី២ ៖ ការផ្ទេរដីគ្មានប័ណ្ណកម្មសិទ្ធិ ..................................................... ៦២

២.១. គូភាគី ឬ ភាគី ..................................................... ៦២

២.២. អាជ្ញាធរមូលដ្ឋាន ..................................................... ៦៣

ផ្នែកទី២ ៖ ការផ្ទេរអគារសហកម្មសិទ្ធិ ..................................................... ៦៤

កថាខណ្ឌទី១ ៖ ការផ្ទេរអគារសហកម្មសិទ្ធិមានប័ណ្ណ ..................................................... ៦៤

១.១. អ្នកស្នើសុំចុះបញ្ជី ..................................................... ៦៥

១.២. រដ្ឋបាលសុរិយោដី ក្រុង ស្រុក ខណ្ឌ ..................................................... ៦៦

១.៣. មេឃុំ ចៅសង្កាត់ ឬ អភិបាលក្រុង ស្រុក ខណ្ឌ ..................................................... ៦៦

១.៤. ការបង់ពន្ធប្រថាប់ត្រានៅសាខាពន្ធដារាជធានី-ខេត្ត ..................................................... ៦៧

១.៥. រដ្ឋបាលសុរិយោដីរាជធានី ខេត្ត ..................................................... ៦៧

កថាខណ្ឌទី២ ៖ ការផ្ទេរអគារសហកម្មសិទ្ធិគ្មានប័ណ្ណ ..................................................... ៦៨

២.១. គូភាគី ឬ អ្នកលក់ និងអ្នកទិញ ..................................................... ៦៨

២.២. ការដឹងឮពីឃុំ/សង្កាត់ ឬ ស្រុក/ខណ្ឌ ..................................................... ៦៩

**សេចក្តីសន្និដ្ឋាន ..................................................... ៧០**

**អនុសាសន៍ ..................................................... ៧២**

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

ដោយមើលឃើញថា ប្រទេសកម្ពុជាបច្ចុប្បន្នមានសន្តិភាព ចំនួនប្រជាជនក៏មានការកើនឡើងយ៉ាងឆាប់រហ័ស និង ព្រមទាំងកំណើនសេដ្ឋកិច្ចក៏កើនឡើងជាលំដាប់ជារៀងរាល់ឆ្នាំ និងមានការរីកចម្រើនស្ទើតែគ្រប់វិស័យដូចជា វិស័យកសិកម្ម ឧស្សាហកម្ម ពាណិជ្ជកម្មជាដើម។ និងដោយមើលឃើញថា ប្រជាពលរដ្ឋមានជីវភាពធូរធាជាងមុន និងមានតម្រូវការក្នុងការរស់នៅក៏ច្រើន ដែលធ្វើឲ្យប្រជាពលរដ្ឋ មានការកែប្រែទម្លាប់រស់នៅពីសម័យបុរាណមកជាការរស់នៅបែបសម័យទំនើបស៊ីវីល័យ (civilize) និង ចង់បានសម្ភារៈទំនើបគ្រប់បែបយ៉ាង។ ដូច្នេះមូលហេតុទាំងអស់នេះហើយ ដែលជាហេតុធ្វើឲ្យ អ្នកវិនិយោគក្នុងប្រទេស និងក្រៅប្រទេសមានការចាប់អារម្មណ៍មកធ្វើការវិនិយោគ ទៅលើគ្រប់វិស័យនៅក្នុងប្រទេសកម្ពុជាបច្ចុប្បន្ននេះ។ រួមទាំងវិស័យអចលនវត្ថុផងដែរ ដែលត្រូវបានចាប់អារម្មណ៍ពីអ្នកវិនិយោគ និងប្រជាពលរដ្ឋសាមញ្ញ។ ដូច្នេះហើយ ទើបធ្វើឲ្យមានចលនានៃការលក់ទិញអចលនវត្ថុមានការកើនឡើងយ៉ាងខ្លាំងគួរឲ្យកត់សម្គាល់ រវាងវិនិយោគិន និងប្រជាពលរដ្ឋសាមញ្ញ រវាងប្រជាពលរដ្ឋសាមញ្ញ និងប្រជាពលរដ្ឋសាមញ្ញ និងរវាងវិនិយោគិន និងវិនិយោគិនជាដើម យ៉ាងមមាញឹកនៅក្នុងការប្រកបមុខរបរចិញ្ចឹមជីវិត និងរស់នៅសព្វថ្ងៃ។

នៅពេលដែលមានការលក់ទិញកើតឡើង គឺត្រូវតែតម្រូវឲ្យមានការបង្កើតកិច្ចសន្យាលក់ទិញមួយ ដើម្បីឲ្យស្របទៅតាមផ្លូវច្បាប់ និងជាភស្តុតាងបញ្ជាក់អំពីការលក់ទិញនោះ។ នៅក្នុងក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ បានឲ្យនិយមន័យនៃការលក់ទិញថា ការលក់ទិញសំដៅទៅលើកិច្ចសន្យាមួយដែលភាគីម្ខាងហៅថា អ្នកលក់មានករណីយកិច្ចត្រូវផ្ទេរកម្មសិទ្ធិ ឬ សិទ្ធិផ្សេងទៀតលើទ្រព្យសម្បត្តិឲ្យទៅភាគីម្ខាងទៀតហៅថា អ្នកទិញ ហើយអ្នកទិញមានករណីយកិច្ចត្រូវចេញថ្លៃជាប្រាក់ឲ្យអ្នកលក់។ រីឯនិយមន័យនៃកិច្ចសន្យាលក់ទិញវិញ គឺជាកិច្ចសន្យាអញ្ញមញ្ញ ដែលក្នុងកិច្ចសន្យាភាគីមានបន្ទុកបំពេញកាតព្វកិច្ចជាតាវកាលិកឲ្យគ្នាទៅវិញទៅមក។ ចំណែកឯអចលនវត្ថុ បើយោងតាមក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ បានឲ្យនិយមន័យថា អចលនវត្ថុ គឺសំដៅទៅលើដីធ្លី និងវត្ថុជាប់នៅលើដី ហើយមិនអាចផ្លាស់ប្តូរទីកន្លែងបាន ដូចជាអាគារ សំណង់ ដំណាំ រុក្ខជាតិ ជាអាទិ៍។ ហើយបើយោងតាមច្បាប់ភូមិបាល ឆ្នាំ២០០១ អចលនវត្ថុត្រូវបានបែងចែកជា ៣ (បី) ប្រភេទដូចជា៖

– អចលនវត្ថុពីកំណើត គឺមានដីធម្មជាតិដូចជា ដីព្រៃឈើ ដីកាប់រាន ដីដាំដុះ ដីទុកទំនេរ ឬមិនអាចដាំដុះ ដីលិចទឹកដោយទឹកនៅនឹង ឬ ទឹកហូរ និងសំណង់ ឬ ការៀបចំទាំងឡាយដែលស្ថិត

នៅមួយកន្លែង កើតឡើងដោយអំពើមនុស្ស ហើយមិនអាចរំកិល ឬ ផ្លាស់ប្តូរកន្លែងបាន។

– អចលនវត្ថុពីភ័ព្វវាសនា គឺមានវត្ថុដែលជាប់នឹងដី ឬ បញ្ចូលជាមួយសំណង់ទាំងឡាយដែលមិនអាចបំបែកចេញបានដោយមិនធ្វើឲ្យមានការខូចខាត ឬ មិនដូរសភាពដើមដូចជា ដើមឈើ ឧបករ-ណ៍តែងលំអជាដើម។

– អចលនវត្ថុតាមការកំណត់របស់ច្បាប់ គឺមានសិទ្ធិភណ្ឌិកទាំងឡាយលើអចលនវត្ថុ និងចល-នវត្ថុទាំងឡាយដែលបានកំណត់ដោយច្បាប់ជាអចលនវត្ថុ។ ហើយគេក៏អាចចាត់ទុកជាអចលនវត្ថុតាមច្បាប់កំណត់បានដែរដូចជា ទូក កប៉ាល់ ផ្ទះផែជាដើម ដែលមានទម្ងន់ចំណុះ៣០តោនឡើងទៅ ថ្វីត្បិតតែវាជាវត្ថុអាចបំលាស់ទីបានក៏ដោយ ឲ្យតែមានច្បាប់បានកំណត់ថាវាជាអចលនវត្ថុពីកំណើត។

ជារួមមកការលក់ទិញអចលនវត្ថុ គឺជាកិច្ចសន្យាមួយដែលអ្នកលក់មានករណីយកិច្ចត្រូវផ្ទេរកម្មសិទ្ធិ ឬ សិទ្ធិផ្សេងទៀតលើដីធ្លី សំណង់ អាគារ ឲ្យទៅអ្នកទិញ ដោយអ្នកទិញមានករណីយកិច្ចត្រូវចេញថ្លៃជាប្រាក់ឲ្យអ្នកលក់។

នៅក្នុងការលក់ទិញអចលនវត្ថុនេះផងដែរ នៅក្នុងប្រទេសកម្ពុជាយើងសព្វថ្ងៃមានច្បាប់ និងបទដ្ឋានគតិយុត្តជាច្រើន ដែលមានវិសាលភាពគ្របដណ្តប់ទៅលើការលក់ទិញអចលនវត្ថុនេះ ដើម្បីផ្តល់ភាព ងាយស្រួល ដល់ការគ្រប់គ្រង ប្រើប្រាស់ លក់ ជួល បញ្ចាំ ការធានាការពាររបបកម្មសិទ្ធិលើអចលនវត្ថុដល់ប្រជាពលរដ្ឋ និង ជនបរទេសដែលមានបំណងចង់ទិញ ផ្ទះ ឬ សំណង់ អគារ នៅក្នុងប្រទេសកម្ពុជាជាដើម។ ច្បាប់ និងបទដ្ឋានគតិយុត្តទាំងនោះមានដូចជា ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ ច្បាប់ភូមិបាលឆ្នាំ២០០១ ច្បាប់ស្តីពីការផ្តល់សិទ្ធិកម្មសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិដល់ជនបរទេសឆ្នាំ២០១០ និងព្រមទាំងអនុក្រឹត្យស្តីពីការគ្រប់គ្រង និងប្រើប្រាស់អគារសហកម្មសិទ្ធិឆ្នាំ ២០០៩ ជាអាទិ៍។

ការលក់ទិញអចលនវត្ថុ គឺជាកិច្ចសន្យាមួយប្រភេទដែលមាននីតិវិធីស្មុគស្មាញ និងមានលក្ខខណ្ឌតម្រូវជាច្រើនដូចជា អ្នកទិញត្រូវធ្វើការចរចា ត្រួតពិនិត្យអចលនវត្ថុ ត្រូវធ្វើលិខិតយថាភូត និងត្រូវធ្វើការចុះបញ្ជីកាត់ឈ្មោះ ឬ ត្រូវមានការទទួលស្គាល់ដឹងឮពីអាជ្ញាធរមូលដ្ឋានជាដើម ដែលវាមានការលំបាកជាងការបង្កើតកិច្ចសន្យាលក់ទិញចលនវត្ថុ ឬ វត្ថុសាមញ្ញ។ ដូច្នេះហើយ នៅក្នុងសារណានេះនឹងបង្ហាញឲ្យបានដឹង បានយល់អំពីចំណុចសំខាន់ៗជាច្រើន ដែលទាក់ទងដល់ការលក់ទិញអចលនវត្ថុនៅក្នុងព្រះរាជាណាចក្រកម្ពុជាយើងសព្វថ្ងៃនេះ ជូនដល់ប្រជាពលរដ្ឋទាំងអស់ដែលមានបំណង ឬ គំរោងចង់ទិញអចលនវត្ថុនៅថ្ងៃអនាគត ឲ្យបានភាពងាយស្រួលឆាប់រហ័ស និងមិនត្រូវបាន

គេបន្លំ បោកប្រាស ឬ ត្រូវបានខាតពេលវេលា លុយកាក់ និងដើម្បីកុំឲ្យកើតមាននូវវិវាទនៅថ្ងៃខាងមុខផងដែរ។ មួយវិញទៀតនោះ អត្ថន័យទាំងអស់នៅក្នុងសារណានេះ គឺមានគោលបំណងផ្តោតសំខាន់ទៅលើ ការលក់ទិញអចលនវត្ថុដែលជាដីធ្លី ផ្ទះ និងអគារសហកម្មសិទ្ធិរបស់បុគ្គលឯកជននឹងបុគ្គលឯកជនតែប៉ុណ្ណោះ ដោយមិនជាប់ពាក់ព័ន្ធទៅនឹងអចលនវត្ថុដែលជាទ្រព្យសម្បត្តិសាធារណៈ ឬ ឯក-ជនរបស់រដ្ឋឡើយ។

ទាក់ទងនឹងការលក់ទិញអចលនវត្ថុនេះផងដែរ មានសំណួរ និងចម្ងល់របស់ប្រជាពលរដ្ឋជាច្រើនបានលើកឡើងថា តើនៅពេលដែលគាត់ចង់ទិញដីធ្លី ផ្ទះ ឬអាគារខុនដូ ដើម្បីឲ្យមានភាពងាយស្រួល និងឆាប់រហ័ស តើគាត់ត្រូវធ្វើយ៉ាងដូចម្តេចខ្លះ? នៅក្នុងដំណាក់កាលដំបូង តើអ្នកលក់ និងអ្នកទិញ ត្រូវធ្វើអ្វីខ្លះនៅមុនពេលឈានដល់ដំណាក់កាលចុះកិច្ចសន្យា? តើនៅពេលដល់ដំណាក់កាលចុះកិច្ចសន្យា ឬ បង្កើតកិច្ចសន្យាហើយ តើអ្នកលក់ និងអ្នកទិញត្រូវធ្វើអ្វីខ្លះ ដើម្បីឲ្យកិច្ចសន្យានេះមានអានុភាព ហើយអាចអនុវត្តបាន? ហើយនៅពេលដែលកិច្ចសន្យាត្រូវបានចុះ ឬ បង្កើតរួចរាល់ហើយ តើត្រូវធ្វើការផ្ទេរអចលនវត្ថុដោយរបៀបណាទើប អ្នកទិញអាចទទួលបាននូវសិទ្ធិកម្មសិទ្ធិ ឬសិទ្ធិផ្សេងទៀតទៅលើអចលនវត្ថុដែលខ្លួនបានទិញ? ដូច្នេះដើម្បីស្រាយនូវចម្ងល់ និងសំណួរទាំងអស់ដែលបានលើកឡើងខាងលើ សូមធ្វើការបកស្រាយ និងឆ្លើយនូវសំណួរទាំងអស់នេះតាមរយៈខ្លឹមសារនៅក្នុងសារណានេះ ដោយធ្វើការបែងចែកជា៣ (បី) ជំពូកដូចខាងក្រោម៖

- ជំពូកទី១ អំពីដំណាក់កាលមុនការចុះកិច្ចសន្យាលក់ទិញអចលនវត្ថុ
- ជំពូកទី២ អំពីដំណាក់កាលចុះកិច្ចសន្យាលក់ទិញអចលនវត្ថុ
- ជំពូកទី៣ អំពីដំណាក់កាលផ្ទេរអចលនវត្ថុ

# ជំពូកទី១
# ដំណាក់កាលមុនការចុះកិច្ចសន្យាលក់ទិញអចលនវត្ថុ

នៅក្នុងការលក់ទិញអចលនវត្ថុមានដំណាក់កាលជាច្រើនដែលគូភាគីត្រូវបំពេញ។ ក្នុងនោះ ដំណាក់កាលមុនការចុះកិច្ចសន្យាក៏ជាដំណាក់កាលមួយដ៏សំខាន់ផងដែរ ចំពោះគូភាគីដែលត្រូវធ្វើ។ ដោយមូលហេតុថា ការលក់ទិញអចលនវត្ថុគឺជាការលក់ទិញមួយប្រភេទដែលមានលក្ខណៈពិសេស និង ស្មុគស្មាញជាងការលក់ទិញចលនវត្ថុធម្មតា។ ពីព្រោះតែអចលនវត្ថុវាគឺជារបស់ដែលមានតម្លៃថ្លៃខុសពីរបស់ធម្មតា ដែលការលក់ទិញត្រូវតម្រូវឲ្យមានលក្ខខណ្ឌ និងនីតិវិធីជាច្រើន។ ដូច្នេះក្នុងដំណាក់កាលនេះ នឹងធ្វើការបកស្រាយអំពីការសាកសួរព័ត៌មាន និងការចរចា (ផ្នែកទី១) និងការត្រួតពិនិត្យអចលនវត្ថុ (ផ្នែកទី២) ឲ្យបានច្បាស់លាស់ជាមុនសិន មុននឹងឈានដល់ដំណាក់កាលចុះកិច្ចសន្យា។

## ផ្នែកទី១៖ ការសាកសួរព័ត៌មាន និងការចរចា

យើងដឹងហើយថាការលក់ទិញអចលនវត្ថុ គឺជាការលក់ទិញមួយប្រភេទដែលវាមានលក្ខណៈខុសពីការទិញលក់វត្ថុ ឬ ទំនិញធម្មតានៅតាមទីផ្សារ ដែលវាទាមទារឲ្យគូភាគីគួរតែសាកសួរព័ត៌មាន និងធ្វើការស្វែងយល់អំពីសិទ្ធិ និងករណីយកិច្ច (កថាខណ្ឌទី១) របស់ខ្លួនឲ្យបានច្បាស់លាស់ និងមួយវិញទៀតនោះត្រូវធ្វើការចរចា (កថាខណ្ឌទី២) ឲ្យបានត្រូវរ៉ូវគ្នាជាមុនសិន មុននឹងឈានដល់ដំណាក់កាលចុះកិច្ចសន្យា។

### កថាខណ្ឌទី១៖ ការសាកសួរព័ត៌មាន និងការស្វែងយល់សិទ្ធិ និងករណីយកិច្ចរបស់ភាគី

នៅក្នុងចំណុចនេះ នឹងសិក្សាផ្តោតទៅលើការសាកសួរព័ត៌មានទាំងឡាយអំពីអចលនវត្ថុ(១.១) ព្រមទាំងសិក្សាអំពីសិទ្ធិ និងករណីយកិច្ចរបស់អ្នកលក់ និងអ្នកទិញ (១.២) ផងដែរ។

#### ១.១. ការសាកសួរព័ត៌មានទូទៅអំពីអចលនវត្ថុ

ជាទូទៅប្រជាពលរដ្ឋខ្មែរដែលមានចេតនាចង់លក់ដី ឬផ្ទះពួកគាត់តែងតែសរសេរអក្សរដាក់លើផ្លាកមួយថា ដីលក់ ឬ ផ្ទះលក់ដែលភ្ជាប់ជាមួយលេខទូរស័ព្ទទំនាក់ទំនងនៅទីកន្លែងដែលអចលនវត្ថុ

នោះតាំងនៅតែម្តង ហើយចំពោះអ្នកដែលមានធនធានច្រើនក៏គាត់ធ្វើការផ្សព្វផ្សាយតាមរយៈបណ្តាញផ្សព្វផ្សាយជាច្រើនផ្សេងទៀតផងដែរដូចជា៖ ទូរទស្សន៍, វិទ្យុ, សារព័ត៌មាន, គេហទំព័រ និង ហ្វេសប៊ុក (Facebook) ជាដើម ពីព្រោះតែសព្វថ្ងៃនេះគឺមានការរីកចម្រើនខ្លាំងលើផ្នែកបច្ចេកវិទ្យា។

ក្រោយពីទទួលបានព័ត៌មាន ឬការផ្សាយពាណិជ្ជកម្មនៃការលក់ទិញរបស់បុគ្គលម្ចាស់ដីរួចមក អ្នកទិញអាចធ្វើការទំនាក់ទំនងដើម្បីសាកសួរព័ត៌មានអំពីអចលនវត្ថុ (ដីធ្លី) ដូចជា៖ សាកសួរអំពីតម្លៃលក់របស់ដី ឯកសារដែលពាក់ព័ន្ធនឹងប្រភេទដី ( ប័ណ្ណភោគៈ និងប័ណ្ណកម្មសិទ្ធិ) សាកសួរពីប្រវត្តិរបស់អចលនវត្ថុនោះថាតើដីនោះមកពីណា មានទំហំប៉ុន្មាន និងសាកសួរអំពីស្ថានភាពនៃដីនោះថាតើដីនោះមានជម្លោះជាមួយអ្នកជិតខាងណាមួយដែរ ឬទេ និងសាកសួរអំពីព្រំដីជាដើម។

រីឯការប្រកាសលក់អគារសហកម្មសិទ្ធិវិញតាមរយៈការអង្កេត និងកត់សម្គាល់នាពេលកន្លងមកឃើញថា ក្រុមហ៊ុនដែលទទួលបានអាជ្ញាប័ណ្ណ ឬ បុគ្គលអភិវឌ្ឍអចលនវត្ថុ[១] តែងតែប្រើនូវមធ្យោបាយ នៃការផ្សាយពាណិជ្ជកម្មទៅឲ្យអតិថិជនរបស់ខ្លួនតាមរយៈ ទូរទស្សន៍, វិទ្យុ, សារព័ត៌មាន, ហ្វេសប៊ុក (Facebook) និងគេហទំព័រជាដើម និងមួយវិញទៀតនោះតាមរយៈភ្នាក់ងារទីផ្សាររបស់ខ្លួនដោយភ្នាក់ងារទីផ្សារធ្វើការចែក ឬ បិទផ្សាយខិតប័ណ្ណទៅតាមទីសាធារណៈ ក៏ដូចជានៅទីកន្លែងឯកជននានាដូចជា៖ នៅតាមដងវិថី ទីផ្សារ កន្លែងកំសាន្តនានា និងនៅតាមគេហដ្ឋានរបស់ប្រជាពលរដ្ឋមួយចំនួនជាដើម។

ដូច្នេះក្រោយពីការផ្សាយពាណិជ្ជកម្មរបស់បុគ្គលអភិវឌ្ឍអចលនវត្ថុ និងទទួលបានព័ត៌មានរួចមក អ្នកទិញអាចធ្វើការទំនាក់ទំនង ដើម្បីសាកសួរព័ត៌មាននៅតាមទីតាំងស្នាក់ការលក់ (មានស្នាក់ការកណ្តាល និងស្នាក់ការតាមទីតាំងសំណង់) របស់ក្រុមហ៊ុនអភិវឌ្ឍអចលនវត្ថុ ឬ តាមរយៈក្រុមហ៊ុនដែលទទួលបានអាជ្ញាប័ណ្ណពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដែលភាសាអង់គ្លេសហៅថា (Real Estate Group) ដើម្បីសាកសួរព័ត៌មានដែលទាក់ទងនឹងអគារសហកម្មសិទ្ធិដូចជា៖ សាកសួរអំពីតម្លៃដែលត្រូវលក់ អំពីការបង់រំលួស អំពីការបង់ប្រាក់កក់ និងឲ្យបង្ហាញអំពីលេខអាជ្ញាប័ណ្ណ និងកាលបរិច្ឆេទសុពលភាពនៃអាជ្ញាប័ណ្ណ និងឈ្មោះព្រមទាំងអាស្រ័យដ្ឋានរបស់បុគ្គលអភិវឌ្ឍអចលនវត្ថុ និងសិទ្ធិជាកម្មសិទ្ធិករលើដីផងដែរ។

---

[១] បុគ្គល ឬ អ្នកអភិវឌ្ឍអចលនវត្ថុ សំដៅដល់ រូបវន្តបុគ្គល ឬ នីតិបុគ្គលដែលដាក់ទុនវិនិយោគលើការសាងសង់អគារសហកម្មសិទ្ធិ ក្នុងគោលបំណងសម្រាប់លក់ ឬ ជួល។

ប្រសិនដីនោះជាដីភតិសន្យាត្រូវបង្ហាញពីកាលបរិច្ឆេទផុតកំណត់ និងសំណុំបែបបទ ព្រមទាំងលក្ខខណ្ឌដែលពាក់ព័ន្ធនឹងកម្មវត្ថុនៃការប្រើប្រាស់ដីនោះ និងចុងក្រោយឲ្យបង្ហាញអំពីគំរូប័ណ្ណ សៀវភៅ ឬស្លាកយីហោ និងរូបភាពផ្សាយពាណិជ្ជកម្មស្ដីពីគម្រោងអភិវឌ្ឍអចលនវត្ថុ ប្រសិនបើពុំមានអ្នកប្រាប់ ឬផ្ដល់អំពីព័ត៌មានទាំងអស់នោះ។

មួយវិញទៀតនោះដើម្បីឲ្យទទួលព័ត៌មានកាន់តែច្បាស់ ត្រឹមត្រូវ និងអាចទុកចិត្តបានអ្នកទិញត្រូវដឹងថា បុគ្គលអភិវឌ្ឍអចលនវត្ថុមួយណាមានបុគ្គលភាពគតិយុត្តស្របច្បាប់ ហើយទទួលបានសិទ្ធិធ្វើអាជីវកម្មអភិវឌ្ឍអចលនវត្ថុ និងភាពស្របច្បាប់នៃអគារសហកម្មសិទ្ធិ អ្នកទិញគួរតែធ្វើការសាកសួរ ឬ ស្វែងរកព័ត៌មានពីគ្រប់មជ្ឈដ្ឋាន ដូចជា៖ តាមអាជ្ញាធរមូលដ្ឋានដែលអគារនោះស្ថិតនៅ ទាំងថ្នាក់ឃុំសង្កាត់ ថ្នាក់ក្រុង ស្រុក ខណ្ឌ និងថ្នាក់រាជធានី-ខេត្ត ឬ ក៏មកដល់នាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដើម្បីដឹងព័ត៌មានលំអិតតែម្ដង ឬ ក៏អាចសាកសួរក្នុងស្ថាប័នមានសមត្ថកិច្ចណាមួយខាងលើ ដើម្បីដឹងថាអគារនោះមានលិខិតអនុញ្ញាតបើក ឬ បិទការដ្ឋាន ហើយឬនៅផងដែរ។

### ១.២. សិទ្ធិ និងករណីយកិច្ចរបស់អ្នកលក់ និងអ្នកទិញ

មុននឹងឈានដល់ដំណាក់កាលបង្កើតកិច្ចសន្យាភាគីគប្បីស្វែងយល់អំពីសិទ្ធិ និងករណីយកិច្ចរបស់ខ្លួនដែលមានចែងក្នុងច្បាប់ជាមុនសិន កុំឲ្យមានបញ្ហាកើតឡើងនៅពេលក្រោយការចុះកិច្ចសន្យាដោយសារតែយើងមិនបានដឹងអំពីទំហំនៃសិទ្ធិរបស់យើងមានត្រឹមណា ឬ ត្រូវបំពេញករណីយកិច្ចអ្វីខ្លះនៅពេលកើតមានកិច្ចសន្យា។ យើងដឹងហើយថានៅពេលដែលមានកិច្ចសន្យាមួយកើតមានឡើងនោះនឹងនាំឲ្យសិទ្ធិ និងករណីយកិច្ចរវាងគូភាគីក៏នឹងកើតមានឡើងដែរ។ ដូច្នេះថាតើសិទ្ធិ និង ករណីយកិច្ចរបស់អ្នកលក់ និងអ្នកទិញមានអ្វីខ្លះ? និងខុសគ្នាយ៉ាងដូចម្ដេចដែរ? ចម្លល់ទាំងអស់នេះយើងនឹងសិក្សានៅខាងក្រោមនេះ៖

#### ១.២.១. សិទ្ធិ និងករណីយកិច្ចរបស់អ្នកលក់

**សិទ្ធិរបស់អ្នកលក់:** អ្នកលក់មានសិទ្ធិមួយចំនួនដូចជា៖ សិទ្ធិជួសជុល សិទ្ធិតវ៉ាអនុវត្តព្រមគ្នា និងសិទ្ធិតវ៉ាដោយមានការបារម្ភ និងចុងក្រោយសិទ្ធិទទួលផល។

– សិទ្ធិជួសជុលរបស់អ្នកលក់ ៖ ក្នុងករណីដែលអ្នកលក់ប្រគល់វត្ថុដែលមានវិការៈមុនពេលកំណត់ត្រូវប្រគល់ អ្នកលក់នោះអាចជួសជុលវិការៈរហូតដល់ពេលកំណត់នោះបាន។ ប៉ុន្តែ អ្នកទិញ

មិនត្រូវបានរារាំងក្នុងការអនុវត្តសិទ្ធិទាមទារសំណងនៃការខូចខាតឡើយ[២] ។ ទោះបីជាក្រោយពេលកំណត់ត្រូវប្រគល់ក៏ដោយ អ្នកលក់អាចជួសជុលវិការៈទាំងអស់ដោយចេញចំណាយដោយខ្លួនឯងបានលុះត្រាតែមិនបណ្តាលឲ្យមានការខូចខាតផលប្រយោជន៍ហួសហេតុដល់អ្នកទិញ។ ប៉ុន្តែ អ្នកទិញមិនត្រូវបានរារាំងក្នុងការអនុវត្តសិទ្ធិរំលាយនិងសិទ្ធិទាមទារសំណងនៃការខូចខាតឡើយ[៣]។

– សិទ្ធិតវ៉ាអនុវត្តព្រមគ្នា និងសិទ្ធិតវ៉ាដោយមានការបារម្ភ ៖ អ្នកលក់អាចប្រកែកមិនព្រមផ្ទេរសិទ្ធិដែលជាកម្មវត្ថុ និងមិនព្រមប្រគល់វត្ថុដែលជាកម្មវត្ថុទៅអ្នកទិញបាន រហូតដល់ពេលដែលអ្នកទិញបានផ្តល់ការសង ចំពោះកាតព្វកិច្ចបង់ថ្លៃលក់[៤] ។

– សិទ្ធិទទួលផល ៖ ក្នុងករណីដែលជាកម្មវត្ថុនៃការលក់បានបង្កើតផលធម្មជាតិមុនពេលប្រគល់ទៅអ្នកទិញ ផលនេះត្រូវទុកជាកម្មសិទ្ធិរបស់អ្នកលក់ លើកលែងតែមានការព្រមព្រៀងគ្នាពិសេសរវាងគូភាគី។ ក្នុងករណីនេះត្រូវអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលកម្មវត្ថុនៃការលក់ បង្កើតផលស៊ីវិលដូចជាថ្លៃឈ្នួល ជាអាទិ៍[៥] ។

**ករណីយកិច្ចរបស់អ្នកលក់:** យោងតាមក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ករណីយកិច្ចរបស់អ្នកលក់មានដូចជា៖ ករណីយកិច្ចពន្យល់ ករណីយកិច្ចត្រូវផ្ទេរសិទ្ធិ ករណីយកិច្ចប្រគល់វត្ថុដែលជាកម្មវត្ថុ ករណីយកិច្ចរក្សាទុកវត្ថុដែលជាកម្មវត្ថុ ករណីយកិច្ចប្រគល់លិខិតផ្សេងៗដែលចាំចាច់ដើម្បីបញ្ជាក់នូវសិទ្ធិ និងចុងក្រោយករណីយកិច្ចធានា។

– ករណីយកិច្ចពន្យល់ ៖ អ្នកលក់មានករណីយកិច្ចត្រូវពន្យល់ឲ្យបានច្បាស់លាស់នូវខ្លឹមសារនៃករណីយកិច្ចដែលអ្នកលក់ទទួលបន្ទុក ទំនាក់ទំនងគតិយុត្តដែលទាក់ទងនឹងវត្ថុ ឬ សិទ្ធិដែលជាកម្មវត្ថុនៃការលក់ទិញ ហើយជាពិសេសក្នុងករណីលក់អចលនវត្ថុ ត្រូវពន្យល់ដល់អ្នកទិញឲ្យបានច្បាស់លាស់នូវខ្លឹមសារនៃសិទ្ធិ ការទទួលបន្ទុក និងព្រំនៃអចលនវត្ថុ ជាអាទិ៍[៦]។ ការធ្វើបែបនេះ (ដើម្បីជៀសវៀងកុំឲ្យមានវិវាទកើតឡើងនាពេលអនាគត គូភាគីគួរតែបង្កើតកិច្ចសន្យាលក់ទិញ ដោយយល់ខ្លឹមសារចម្បងនៃកិច្ចសន្យានោះដោយត្រឹមត្រូវ។ ក្នុងកិច្ចសន្យាលក់ទិញ ករណីយកិច្ចរបស់អ្នកទិញ

[២] មាត្រា៥៤១ កថាខណ្ឌទី១, ក្រមរដ្ឋប្បវេណី, លេខនស/រកម/១២-០៧/ចុះថ្ងៃទី១៨, ធ្នូ, ២០០៧។

[៣] មាត្រា៥៤១ កថាខណ្ឌទី២, ក្រមរដ្ឋប្បវេណី, លេខនស/រកម/១២-០៧/ចុះថ្ងៃទី១៨, ធ្នូ, ២០០៧។

[៤] មាត្រា៥៥១ កថាខណ្ឌទី១, ក្រមរដ្ឋប្បវេណី, លេខនស/រកម/១២-០៧/ចុះថ្ងៃទី១៨, ធ្នូ, ២០០៧។

[៥] មាត្រា៥៥៣, ក្រមរដ្ឋប្បវេណី, លេខនស/រកម/១២-០៧/ចុះថ្ងៃទី១៨, ធ្នូ, ២០០៧។

[៦] មាត្រា៥២៩, ក្រមរដ្ឋប្បវេណី, លេខនស/រកម/១២-០៧/ចុះថ្ងៃទី១៨, ធ្នូ, ២០០៧។

មានភាពច្បាស់លាស់ ដោយសារករណីយកិច្ចចម្បងនោះមានតែករណីយកិច្ចបង់ថ្លៃលក់ទិញប៉ុណ្ណោះ ។ ផ្ទុយទៅវិញ ករណីយកិច្ច និងការទទួលខុសត្រូវរបស់អ្នកលក់អាចមានខ្លឹមសារផ្សេងៗ ហើយជាទូទៅ អ្នកលក់មានព័ត៌មានអំពីវត្ថុដែលជាកម្មវត្ថុនៃការលក់ទិញ។ ប្រសិនបើអ្នកលក់បំពានករណីយកិច្ចពន្យល់នេះ អ្នកលក់ត្រូវទទួលខុសត្រូវចំពោះការខូចខាតដែលបានកើតឡើងដោយសារការបំពាននោះ។ លើសពីនេះទៅទៀត ប្រសិនបើអ្នកលក់ពន្យល់ហេតុមិនពិត ឬ លាក់ហេតុពិត ដោយចេតនាចំពោះចំណុចដែលមានឥទ្ធិពលលើការសម្រេចរបស់អ្នកទិញក្នុងការធ្វើ ឬ មិនធ្វើកិច្ចសន្យា ហើយជាលទ្ធផល នាំឲ្យអ្នកទិញភាន់ច្រឡំ និង ធ្វើកិច្ចសន្យាដោយផ្អែកលើការភាន់ច្រឡំនេះ អាចមានករណីដែលកិច្ចសន្យានោះត្រូវបានលុបចោលដោយយកការឆបោក ឬ ការភាន់ច្រឡំមកធ្វើជាមូលហេតុ)[៧]។

– ករណីយកិច្ចត្រូវផ្ទេរសិទ្ធិ ៖ អ្នកលក់ត្រូវមានករណីយកិច្ចផ្ទេរសិទ្ធិលើទ្រព្យសម្បត្តិដែលខ្លួនបានលក់[៨] ។ និង (អ្នកលក់មានករណីយកិច្ចត្រូវផ្ទេរសិទ្ធិលើទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការលក់ទិញទៅឲ្យអ្នកទិញ។ ប្រសិនបើកម្មវត្ថុនៃការលក់ទិញជាសិទ្ធិរបស់អ្នកដទៃ អ្នកលក់មានករណីយកិច្ចត្រូវទទួលសិទ្ធិនោះ ហើយត្រូវផ្ទេរសិទ្ធិនោះទៅឲ្យអ្នកទិញ។ ហើយប្រសិនបើអ្នកលក់មិនអាចផ្ទេរសិទ្ធិដែលជាកម្មវត្ថុនៃការលក់ទិញទៅឲ្យអ្នកទិញបានទេ អ្នកទិញអាចរំលាយកិច្ចសន្យាបាន ហើយអ្នកទិញអាចទាមទារសំណងនៃការខូចខាតបាន ប្រសិនបើអ្នកទិញមិនបានដឹងថាសិទ្ធិនោះមិនមែនជាសិទ្ធិរបស់អ្នកលក់ទេ)[៩]។ ដូចនេះការផ្ទេរកម្មសិទ្ធិ គឺជាករណីយកិច្ចដ៏សំខាន់នៅក្នុងកិច្ចសន្យាលក់ទិញពីព្រោះកិច្ចសន្យាលក់ទិញធ្វើឡើងក្នុងគោលបំណង ដើម្បីផ្ទេរកម្មសិទ្ធិពីអ្នកលក់ទៅឲ្យអ្នកទិញ។ ការផ្ទេរកម្មសិទ្ធិក្នុងកិច្ចសន្យាលក់ទិញ ត្រូវអនុវត្តតាមគោលការណ៍ទូទៅ គឺការបង្កើត ការផ្ទេរ និងការកែប្រែនូវសិទ្ធិប្រត្យក្ស ត្រូវមានអានុភាពតាមការព្រមព្រៀងរវាងភាគី[១០] ។ ប៉ុន្តែលក្ខខណ្ឌតតាំងនៃការបង្កើតការផ្ទេរ និងការកែប្រែនូវសិទ្ធិប្រត្យក្សលើអចលនវត្ថុ ក្រៅពីសិទ្ធិកាន់កាប់ សិទ្ធិឃាត់ទុកសិទ្ធិប្រើប្រាស់ និងសិទ្ធិអាស្រ័យនៅ មិនអាចតតាំងនឹងតតិយជនបានឡើយ បើពុំបានចុះបញ្ជីសិទ្ធិនោះតាម បញ្ញត្តិនៃច្បាប់ ឬ បទដ្ឋានគតិយុត្តផ្សេង ដែលទាក់ទងនឹងការចុះបញ្ជី[១១] ។ ដូចនេះជារួមមកកិច្ចសន្យាលក់

[៧] មាត្រា៥២៩,សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណីភាគ៣ គន្លឹទី៥, ឆ្នាំ២០១០។

[៨] មាត្រា៥៣០, ក្រមរដ្ឋប្បវេណី, លេខនស/រកម/១២-០៧/ចុះថ្ងៃទី១៨, ធ្នូ, ២០០៧។

[៩] មាត្រា៥៣១, ក្រមរដ្ឋប្បវេណី, លេខនស/រកម/១២-០៧/ចុះថ្ងៃទី១៨, ធ្នូ, ២០០៧។

[១០] មាត្រា១៣៣, ក្រមរដ្ឋប្បវេណី, លេខនស/រកម/១២-០៧/ចុះថ្ងៃទី១៨, ធ្នូ, ២០០៧។

[១១] មាត្រា១៣៤ កថាខណ្ឌទី១, ក្រមរដ្ឋប្បវេណី, លេខនស/រកម/១២-០៧/ចុះថ្ងៃទី១៨, ធ្នូ, ២០០៧។

ទិញអចលនវត្ថុដែលមានប័ណ្ណកម្មសិទ្ធិ នៅពេលមានការផ្ទេរកម្មសិទ្ធិ ពេលនោះការចុះបញ្ជីផ្ទេរកម្មសិទ្ធិនឹងត្រូវបានធ្វើឡើង ប៉ុន្តែកិច្ចសន្យាលក់ទិញអចលនវត្ថុដែលគ្មានប័ណ្ណកម្មសិទ្ធិ គឺមិនមានការចុះបញ្ជីផ្ទេរកម្មសិទ្ធិ នោះទេ មានតែការផ្ទេរការកាន់កាប់ដោយការព្រមព្រៀងរបស់គូរភាគី និងមានការដឹងឮពីអាជ្ញាធរ មូលដ្ឋានតែប៉ុណ្ណោះ។

– ករណីយកិច្ចប្រគល់វត្ថុដែលជាកម្មវត្ថុ ៖ (អ្នកលក់ត្រូវមានករណីយកិច្ចប្រគល់វត្ថុដែលជាកម្មវត្ថុទៅឲ្យអ្នកទិញ តាមកាលបរិច្ឆេទ និងតាមទីកន្លែងដែលបានកំណត់នៅក្នុងកិច្ចសន្យា។ និងករណីដែលកំណត់តែពេលត្រូវបង់ថ្លៃលក់ប៉ុណ្ណោះ នោះត្រូវសន្មតថា ពេលកំណត់នៃការប្រគល់វត្ថុដែលជាកម្មវត្ថុ ក៏ដូចពេលកំណត់នៃការបង់ថ្លៃលក់ដែរ។ មួយវិញទៀតក្នុងករណីដែលមិនបានកំណត់កាលបរិច្ឆេទដែលត្រូវប្រគល់ផង មិនបានកំណត់កាលបរិច្ឆេទដែលត្រូវបង់ថ្លៃលក់ផង អ្នកលក់មានករណីយកិច្ចប្រគល់វត្ថុដែលជាកម្មវត្ថុទៅឲ្យអ្នកទិញ នៅពេលដែលអ្នកទិញទាមទារឲ្យប្រគល់។ ហើយក្នុងករណីដែលមិនបានកំណត់ទីកន្លែងដែលត្រូវប្រគល់ទេ ចំពោះការលក់វត្ថុដែលបានកំណត់ជាក់លាក់ អ្នកលក់ត្រូវប្រគល់វត្ថុដែលជាកម្មវត្ថុនៅទីកន្លែងដែលវត្ថុនោះស្ថិតនៅ នៅពេលធ្វើកិច្ចសន្យា និងចំពោះករណីក្រៅពីនេះ ត្រូវប្រគល់វត្ថុដែលជាកម្មវត្ថុនោះ នៅលំនៅឋានរបស់អ្នកទិញ។ លើសពីនេះទៅទៀតនោះអ្នកលក់ត្រូវចេញសោហ៊ុយសម្រាប់ប្រគល់ លើកលែងតែមានការព្រមព្រៀងគ្នាពិសេស។ ប៉ុន្តែ ប្រសិនបើសោហ៊ុយប្រគល់នោះកើតឡើងដោយសារអ្នកទិញបានប្តូរលំនៅឋាន ឬ ដោយសារអំពើអ្វីមួយរបស់អ្នកទិញ អ្នកទិញត្រូវទទួលបន្ទុកបង់នូវចំនួនកំណើននៃសោហ៊ុយនេះ[១២]។ ការប្រគល់វត្ថុត្រូវធ្វើឡើងតាមវិធីប្រគល់កម្មវត្ថុដោយជាក់ស្តែង វិធីប្រគល់ដោយសង្ខេប វិធីផ្ទេរការកាន់កាប់ដោយបញ្ជា ឬ វិធីប្តូរលក្ខណៈនៃការកាន់កាប់ តាមបញ្ញត្តិនៃមាត្រា ២២៩ (ការផ្ទេរការកាន់កាប់) នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។ ការប្រគល់អចលនវត្ថុអាចធ្វើឡើងបាន ដោយការប្រគល់សោនៃអគារ ឬ ប្រគល់ប័ណ្ណបញ្ជាក់សិទ្ធិ[១៣]។

– ករណីយកិច្ចរក្សាទុកវត្ថុដែលជាកម្មវត្ថុ ៖ អ្នកលក់ត្រូវមានករណីយកិច្ចថែរក្សាទុកវត្ថុដែលជាកម្មវត្ថុនៃការលក់ទិញដោយប្រុងប្រយ័ត្នក្នុងនាមជាអ្នកគ្រប់គ្រងដ៏ល្អ រហូតដល់ពេលប្រគល់វត្ថុនោះទៅឲ្យអ្នកទិញ[១៤] ។ ក្នុងករណីដែលអ្នកលក់ធ្វើឲ្យបាត់បង់ ឬ ធ្វើឲ្យខូចខាតកម្មវត្ថុដោយសារខ្លួនធ្វេស

---

[១២] មាត្រា៥៤៩, ក្រមរដ្ឋប្បវេណី, លេខនស/រកម/១២-០៧/ចុះថ្ងៃទី១៨, ធ្នូ, ២០០៧។

[១៣] មាត្រា៥៥០, ក្រមរដ្ឋប្បវេណី, លេខនស/រកម/១២-០៧/ចុះថ្ងៃទី១៨, ធ្នូ, ២០០៧។

[១៤] មាត្រា៥៥២ កថាខណ្ឌទី១, ក្រមរដ្ឋប្បវេណី, លេខនស/រកម/១២-០៧/ចុះថ្ងៃទី១៨, ធ្នូ, ២០០៧។

ប្រហែស អ្នកលក់ត្រូវទទួលខុសត្រូវសងសំណងនៃការខូចខាត[១៥] ។ ផ្ទុយទៅវិញ ប្រសិនបើការខូចខាតដោយករណីប្រធានសក្តិនោះ អ្នកលក់ត្រូវរួចផុតពីការទទួលខុសត្រូវ។

– ករណីយកិច្ចប្រគល់លិខិតផ្សេងៗ ដែលចាំចាច់ដើម្បីបញ្ជាក់នូវសិទ្ធិ ៖ អ្នកលក់មានកាតព្វកិច្ចត្រូវប្រគល់រាល់លិខិតផ្សេងៗដែលចាំចាច់ដើម្បីបញ្ជាក់នូវសិទ្ធិ[១៦] ។ "លិខិតផ្សេងៗ ដែលចាំបាច់ដើម្បីបញ្ជាក់សិទ្ធិ" គឺជាប័ណ្ណបញ្ជាក់សិទ្ធិដែលមានចែងនៅក្នុងមាត្រា ៥៥០ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ , លិខិតកិច្ចសន្យា ឬ ឯកសារចាំបាច់សម្រាប់ចុះបញ្ជី។

– ករណីយកិច្ចធានា ៖ អ្នកលក់មានករណីយកិច្ចធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើវត្ថុនៃកិច្ចសន្យាលក់ទិញនោះ ហើយផ្ទេរកម្មសិទ្ធិនោះទៅឲ្យអ្នកទិញ។ ប៉ុន្តែប្រសិនបើ អ្នកលក់មិនអាចធ្វើបានទេនោះ អ្នកលក់អាចរំលាយកិច្ចសន្យាដើម្បីរួចផុតពីករណីយកិច្ចផ្ទេរសិទ្ធិនោះ បានតែក្នុងករណីដែល "អ្នកលក់សុចរិត" ប៉ុណ្ណោះ។ ដូច្នេះអ្នកលក់សុចរិតមានករណីយកិច្ចទទួលសិទ្ធិដូចជា៖ អ្នកលក់សុចរិតអាចរំលាយកិច្ចសន្យានោះបាន តែត្រូវសងការខូចខាត[១៧] ។ ហើយអ្នកលក់សុចរិតអាចរំលាយកិច្ចសន្យានោះបាន ដោយមិនចាំបាច់សងការខូចខាតទេប្រសិនបើអ្នកទិញបានដឹងនៅពេលធ្វើកិច្ចសន្យាថាសិទ្ធិលើទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការលក់ទិញមិនមែនជាសិទ្ធិរបស់អ្នកលក់ទេ[១៨]។ ចំពោះអ្នកទិញ វិញ ប្រសិនបើកម្មវត្ថុនៃការលក់ទិញ ជាសិទ្ធិរបស់អ្នកដទៃ អ្នកលក់មានករណីយកិច្ចត្រូវ ទទួលសិទ្ធិ នោះ ហើយត្រូវផ្ទេរសិទ្ធិនោះទៅឲ្យអ្នកទិញ។ ហើយប្រសិនបើអ្នកលក់មិនអាចផ្ទេរសិទ្ធិដែល ជាកម្មវត្ថុនៃការលក់ទិញទៅឲ្យអ្នកទិញបានទេ អ្នកទិញអាចរំលាយកិច្ចសន្យានោះបាន ហើយអ្នកទិញអាចទាមទារសំណង នៃការខូចខាតបានប្រសិនបើអ្នកទិញមិនបានដឹងថា សិទ្ធិនោះមិនមែនជាសិទ្ធិរបស់អ្នកលក់ទេនៅពេលធ្វើកិច្ចសន្យា[១៩] ។

### ១.២.២. សិទ្ធិ និងករណីយកិច្ចរបស់អ្នកទិញ

**សិទ្ធិរបស់អ្នកទិញ:** អ្នកទិញមានសិទ្ធិមួយចំនួនដូចជា៖ សិទ្ធិទាមទារឲ្យអនុវត្តពេញលេញរបស់អ្នកទិញ សិទ្ធិរំលាយកិច្ចសន្យារបស់អ្នកទិញ សិទ្ធិទាមទារឲ្យបន្ថយថ្លៃលក់របស់អ្នកទិញ សិទ្ធិបដិសេធ

---

[១៥] មាត្រា៥៥២ កថាខណ្ឌទី២, ក្រមរដ្ឋប្បវេណី, លេខនស/រកម/១២-០៧/ចុះថ្ងៃទី១៨, ធ្នូ, ២០០៧។

[១៦] មាត្រា៥៣០, ក្រមរដ្ឋប្បវេណី, លេខនស/រកម/១២-០៧/ចុះថ្ងៃទី១៨, ធ្នូ, ២០០៧។

[១៧]មាត្រា៥៣២ កថាខណ្ឌទី១, ក្រមរដ្ឋប្បវេណី, លេខនស/រកម/១២-០៧/ចុះថ្ងៃទី១៨, ធ្នូ, ២០០៧។

[១៨]មាត្រា៥៣២ កថាខណ្ឌទី២, ក្រមរដ្ឋប្បវេណី, លេខនស/រកម/១២-០៧/ចុះថ្ងៃទី១៨, ធ្នូ, ២០០៧។

[១៩]មាត្រា៥៣១ កថាខណ្ឌទី២,៣, ក្រមរដ្ឋប្បវេណី, លេខនស/រកម/១២-០៧/ចុះថ្ងៃទី១៨, ធ្នូ, ២០០៧។

មិនបង់ថ្លៃទិញក្នុងករណីដែលតតិយជនអះអាងសិទ្ធិរបស់ខ្លួនលើវត្ថុ ដែលជាកម្មវត្ថុនៃការលក់ទិញ និងចុងក្រោយសិទ្ធិតវ៉ាអនុវត្តព្រមគ្នា និងសិទ្ធិតវ៉ាដោយមានការបារម្ភ។

– សិទ្ធិទាមទារឲ្យអនុវត្តពេញលេញរបស់អ្នកទិញ ៖ អ្នកទិញអាចទាមទារឲ្យអ្នកលក់ អនុវត្តករណីយកិច្ចបាន។ ប៉ុន្តែ មិនអាចទាមទារបានឡើយចំពោះការទាមទារឲ្យរំលាយ ឬ ឲ្យបន្ថយនូវតម្លៃលក់[២០] ។ ក្នុងករណីដែលកម្មវត្ថុនៃការលក់ទិញមានវិការៈ អ្នកទិញអាចទាមទារឲ្យអ្នកលក់ ប្រគល់វត្ថុជំនួសដែលគ្មានវិការៈ ឬ ជួសជុលវត្ថុដែលជាកម្មវត្ថុនោះបាន [២១]។

– សិទ្ធិរំលាយកិច្ចសន្យារបស់អ្នកទិញ ៖ ក្នុងករណីដែលអ្នកទិញមិនអាចសម្រេចគោលបំណងនៃកិច្ចសន្យាលក់ទិញបានដោយសារវត្ថុដែលត្រូវបានប្រគល់មានវិការៈ អ្នកទិញនោះអាចរំលាយកិច្ចសន្យានោះបាន[២២] ។

– សិទ្ធិទាមទារឲ្យបន្ថយថ្លៃលក់របស់អ្នកទិញ ៖ ក្នុងករណីវត្ថុដែលត្រូវបានប្រគល់មានវិការៈ ទោះបីជាថ្លៃលក់ត្រូវបានបង់រួចហើយក៏ដោយ ឬ មិនទាន់បង់ក៏ដោយ ក៏អ្នកទិញអាចទាមទារបន្ថយថ្លៃលក់នោះ តាមសមាមាត្រនៃភាពខុសគ្នានៅពេលប្រគល់ រវាងតម្លៃនៃវត្ថុដែលគ្មានវិការៈ និង តម្លៃនៃវត្ថុដែលត្រូវបានប្រគល់បានដែរ ប្រសិនបើមិនមានករណីដែលអ្នកទិញមិនព្រមទទួលសេចក្ដីស្នើផ្ដល់ការជួសជុលរបស់អ្នកលក់ដោយគ្មានមូលហេតុត្រឹមត្រូវ[២៣]។

– សិទ្ធិបដិសេធមិនបង់ថ្លៃទិញក្នុងករណី ដែលតតិយជនអះអាងសិទ្ធិរបស់ខ្លួនលើវត្ថុដែលជាកម្មវត្ថុនៃការលក់ទិញ៖ ក្នុងករណីដែលមានអ្នកអះអាងសិទ្ធិលើវត្ថុដែលជាកម្មវត្ថុនៃការលក់ទិញហើយមានការបារម្ភថា អ្នកទិញនឹងបាត់បង់នូវសិទ្ធិទាំងអស់ ឬ មួយភាគដែលខ្លួនបានទិញនោះ អ្នកទិញអាចបដិសេធមិនបង់ថ្លៃទិញទាំងអស់ ឬ មួយភាគទៅតាមទំហំនៃហានិភ័យនោះបាន ប្រសិនបើអ្នកលក់មិនបានដាក់ប្រាតិភោគសមរម្យ[២៤] ។

– សិទ្ធិតវ៉ាឲ្យអនុវត្តព្រមគ្នា និង សិទ្ធិតវ៉ាដោយមានការបារម្ភ[២៥] ៖ អ្នកទិញអាចមិនព្រមបង់ថ្លៃ

[២០]មាត្រា៥៤២ កថាខណ្ឌទី១ ក្រមរដ្ឋប្បវេណី, លេខនស/រកម/១២០៧/០៣០ ចុះថ្ងៃទី១៨, ធ្នូ, ២០០៧។

[២១]មាត្រា៥៤២ កថាខណ្ឌទី២,៣ ក្រមរដ្ឋប្បវេណី, លេខនស/រកម/១២០៧/០៣០ ចុះថ្ងៃទី១៨, ធ្នូ, ២០០៧។

[២២]មាត្រា៥៤៣, ក្រមរដ្ឋប្បវេណី, លេខនស/រកម/១២០៧/០៣០ចុះថ្ងៃទី១៨, ធ្នូ, ២០០៧។

[២៣]មាត្រា៥៤៤, ក្រមរដ្ឋប្បវេណី, លេខនស/រកម/១២០៧/០៣០ចុះថ្ងៃទី១៨, ធ្នូ, ២០០៧។

[២៤]មាត្រា៥៥៧ កថាខណ្ឌទី១, ក្រមរដ្ឋប្បវេណី, លេខនស/រកម/១២០៧/០៣០ ចុះថ្ងៃទី១៨, ធ្នូ, ២០០៧។

[២៥]មាត្រា៥៥៨, ប្បវេណី, លេខនស/រកម/១២០៧/០៣០ចុះថ្ងៃទី១៨, ធ្នូ, ២០០៧។

ទិញបាន រហូតដល់ពេលដែលអ្នកលក់បានផ្តល់នូវការសងចំពោះកាតព្វកិច្ចរបស់ខ្លួន។ ប៉ុន្តែមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលកាតព្វកិច្ចរបស់អ្នកលក់មិនទាន់ដល់ពេលកំណត់ត្រូវសង ឬ ករណីដែលមានការព្រមព្រៀងគ្នាអំពីការអនុវត្តកាតព្វកិច្ចបង់ថ្លៃជាមុន។ និងទោះបីជាអ្នកទិញ បានអនុញ្ញាតឲ្យអ្នកលក់មានពេលកំណត់ដើម្បីអនុវត្តកាតព្វកិច្ចក៏ដោយ ប្រសិនបើមានការបារម្ភយ៉ាងជាក់ស្តែ-ងថា អ្នកលក់នឹងមិនអនុវត្តកាតព្វកិច្ចរបស់ខ្លួន ក៏អ្នកទិញអាចប្រកែកមិនបង់ថ្លៃទិញបានដែរ។ ប៉ុន្តែមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលអ្នកលក់បានដាក់ប្រាតិភោគ ឬ ចាត់ចែងវិធានការដើម្បីរំលត់ការបារម្ភនោះ។

**ករណីយកិច្ចរបស់អ្នកទិញ:** ករណីយកិច្ចរបស់អ្នកទិញមានពីរគឺៈ ករណីយកិច្ចបង់ថ្លៃជាប្រាក់ដែលសន្យា និង ករណីយកិច្ចទទួលវត្ថុដែលខ្លួនបានទិញ។

- ករណីយកិច្ចបង់ថ្លៃទិញ[២៦] ៖ អ្នកទិញមានករណីយកិច្ចបង់ថ្លៃទិញជាប្រាក់ដែលបានកំណត់ក្នុងកិច្ចសន្យាតាមកាលបរិច្ឆេទ និងនៅទីកន្លែងដែលបានកំណត់ក្នុងកិច្ចសន្យា។ ...ក្នុងករណីនៃការលក់អចលនវត្ថុ ដែលមានតែកំណត់ពេលនៃការធ្វើសកម្មភាពចាំបាច់ដើម្បីចុះបញ្ជីអចលនវត្ថុនៃការលក់ប៉ុណ្ណោះនោះត្រូវសន្មតថាពេលកំណត់នៃការបង់ថ្លៃទិញ ក៏ដូចពេលកំណត់នៃការប្រគល់ ឬ ការធ្វើសកម្មភាពចាំបាច់ដើម្បីចុះបញ្ជីដែរ។ ក្នុងករណីដែលមិនបានកំណត់ពេលធ្វើសកម្មភាពចាំបាច់ដើម្បីចុះបញ្ជីអចលនវត្ថុដែលជាកម្មវត្ថុផង មិនបានកំណត់ពេលបង់ថ្លៃផង អ្នកទិញមានករណីយកិច្ចបង់ថ្លៃទៅអ្នកលក់ នៅពេលអ្នកលក់ទាមទារឲ្យអ្នកទិញបង់ ។ ក្នុងករណីដែលអ្នកទិញបង់ប្រាក់ក្រោយកាលបរិច្ឆេទដែលបានកំណត់នោះអ្នកទិញត្រូវទទួលខុសត្រូវចំពោះការយឺតយ៉ាវនៅក្នុងការអនុវត្ត។
- ករណីយកិច្ចទទួលវត្ថុដែលខ្លួនបានទិញ ៖ អ្នកទិញមានករណីយកិច្ចទទួលវត្ថុ ដែលខ្លួនបានទិញ[២៧] ។ ប្រសិនអ្នកលក់បានប្រគល់កម្មវត្ថុនៃកិច្ចសន្យាមកឲ្យអ្នកទិញ ប៉ុន្តែអ្នកទិញបដិសេធក្នុងការទទួលវត្ថុដែលបានប្រគល់ នោះអ្នកទិញ ត្រូវទទួលខុសត្រូវចំពោះការយឺតយ៉ាវនៅក្នុងការទទួល[២៨] ។ ក្នុងករណីដែលកម្មវត្ថុត្រូវបានបាត់បង់ ឬ ខូចខាតដោយគ្មានកំហុសរបស់អ្នកលក់ នោះវា គឺជាបញ្ហានៃ

[២៦]មាត្រា៥៥៥, ក្រមរដ្ឋប្បវេណី, លេខនស/រកម/១២០៧/០៣០ចុះថ្ងៃទី១៨, ធ្នូ, ២០០៧។
[២៧]មាត្រា៥៥៤, ក្រមរដ្ឋប្បវេណី, លេខនស/រកម/១២០៧/០៣០ ចុះថ្ងៃទី១៨, ធ្នូ, ២០០៧។
[២៨]មាត្រា៥៥៩, ក្រមរដ្ឋប្បវេណី, លេខនស/រកម/១២០៧/០៣០ចុះថ្ងៃទី១៨, ធ្នូ, ២០០៧។

ការទទួលបន្ទុកហានិភ័យ”។ នៅក្នុងករណីនេះអ្នកទិញត្រូវទទួលបន្ទុកហានិភ័យ ចំពោះការខូចខាត ឬ ការបាត់បង់[29] ។"

## កថាខណ្ឌទី២ ៖ ការចរចានៅក្នុងការលក់ទិញអចលនវត្ថុ

មុនកិច្ចសន្យាលក់ទិញកើតមានឡើងការចរចា គឺជាដំណាក់កាលមួយ ដែលក្នុងនោះគូភាគីនីមួយៗចាប់ផ្តើមធ្វើការពិភាក្សា អំពីចំណុចមួយចំនួន ឬ លក្ខខណ្ឌមួយចំនួនឲ្យបានច្បាស់លាស់ជាមុនសិន មុននឹងធ្វើការចុះកិច្ចសន្យានៅក្នុងពេលអនាគត។ នៅក្នុងដំណាក់កាលចរចានេះ ភាគីនីមួយៗពុំទាន់ជាប់ចំណងកាតព្វកិច្ចនៅឡើយទេ ដោយសារតែគូភាគីក៏ពុំទាន់បានផ្តល់ការព្រមព្រៀងនឹងគ្នានៅឡើយដែរ។ យើងដឹងហើយថាដំណាក់នេះ ជាដំណាក់កាលមួយដែលអាចឈានទៅដល់ ការត្រូវរូវគ្នាក្នុងការចុះកិច្ចសន្យា ឬ អាចឈានដល់ការព្រមព្រៀងគ្នាលក់ទិញ ប្រសិនបើគូភាគីទាំងសងខាងធ្វើការពិភាក្សាត្រូវគ្នា តែបើការចរចាមិនបានសម្រេច ឬ មិនត្រូវរូវគ្នាទេនោះការចរចានឹងត្រូវបានបញ្ចប់នៅពេលនោះផងដែរ។ ក្នុងចំណុចនេះយើងនឹងធ្វើការសិក្សាទៅលើការចរចាពីតម្លៃ (២.១) ការចរចាពីប្រាក់កក់ (២.២) និងការចរចាអំពីករណីបង់រំលួស (២.៣)។

### ២.១. ការចរចាពីតម្លៃ

នៅក្នុងការលក់ទិញទាំងអស់ មិនថាតែការលក់ទិញអចលនវត្ថុនោះទេ តម្លៃគឺជាចំណុចមួយដែលអ្នកទិញគិតទៅដល់មុនគេ ហើយក៏វាជាចំណុចមួយដែលគូភាគីលើកមកនិយាយ ឬ ចរចាមុនគេផងដែរនៅក្នុងការលក់ទិញ។ ដូចនេះ ថ្លៃលក់ទិញ គឺជាកត្តាមួយដ៏សំខាន់ណាស់នៅក្នុងកិច្ចសន្យាលក់ទិញ ដែលវាតម្រូវឲ្យគូភាគីធ្វើការចរចាកំណត់ឲ្យបានច្បាស់លាស់។ ដូច្នេះ ភាគីនៃកិច្ចសន្យាត្រូវកំណត់ចំនួនប្រាក់នៃថ្លៃលក់ទិញ ឬ វិធីកំណត់ចំនួនប្រាក់នោះនៅក្នុងកិច្ចសន្យា[30] ។ ហើយមួយវិញទៀតនោះ ចំនួនប្រាក់នៃថ្លៃលក់ទិញអាចត្រូវបានកំណត់ ដោយយោលទៅតាមតម្លៃនៃទំនិញណាមួយនៅទីផ្សារក្នុងពេលបច្ចុប្បន្ន ឬ អនាគត ឬ ដោយផ្អែកលើការវាយតម្លៃដែលធ្វើដោយតតិយជនដែលត្រូវបានជ្រើសរើស តាមរបៀបកំណត់ដោយគូភាគី។ ក្នុងករណីដែលការវាយតម្លៃរបស់តតិយជនត្រូវបានធ្វើឡើងដោយភាន់ច្រឡំ ឬ ករណីដែលការវាយតម្លៃនោះច្បាស់ជាផ្ទុយនឹងសមភាព ភាគីនៃកិច្ច

[29] មាត្រា៥៥៩ កថាខណ្ឌទី២, ក្រមរដ្ឋប្បវេណី, លេខនស/រកម/១២០៧/០៣០ចុះថ្ងៃទី១៨, ធ្នូ, ២០០៧។

[30] មាត្រា៥២១ កថាខណ្ឌទី១, ក្រមរដ្ឋប្បវេណី, លេខនស/រកម/១២០៧/០៣០ចុះថ្ងៃទី៨, ធ្នូ, ២០០៧។

សន្យាដែលទទួលការខូចខាតផលប្រយោជន៍របស់ខ្លួន ដោយសារការវាយតម្លៃនោះ អាចតវ៉ាចំពោះការវាយតម្លៃនោះបាន[៣១] ។ មួយវិញទៀតនោះ ភាគីនៃកិច្ចសន្យាអាចកំណត់ចំនួនថ្លៃលក់ទិញដោយបង្ហាញចំនួនថ្លៃដើមពិតប្រាកដ ឬ ដោយឲ្យអ្នកទិញបង់ថ្លៃដែលមិនបានកំណត់ពេល ឬ ធនលាភមួយជីវិតបាន[៣២] ។

នៅក្នុងដំណាក់កាលការចរចាតម្លៃនេះផងដែរ ភាគីក៏អាចចរចានូវប្រភេទនៃវត្ថុបិយវត្ថុ ដែលត្រូវទូទាត់ក្នុងកិច្ចសន្យា និងសោហ៊ុយធ្វើលិខិត ឬ សោហ៊ុយផ្សេងៗដែលត្រូវចំណាយក្នុងការធ្វើកិច្ចសន្យាលក់ទិញ ឬ សោហ៊ុយក្នុងការជួលមេធាវី ដែលក្នុងចំណុចនេះច្បាប់បានចែងឲ្យភាគីទទួលបន្ទុកស្មើគ្នា (ពីព្រោះថាវាជាផលប្រយោជន៍របស់ភាគីទាំងពីរ) ឬ ក៏តាមរយៈការកំណត់ផ្សេងរបស់គូភាគី[៣៣]។ ប៉ុន្តែចំពោះសោហ៊ុយសម្រាប់នីតិវិធីចាំបាច់ ដើម្បីឲ្យអ្នកទិញធ្វើលទ្ធកម្មនូវសិទ្ធិដោយពិតប្រាកដ (ការចុះបញ្ជីដែលជាលក្ខខណ្ឌដើម្បីបង្កើតអានុភាព នៃការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុដោយការព្រមព្រៀង ការចុះបញ្ជីដែលជាលក្ខខណ្ឌតតាំងនៃការបង្កើតជាអាទិ៍) គឺជាសោហ៊ុយសម្រាប់អនុវត្តកាតព្វកិច្ច ហេតុនេះហើយសោហ៊ុយនេះ គឺជាបន្ទុករបស់អ្នកលក់ ប្រសិនបើគ្មានការព្រមព្រៀងរវាងភាគីទេ[៣៤] ។

### ២.២. ការចរចារពីប្រាក់កក់

នៅក្នុងការលក់ទិញអចលនវត្ថុការបង់ប្រាក់កក់ ក៏វាជាចំណុចមួយដែលយើងគួរដឹងផងដែរថាតើគេបង់ប្រាក់កក់ដើម្បីអ្វី និងសម្រាប់ធ្វើអ្វី? ជាដំបូងនេះយើងគួរស្វែងយល់អំពីនិយមន័យនៃប្រាក់កក់ជាមុនសិន ប្រាក់កក់ គឺជាប្រាក់ដែលបង់ដោយអ្នកទិញទៅឲ្យអ្នកលក់ នៅពេលបង្កើតកិច្ចសន្យាដើម្បីធានាសិទ្ធិរបស់ខ្លួនក្នុងការរំលាយកិច្ចសន្យា។ និងប្រាក់កក់បង់សម្រាប់ធានាការជួលវត្ថុអ្វីមួយហើយត្រូវសងវិញ នៅពេលប្រគល់វត្ថុនោះត្រឡប់ឲ្យវិញ ដោយគ្មានការខូចខាត[៣៥] ។ ហើយនៅក្នុងអត្ថន័យនៃមាត្រា ៥១៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧បានចែងអំពីប្រាក់កក់ថា "បើអ្នកទិញបានបង់ប្រាក់កក់ទៅឲ្យអ្នកលក់ អ្នកទិញអាចរំលាយកិច្ចសន្យាលក់ទិញដោយបោះបង់ចោលនូវប្រាក់កក់នោះ

[៣១] មាត្រា៥២១ កថាខណ្ឌទី២, ក្រមរដ្ឋប្បវេណី, លេខនស/រកម/១២០៧/០៣០ ចុះថ្ងៃទី៨, ធ្នូ, ២០០៧។

[៣២] មាត្រា៥២១កថាខណ្ឌទី៣, ក្រមរដ្ឋប្បវេណី, លេខនស/រកម/១២០៧/០៣០ចុះថ្ងៃទី៨, ធ្នូ, ២០០៧។

[៣៣] មាត្រា៥២២, ក្រមរដ្ឋប្បវេណី, លេខនស/រកម/១២០៧/០៣០ចុះថ្ងៃទី៨, ធ្នូ, ២០០៧។

[៣៤] មាត្រា៤៩៦ , ក្រមរដ្ឋប្បវេណី, លេខនស/រកម/១២០៧/០៣០ ចុះថ្ងៃទី៨,ធ្នូ,២០០៧។

[៣៥] សន្ទានុក្រមផ្នែករដ្ឋប្បវេណីឆ្នាំ២០០៧, លេខ១០២។

បាន រីឯអ្នកលក់អាចរំលាយកិច្ចសន្យាលក់ទិញដោយសងប្រាក់ស្មើនឹងពីរដងនៃប្រាក់កក់នេះមកវិញបានដែរ។ ប៉ុន្តែ ភាគីមិនអាចរំលាយកិច្ចសន្យាបានឡើយ ក្រោយពេលភាគីម្ខាងទៀតបានចាប់ផ្តើមអនុវត្តកិច្ចសន្យាហើយ[៣៦]។ ប៉ុន្តែនៅក្នុងការអនុវត្តសព្វថ្ងៃនេះ យើងសង្កេតឃើញថានៅក្នុងការធ្វើកិច្ចសន្យាលក់ទិញមួយចំនួនដែលភាគីខិលខូចខ្លះ តែងតែបន្ថែមចំនួនប្រាក់កក់ហួសពីច្បាប់ដែលបានកំណត់ដោយភាគីខ្លះបានកំណត់ឲ្យសងប្រាក់កក់ដល់ទៅប្រាំដង ឬ ដប់ដងក៏មាន ដែលនេះហើយជាអំពើមួយដែលមានការរំលោភបំពានលើច្បាប់។ ហើយអាចធ្វើឲ្យខូចខាតប្រយោជន៍យ៉ាងធ្ងន់ធ្ងរដល់ភាគីម្ខាងទៀត ដែលនាំឲ្យមានបញ្ហានៅក្នុងការចរចា និងធ្វើឲ្យគូភាគីបាត់បង់ទំនុកចិត្តរវាងគ្នាទៅវិញទៅមក។

ប្រាក់កក់មានតួនាទីមួយចំនួនដែលគូភាគីគួរយល់ដឹង ដូចជាៈ បញ្ជាក់នូវការបង្កើតកិច្ចសន្យា (ប្រាក់កក់បញ្ជាក់កិច្ចសន្យា) បបនីយនូវសិទ្ធិរំលាយកិច្ចសន្យា (ប្រាក់កក់សម្រាប់រំលាយកិច្ចសន្យា) រឺបអូសយកប្រាក់កក់ក្នុងករណីដែលមិនអនុវត្តកាតព្វកិច្ច (យកប្រាក់កក់មកធ្វើជាប្រាក់ធានាបំណុលក្នុងករណីបំពានកិច្ចសន្យា) និង (ប្រាក់កក់ធានាសំណងក្នុងករណីបំពានកិច្ចសន្យា) ជាអាទិ៍[៣៧]។ ការចរចាអំពីប្រាក់កក់នេះ គូភាគីគួរធ្វើការចរចាកំណត់នូវចំនួននៃប្រាក់កក់ដែលត្រូវបង់យ៉ាងណាឲ្យសមាមាត្រទៅនឹងតម្លៃដើមរបស់អចលនវត្ថុ។ មួយវិញទៀតនោះគូភាគីគួរតែប្រកាន់ភ្ជាប់នៅគោលការណ៍សុចរិតភាព និងភាពស្មោះត្រង់ចំពោះគ្នាទៅវិញទៅមកនៅក្នុងការចរចា។ ជាគោលការណ៍ នៅក្នុងរឿងរដ្ឋប្បវេណីឲ្យតែមានការព្រមព្រៀងគ្នារវាងគូភាគី គឺអាចធ្វើទៅបានហើយ ដូចគ្នាផងដែរនៅក្នុងការចរចាអំពីប្រាក់កក់ ប្រសិនបើគូភាគីព្រមព្រៀងគ្នាថាបង់ប្រាក់កក់ចំនួនណាហើយ នោះការចរចានឹងបានសម្រេចហើយ។

### ២.៣. ការចរចាអំពីករណីបង់រំលស់

ការបង់រំលស់ គឺជាវិធីសាស្ត្រដ៏ល្អមួយសម្រាប់អ្នកដែលគ្មានប្រាក់កាក់ច្រើនបង់ផ្តាច់ ឬបង់គ្រប់តម្លៃនៃវត្ថុនោះភ្លាមៗ ដែលអាចបង់ប្រាក់ជាដំណាក់កាលតិចៗ ឬ រំដោះបន្តិចម្តងៗទៅតាមការព្រមព្រៀងរបស់គូភាគី។ ហើយការបង់រំលស់នេះ គឺវាបានបង្កប់ជាស្រេចនូវអត្រាការប្រាក់ នៅក្នុងនោះរួចស្រេចទៅហើយ គ្រាន់តែអាត្រាការប្រាក់នោះអាចមានតិច ឬ ច្រើនតែប៉ុណ្ណោះ។

[៣៦] មាត្រា៥១៨ , ក្រមរដ្ឋប្បវេណី, លេខនស/រកម/១២០៧/០៣០ ចុះថ្ងៃទី៨, ធ្នូ, ២០០៧។

[៣៧] មាត្រា៥១៨,សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណីភាគ៣ គន្លីទី៥, ឆ្នាំ២០១០។

ប្រសិនបើអ្នកមិនសូវមានលុយ នៅក្នុងការបង់ផ្តាច់សម្រាប់ការទិញអចលនវត្ថុនោះទេអ្នកគួរតែគិតពិចារណាទៅលើការបង់រំលួសអចលនវត្ថុនោះ។ នៅក្នុងការបង់រំលួសនេះគឺមានជម្រើស២(ពីរ)គឺៈ

– ទី១: អ្នកអាចធ្វើការបង់រំលស់នៅក្រុមហ៊ុនអភិវឌ្ឍអចលនវត្ថុ ឬ នៅនឹងអ្នកលក់នោះដោយផ្ទាល់។ ជាទូទៅនៅក្នុងការបង់រំលួសនៅក្រុមហ៊ុនអភិវឌ្ឍអចលនវត្ថុនេះ អត្រាការប្រាក់ គឺច្រើនជាងជម្រើសទី២ (ការខ្ចីលុយនៅធានាគារ) ហើយអាចធ្វើការផ្ទេរប័ណ្ណកម្មសិទ្ធិលុះត្រាតែអតិថិជនបង់គ្រប់តម្លៃនៃអចលនវត្ថុ១០០%។

– ទី២: ការខ្ចីលុយនៅធនាគារ ឬ ហៅថាឥណទានគេហដ្ឋាន គឺមានគោលដៅផ្តោតទៅលើរូបវន្តបុគ្គលដែលមានមុខរបរ និងចំណូលច្បាស់លាស់ និងទៀងទាត់មានលក្ខណសម្បត្តិគ្រប់គ្រាន់ ដើម្បីទទួលបានប្រាក់កម្ចីពីធនាគារ និងមានបំណងស្នើសុំខ្ចីប្រាក់ដើម្បីយកទៅទិញ ឬ សាងសង់គេហដ្ឋានលើដីកម្មសិទ្ធិដែលមានស្រាប់។ យើងបានដឹងរួចហើយថាការបង់រំលស់នៅក្រុមហ៊ុនអភិវឌ្ឍអចលនវត្ថុមានអត្រាការប្រាក់ច្រើនជាង ហើយការទទួលបានប័ណ្ណកម្មសិទ្ធិ លុះត្រាតែអតិថិជនបង់គ្រប់តម្លៃនៃអចលនវត្ថុ១០០% ប៉ុន្តែការខ្ចីលុយនៅធនាគារ អ្នកទិញអាចក្លាយជាកម្មសិទ្ធិករភ្លាមៗ នៅពេលចុះកិច្ចសន្យាជាមួយនឹងក្រុមហ៊ុនអភិវឌ្ឍអចលនវត្ថុ គ្រាន់តែអ្នកនៅជំពាក់លុយនៅធនាគារ ដោយយកទ្រព្យដែលទិញនោះ មកដាក់ជាវត្ថុធានា។ ដូច្នេះប្រសិនជាអ្នកចង់ទទួលបានប័ណ្ណកម្មសិទ្ធិមុន ដើម្បីបង្ការហានិភ័យផ្សេងៗ គឺគប្បីជ្រើសរើសប្រើប្រាស់សេវាឥណទានគេហដ្ឋានរបស់ធនាគារ ប៉ុន្តែប្រសិនអ្នកគិតថាទ្រព្យដែលនឹងទិញ គឺគ្មានហានិភ័យអ្វីឡើយ ដូចនេះ អ្នកក៏អាចជ្រើសរើសជាការបង់រំលស់នៅក្រុមហ៊ុនអភិវឌ្ឍអចលនវត្ថុបានដែរ។

ជារួមមកប្រសិនបើអ្នកជ្រើសរើសយកសេវាកម្មបង់រំលួស គួរគម្បីធ្វើការជ្រើសរើសនូវជម្រើសណាមួយដែលប្រសើរទៅដល់អ្នក និងអ្នកគួរតែធ្វើការចរចាអំពីការបង់រំលួសនេះឲ្យបានច្បាស់លាស់ផងដែរ ប្រសិនបើអ្នកជ្រើសរើសប្រើប្រាស់សេវាបង់រំលួសជាមួយក្រុមហ៊ុនអភិវឌ្ឍអចលនវត្ថុ ឬ ជាមួយអ្នកលក់។

## ផ្នែកទី២ ៖ ការត្រួតពិនិត្យអចលនវត្ថុ

ក្រោយពីយើងធ្វើការសាកសួរព័ត៌មាន និងធ្វើការស្វែងយល់អំពីសិទ្ធិ និងករណីយកិច្ចរបស់ភាគី និងព្រមទាំងបានធ្វើការចរចារួចចប់សព្វគ្រប់ហើយមក ក៏យើងមិនទាន់ឈានដល់ដំណាក់កាលចុះកិច្ចសន្យាលក់ទិញអចលនវត្ថុភ្លាមដែរ គឺយើងត្រូវធ្វើការត្រួតពិនិត្យអចលនវត្ថុជាមុនសិន។ ដែល

ក្នុងចំណុចនេះយើងនឹងធ្វើការសិក្សាទៅលើ ការត្រួតពិនិត្យប្រភេទឯកសារដែលពាក់ព័ន្ធនឹងអចលនវត្ថុ (កថាខណ្ឌទី១) និងការត្រួតពិនិត្យស្ថានភាពជុំវិញអចលនវត្ថុ (កថាខណ្ឌទី២)។

## កថាខណ្ឌទី១៖ ការត្រួតពិនិត្យប្រភេទឯកសារដែលពាក់ព័ន្ធនឹងអចលនវត្ថុ

នៅក្នុងចំណុចនេះ នឹងសិក្សាទៅលើឯកសារដែលពាក់ព័ន្ធទៅអចលនវត្ថុមានប័ណ្ណកម្មសិទ្ធិ (១.១) និងអចលនវត្ថុគ្មានប័ណ្ណកម្មសិទ្ធិ (១.២) ។

### ១.១. អចលនវត្ថុមានប័ណ្ណកម្មសិទ្ធិ

ប័ណ្ណកម្មសិទ្ធិ ឬ ហៅថាប្លង់រឹង គឺជាប័ណ្ណដែលបញ្ជាក់សិទ្ធិជាស្ថាពរ ឬ ពេញលេញជាម្ចាស់លើទ្រព្យមិនអាចជំទាស់តវ៉ាបាន ហើយប័ណ្ណកម្មសិទ្ធិនេះចេញជូននៅពេលមានការចុះបញ្ជីដីធ្លីលក្ខណៈជាប្រព័ន្ធ ឬ ចុះបញ្ជីដីធ្លីលក្ខណៈដាច់ដោយដុំ។ ប័ណ្ណកម្មសិទ្ធិ គឺមានប័ណ្ណពីរទៀតនៅក្នុងនឹង គឺមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ឬ ប្លង់រឹង (សម្រាប់ដីធ្លី) និងវិញ្ញាបនបត្រសម្គាល់ចំណែកឯកជន (សម្រាប់អគារសហកម្មសិទ្ធិ) ។

- ដីធ្លី

នៅក្នុងករណីលក់ទិញដីធ្លី អ្នកទិញគួរត្រួតពិនិត្យមើលថា តើអ្នកលក់មានប័ណ្ណកាន់កាប់ប្រភេទណា? ហើយថាតើវាជាវិញ្ញាបនបត្រសម្គាល់អចលនវត្ថុ ឬ ហៅថាប្លង់រឹង និងមានលក្ខណៈត្រឹមត្រូវ និងមានការចេញដោយរដ្ឋបាលសុរិយោដី ឬអត់?

វិញ្ញាបនបត្រសម្គាល់អចលនវត្ថុ ឬ ហៅថាប្លង់រឹង គឺជាប្រភេទប័ណ្ណមួយ ដែលមានការការពារពីច្បាប់យ៉ាងពេញលេញ ដែលវាបានសម្គាល់ម្ចាស់កម្មសិទ្ធិលើអចលនវត្ថុយ៉ាងជាក់ស្តែង ដោយមានចាឈ្មោះម្ចាស់កម្មសិទ្ធិករនៅលើប័ណ្ណនោះតែម្តង ហើយវិញ្ញាបនបត្រនោះមានចារឹកនៅក្នុងសៀវភៅគោលបញ្ជីដី។ វិញ្ញាបនបត្រនេះត្រូវបានរាជរដ្ឋាភិបាលបង្កើតឡើងនៅក្នុងឆ្នាំ២០០០ និងបន្តឲ្យប្រើប្រាស់រហូតដល់បច្ចុប្បន្ននេះ។

- អគារសហកម្មសិទ្ធិ

ចំពោះការទិញលក់អគារសហកម្មសិទ្ធិក៏ដូចជាការលក់ទិញដីធ្លីដែរ អ្នកទិញក៏ត្រូវត្រួតពិនិត្យមើលថា តើអ្នកលក់មានប័ណ្ណ កាន់កាប់ប្រភេទណា? ហើយថាតើវាជាវិញ្ញាបនបត្រសម្គាល់ចំណែកឯកជននឹងមានលក្ខណៈត្រឹមត្រូវដែរ ឬទេ និងមានទទួលស្គាល់ដោយអាជ្ញាធរសុរិយោដីឬទេ? ឬ មាន

ការចេញដោយរដ្ឋបាលសុរិយោដី ឬអត់?

អគារសហកម្មសិទ្ធិ គឺសំដៅទៅលើអគារ ឬសំណង់ដែលមានកម្មសិទ្ធិករច្រើនរស់នៅ ហើយមានចំណែកខ្លះជាកម្មសិទ្ធិផ្តាច់មុខរបស់ [សហកម្មសិទ្ធិករ] ហៅថា "ចំណែកឯកជន" និងមានចំណែកខ្លះជាលំហរួម សម្រាប់ការប្រើប្រាស់រួមរបស់សហកម្មសិទ្ធិករទាំងអស់ហៅថា "ចំណែករួម"[៣៨] ។ ហើយប្រភេទនៃអគារសហកម្មសិទ្ធិមានជាអាទិ៍ ភូមិគ្រឹះ ពាក់កណ្តាលភូមិគ្រឹះ ផ្ទះល្វែងដែលមានច្រើនល្វែង និងច្រើនជាន់ជាប់ៗគ្នា ខុនដូ និងប្រភេទផ្ទះផ្សេងទៀត ដែលមានរចនាសម្ព័ន្ធជាប់គ្នា[៣៩] ។

វិញ្ញាបនបត្រសម្គាល់ចំណែកឯកជនវិញ គឺជាប័ណ្ណមួយប្រភេទដែលមានការការពារពីច្បាប់យ៉ាងពេញលេញ ដែលបានសម្គាល់ម្ចាស់កម្មសិទ្ធិផ្តាច់មុខទៅលើចំណែកឯកជននៃអគារសហកម្មសិទ្ធិ។

ចំណែកឯកជន គឺរាល់ចំណែកនៃអគារ ឬ ដីសម្រាប់ការប្រើប្រាស់ផ្តាច់មុខនៃសហកម្មសិទ្ធិករណាមួយ ហើយវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុត្រូវបានកំណត់អំពីប្រភេទ និង ទំហំនៃចំណែកនោះ[៤០] ។ ដូច្នេះ (សហកម្មសិទ្ធិករទាំងឡាយមានសិទ្ធិពេញលេញលើចំណែកឯកជនរបស់ខ្លួនដោយមិនបំពានទៅលើចំណែករួម និងមិនរំខាន ឬ រាំងស្ទះដល់ការប្រើប្រាស់ចំណែករួមដោយសហកម្មសិទ្ធិករដទៃទៀត។ ហើយសហកម្មសិទ្ធិករទាំងនោះអាចផ្ទេរសិទ្ធិដោយសេរី ជួល ឬ បង្កើតផលុបភោគ រៀបចំសិទ្ធិប្រើប្រាស់ និង អាស្រ័យនៅ ដាក់ហ៊ីប៉ូតែក ដាក់បញ្ចាំនូវចំណែកឯកជនរបស់ខ្លួន។ ប៉ុន្តែសហកម្មសិទ្ធិករមិនអាចបង្កើតសេវភាពលើចំណែកឯកជនរបស់ខ្លួននោះបានទេ)[៤១] ។

ចំណែករួម គឺជាកម្មសិទ្ធិអវិភាគរបស់សហកម្មសិទ្ធិករ។ សហកម្មសិទ្ធិករត្រូវធានាការថែទាំចំណែករួម។ ហើយបន្ទុកនៃការថែទាំនេះត្រូវចែកគ្នាតាមសមាមាត្រទៅនឹងតម្លៃនៃឡូត៍នីមួយៗ[៤២] ឬលើកលែងតែមានការព្រមព្រៀងគ្នាផ្សេងពីនេះ ឬ មានចែងដោយឡែកក្នុងបទបញ្ជាផ្ទៃក្នុង[៤៣] ។ ហើយមួយវិញទៀតនោះចំណែករួម និងសិទ្ធិបន្ទាប់បន្សំទាំងឡាយមិនអាចជាកម្មវត្ថុនៃការបែងចែក ឬ

[៣៨]មាត្រា៤ វាក្យខណ្ឌ៣, ច្បាប់ស្តីពីការផ្តល់សិទ្ធិកម្មសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិដល់ជនបរទេស, លេខ នស/រកម/០៥១០/០០៦, ២៤ ឧសភា ២០១០។

[៣៩]មាត្រា៤ វាក្យខណ្ឌ១, អនុក្រឹត្យស្តីពីការគ្រប់គ្រងនិងប្រើប្រាស់អគារសហកម្មសិទ្ធិ, លេខ១២៦អនក្រ.បក, ១២ សីហា ២០០៩។

[៤០]មាត្រា១៧៨, ច្បាប់ភូមិបាល, លេខនស/រកម/០៨០១/១៤, សីហា ២០០១។

[៤១]មាត្រា១៧៧, ច្បាប់ភូមិបាល, លេខនស/រកម/០៨០១/១៤, សីហា ២០០១។

[៤២]មាត្រា១៨១, ច្បាប់ភូមិបាល, លេខនស/រកម/០៨០១/១៤, សីហា ២០០១។

[៤៣]មាត្រា១៤ , អនុក្រឹត្យស្តីពីការគ្រប់គ្រងនិងប្រើប្រាស់អគារសហកម្មសិទ្ធិ, លេខ១២៦អនក្រ.បក, ១២ សីហា ២០០៩។

បង្ខំឲ្យលក់ដាច់ដោយឡែកពីចំណែកឯកជនបានឡើយ[៩៤] ។

ចំពោះចំណែករួម ឬ ទ្រព្យរួម និងសិទ្ធិបន្ទាប់បន្សំដែលចាត់ទុកជាកម្មសិទ្ធិរួមមានដូចជា[៩៥]៖

– ចំណែករួម ឬ ទ្រព្យរួមមានជាអាទិ៍ : ដី ទីធ្លា ឧទ្យាន និង សួនច្បារ ផ្លូវ ច្រកចេញចូល, ជញ្ជាំង សសរទ្រទ្រង់សំខាន់ៗនៃអគារ ឧទាហរណ៍រួម រាប់បញ្ចូលចំណែកនៃបណ្តាញទឹក ភ្លើង បណ្តាញឧស្ម័នដែលអាចឆ្លងកាត់ចំណែកឯកជន, ទូរួម បំពង់ និងក្បាលបំពង់ផ្សេង, ទីកន្លែងនៃសេវារួម។

– សិទ្ធិបន្ទាប់បន្សំដែលត្រូវទុកជាកម្មសិទ្ធិរួមដែរ : សិទ្ធិជីករុករកវត្ថុធាតុដែលមានក្នុងដី, សិទ្ធិស្ថាបនាអគារថ្មីក្នុងទីធ្លា ឧទ្យាន ឬសួនច្បារដែលជាចំណែករួម, សិទ្ធិជីករុករកក្នុងទីធ្លា ឧទ្យាន ឬ សួនច្បារទាំងនោះ, សិទ្ធិនៃអឌ្ឍសិទ្ធិភាពដែលជាប់ទៅនឹងចំណែករួមទាំងឡាយ, សិទ្ធិលើកបន្តឲ្យខ្ពស់នូវអគារសម្រាប់ប្រើប្រាស់រួម ឬដែលមានកន្លែងច្រើនបង្កើតបានជាចំណែកឯកជនផ្សេងគ្នា។ គ្មានករណីណាមួយដែល កម្មសិទ្ធិករនៃអគារសហកម្មសិទ្ធិជាន់លើបំផុតអាចលើកបន្តសម្រាប់តែខ្លួនឯងផ្ទាល់ ឬលក់សិទ្ធិនៃការលើកបន្តនេះឡើយ។

ជារួមមកនៅពេលដែលមានការលក់ទិញអចលនវត្ថុដែលមានប័ណ្ណកម្មសិទ្ធិ អ្នកទិញអាចមានការទុកចិត្តច្រើនជាង ដោយហេតុថាអ្នកលក់ គឺជាកម្មសិទ្ធិករពេញសិទ្ធិលើអចលនវត្ថុរបស់គាត់។ និងដោយហេតុថាប័ណ្ណកម្មសិទ្ធិ ឬ ប្លង់រឹងនេះ អ្នកទិញអាចមើលឃើញពីទំហំ និងទីតាំងរបស់ដី និងឈ្មោះរបស់កម្មសិទ្ធិករ។ ម្យ៉ាងវិញទៀត វាមានការងាយស្រួលក្នុងការផ្ទៀងផ្ទាត់នៅក្នុងសៀវភៅគោលបញ្ជីក្បាលដីផងដែរ។

### ១.២. អចលនវត្ថុគ្មានប័ណ្ណកម្មសិទ្ធិ

នៅក្នុងចំណុចនេះ គឺយើងនឹងធ្វើការត្រួតពិនិត្យ និងសិក្សាអំពីអចលនវត្ថុដែលគ្មានប័ណ្ណកម្មសិទ្ធិ។ ពាក្យថាប័ណ្ណកម្មសិទ្ធិមិនមែនថាអចលនវត្ថុនោះគ្មានប័ណ្ណអ្វីសោះនោះទេ គឺអចលនវត្ថុនោះមានប័ណ្ណដែរ ប៉ុន្តែមិនមែនជាប័ណ្ណកម្មសិទ្ធិពេញលេញនោះទេ។ ប័ណ្ណនោះគ្រាន់តែជាប័ណ្ណបណ្តោះអាសន្នដើម្បីសម្គាល់ សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី ឬ សិទ្ធិកាន់កាប់អចលនវត្ថុតែប៉ុណ្ណោះ ដែលវាផ្ទុយនឹងប័ណ្ណកម្មសិទ្ធិដែលជាសិទ្ធិពេញបរិបូណ៌របស់ជនម្នាក់ៗលើអចលនវត្ថុ។

---

[៩៤]មាត្រា១៨៣, ច្បាប់ភូមិបាល, លេខនស/រកម/០៨០១/១៤, សីហា ២០០១។

[៩៥]មាត្រា១៧៩, ច្បាប់ភូមិបាល, លេខនស/រកម/០៨០១/១៤, សីហា ២០០១។

អចលនវត្ថុគ្មានប័ណ្ណកម្មសិទ្ធិ ឬ ប្លង់ទន់ គឺសំដៅទៅលើប័ណ្ណកាន់កាប់អចលនវត្ថុពីរប្រភេទ ឬ ប្រភេទនៃក្បាលដីពីរ ដែលរួមមាន : ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី និង ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ។

– ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី គឺជាប័ណ្ណសម្គាល់ក្បាលដីមួយប្រភេទ ដែលបានដាក់ចេញដោយរដ្ឋាភិបាលក្នុងសម័យរដ្ឋកម្ពុជា ហើយបានបន្តប្រើប្រាស់ដល់សម័យព្រះរាជាណាចក្រកម្ពុជាទី២ ពោលគឺបានបង្កើតនៅក្នុងចន្លោះឆ្នាំ១៩៨៩ ដល់ ឆ្នាំ១៩៩៥ និងមានតម្លៃប្រើប្រាស់រហូតដល់បច្ចុបន្បន្ន។ ប្រភេទប័ណ្ណនេះត្រូវបានចារឹកនៅក្នុងសៀវភៅចុះបញ្ជីអចលនវត្ថុ ហើយទំហំនៃប័ណ្ណនេះវិញ គឺមានទំហំតូចប៉ុនបាតដៃប៉ុណ្ណោះ។

ប័ណ្ណនេះត្រូវបានសម្គាល់នូវប្រភេទដី ៣ ប្រភេទផ្សេងៗគ្នារួមមាន : ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីចំពោះដីស្រែ ចម្ការ, ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីចំពោះដីសាងសង់លំនៅឋាន និងប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីចំពោះដីគាស់ ដីរានថ្មី។

ដូចនេះប្រសិនបើប័ណ្ណនេះបានចារឹកថា ជាប្រភេទក្បាលដីណាមួយហើយនោះ យើងមិនអាចយកក្បាលដីនោះ បង្វែរមុខងារទៅធ្វើអ្វីមួយផ្សេងទៀតបានឡើយ គឺមានន័យថា បើជាក្បាលដីសម្រាប់សាងសងលំនៅឋានប៉ុណ្ណោះ គឺមិនអាចយកទៅធ្វើស្រែចម្ការបានឡើយ។ បើចង់ធ្វើការផ្លាស់ប្តូរមុខងារនៃដី ត្រូវធ្វើការស្នើសុំទៅអាជ្ញាធរទទួលបន្ទុក ដើម្បីធ្វើការកែប្រែប័ណ្ណសម្គាល់ក្បាលដីនោះ។

– រីឯប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ[៨៦] ឬ ប័ណ្ណថ្មី ឬប័ណ្ណភោគៈវិញ គឺជាលិខិតដែលមានរូបមន្តយថាភូត ចេញដោយអាជ្ញាធរមានសមត្ថកិច្ចសម្រាប់បញ្ជាក់អំពីសិទ្ធិកាន់កាប់លើអចលនវត្ថុរបស់បុគ្គល ឬ ក្រុមណាមួយ ឬ មានន័យថាជាលិខិតសម្រាប់បញ្ជាក់ពីសិទ្ធិដែលជនម្នាក់ៗមានលើអចលនវត្ថុណាមួយជាបណ្តោះអាសន្ន មិនទាន់ស៊ប់ជារបស់ខ្លួនមែនទែនទេ។ ហើយប័ណ្ណនេះផងដែរត្រូវបានដាក់ឲ្យប្រើប្រាស់ក្នុងឆ្នាំ១៩៩៥ និងបន្តឲ្យប្រើប្រាស់មកដល់ពេលបច្ចុប្បន្ននេះ។ ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ ឬ ប័ណ្ណថ្មី និងប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី ឬប័ណ្ណចាស់ គឺប័ណ្ណទាំងពីរនេះមានវិសាលភាពនៃសិទ្ធិ ឬតម្លៃដូចគ្នានោះទេក្នុងការប្រើប្រាស់។

នៅក្នុងសារាចរណែនាំអនុវត្តនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លីលេខ០០១ដន/សជ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០០២ ត្រង់ដំណាក់កាលចេញប័ណ្ណបានបង្ហាញថា

[៨៦] បែបបទបំពេញប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ"ប័ណ្ណថ្មី"ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ១៩៩៥របស់នាយកដ្ឋានសុរិយោដី

ចេញប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ ឬ ប័ណ្ណភោគៈ តែចំពោះក្បាលដី ឬ អចលនវត្ថុណាដែលកាន់កាប់ដោយសន្តិវិធី និងមិនមានការជំទាស់ ហើយមានរយៈពេលតិចជាងប្រាំឆ្នាំ មុនច្បាប់ភូមិបាលចូលជាធរមាន។ រីឯមាត្រា២៩ កថាខណ្ឌទី២នៃច្បាប់ភូមិបាល, លេខនស/រកម/០៨០១/១៨, សីហា ២០០១ វិញបានចែងថា "ការចូលកាន់កាប់ភោគៈត្រូវបញ្ចប់នៅពេលដែលច្បាប់នេះចូលជាធរមាន" ។

សរុបមកចំពោះការលក់ទិញអចលនវត្ថុគ្មានប័ណ្ណកម្មសិទ្ធិ ទាំងដីធ្លីក្តី ទាំងអគារសហកម្មសិទ្ធិក្តី ប្រសិនបើអ្នកលក់មានត្រឹមតែប្លង់ទន់ ឬ គ្រាន់តែជាភោគី (អ្នកកាន់កាប់ស្របច្បាប់តែប៉ុណ្ណោះ) អ្នកទិញគួរមានការប្រុងប្រយ័ត្នខ្ពស់ក្នុងការទិញអចលនវត្ថុប្រភេទនោះ ពីព្រោះតែប្លង់ទន់ គឺមានការទទួលស្គាល់ត្រឹមតែអាជ្ញាធរមូលដ្ឋានតែប៉ុណ្ណោះ មិនមែនធ្វើឡើង ឬ ទទួលស្គាល់ដោយរដ្ឋបាលសុរិយោដីនោះទេ ។ ហើយចំណុចដែលអ្នកទិញត្រូវពិនិត្យមើល គឺអំពីប្រវត្តិរបស់អចលនវត្ថុនោះ ថាតើអចលន-វត្ថុនោះបានផ្ទេរជាដំណ តៗគ្នាប៉ុន្មានដំណាក់មកហើយ ក្នុងដំណាក់នីមួយៗ តើអ្នកលក់បានធ្វើការផ្ទេរដោយគោរពទៅតាមនីតិវិធីកំណត់ដោយច្បាប់ដែរ ឬទេ។ ការពិនិត្យផ្ទៀងផ្ទាត់បែបនេះ ដើម្បីឲ្យប្រាកដថាប្លង់ទន់ដែលអ្នកលក់កំពុងមានក្នុងដៃនេះ បានធ្វើឡើងដោយស្របច្បាប់ដោយអាជ្ញាធរមូល-ដ្ឋាន ហើយម្ចាស់ដីក៏កាន់កាប់ដោយស្របច្បាប់ ជៀសវាងដីមានម្ចាស់ពីរ ឬ បីជាន់លើគ្នាដែលវាធ្វើឲ្យកើតមានជម្លោះនៅថ្ងៃក្រោយ។

### ១.៣. ការត្រួតពិនិត្យបន្ទុកនៅលើអចលនវត្ថុ

ចំពោះបន្ទុកនៃអចលនវត្ថុក៏វាជារឿងដ៏សំខាន់មួយដែរ ដែលអ្នកទិញត្រូវមានការប្រុងប្រយ័ត្ន អ្នកទិញត្រូវពិនិត្យមើលអំពីបន្ទុកដែលម្ចាស់អចលនវត្ថុជាប់មាន។ អ្នកទិញក៏គួរពិនិត្យមើល ថាតើអច-លនវត្ថុនោះត្រូវបានយកទៅដាក់បញ្ចាំ ហ៊ីប៉ូតែក ការធានាលើបំណុល ឬ ការជួល ឬ ប្រវាស់ដែរឬទេ? និងម្យ៉ាងវិញទៀតអ្នកទិញត្រូវពិនិត្យឲ្យដឹង ថាតើដីនោះមានជាប់ពាក់ព័ន្ធនឹងសេចក្តីសម្រេចរបស់តុ-លាការ ឬ ដីការសម្រេចរក្សាការពារ និងដីដែលមានជាប់ពាក់ព័ន្ធនឹងសេចក្តីសម្រេចតុលាការដែលហាមមិនឲ្យលក់ ឬ ក៏ជាកម្មវត្ថុតុលាការឹបអូសជាដើមដែរ ឬទេ។ ហើយប្រសិនបើមាន អ្នកលក់ត្រូវតែដោះបន្ទុកនេះឲ្យជ្រះស្រឡះជាមុនសិន មុននឹងចុះកិច្ចសន្យាលក់ទិញ។

## កថាខណ្ឌទី២៖ ការត្រួតពិនិត្យស្ថានភាពជុំវិញអចលនវត្ថុ

ក្រោយពីយើងបានធ្វើការត្រួតពិនិត្យអំពីប្រភេទឯកសារកាន់កាប់អចលនវត្ថុ បានច្បាស់លាស់ហើយ និងបន្ទុកលើអចនវត្ថុបានរួចរាល់ចប់សព្វគ្រប់ហើយ។ ហើយទោះបីជាអចលនវត្ថុមានប័ណ្ណកម្មសិទ្ធិក្តី និងអចនវត្ថុគ្មានប័ណ្ណកម្មសិទ្ធិក្តី អ្នកទិញគួរតែធ្វើការត្រួតពិនិត្យទៅលើចំណុចមួយចំនួនផ្សេងៗទៀត ពីព្រោះបញ្ហាចោទមិនមែនកើតមានឡើងត្រឹមតែកម្មសិទ្ធិនៅលើអចនវត្ថុនោះទេ គឺបញ្ហាអាចកើតមានឡើងចំពោះស្ថានភាពជុំវិញនៃអចលនវត្ថុនោះ។ ដូចនេះអ្នកទិញគួរតែធ្វើការត្រួតពិនិត្យអំពីទំហំ និងព្រំដី (២.១) ព្រមទាំងធ្វើការត្រួតពិនិត្យអំពីទំហំ និងព្រំអគារសហកម្មសិទ្ធិផងដែរ (២.២) និងចុងក្រោយអ្នកទិញត្រូវធ្វើការត្រួតពិនិត្យអំពីដីចំណីផ្លូវ (២.៣)។

### ២.១. ការត្រួតពិនិត្យទំហំ និងព្រំដី

អ្នកទិញគួរតែចុះទៅទីកន្លែងដែលអចលនវត្ថុនោះតាំងនៅជាក់ស្តែង ដើម្បីធ្វើការត្រួតពិនិត្យអំពីទំហំ និងព្រំដីឲ្យបានច្បាស់លាស់ ថាតើទំហំ និងព្រំដីនោះពិតជាត្រឹមត្រូវដូចដែលព័ត៌មានរបស់អ្នកលក់បានប្រាប់ដែរ ឬទេ ហើយមួយវិញទៀតនោះបើចាំបាច់ យើងត្រូវធ្វើការវាស់វែងជាក់ស្តែងជាមួយអ្នកលក់អំពីទំហំ និងព្រំដី ដើម្បីផ្ទៀងផ្ទាត់ទៅនឹងឯកសារដែលពាក់ព័ន្ធនឹងអចលនវត្ថុនោះ ថាតើវាពិតជាត្រឹមត្រូវ ដូចទៅនឹងព័ត៌មាននៅក្នុងឯកសារទាំងនោះដែរ ឬអត់ បើតាមក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ ត្រង់មាត្រា ៥៤៦ បានចែងអំពីបញ្ញត្តិពិសេសនៃការទទួលខុសត្រូវក្នុងការធានាវិការៈ នៅក្នុងករណីដែលដីមានទំហំខ្វះ ឬ ក៏លើស។ ចំពោះដីដែលបានកំណត់ជាក់លាក់ណាមួយ ក្នុងករណីដែលការលក់ទិញត្រូវបានធ្វើឡើងដោយបញ្ជាក់ទំហំ និងកំណត់នូវតម្លៃតាមខ្នាតដីច្បាស់លាស់ តែការពិតទំហំដី ដែលមាននោះមិនគ្រប់នឹងទំហំដែលបានបញ្ជាក់ អ្នកទិញអាចទាមទារឲ្យអ្នកលក់ផ្តល់តាវកាលិកនូវផ្នែកដែលខ្វះ ឬ បន្ថយនូវតម្លៃដីនោះទៅតាមទំហំដីដែលខ្វះ ឬ រំលាយកិច្ចសន្យា និង ទាមទារសំណងនៃការខូចខាតបានតាមក្រមរដ្ឋប្បវេណី ក្នុងករណីដែល គ្មានការព្រមព្រៀងផ្សេងរវាងភាគី[៤៧]។ ផ្ទុយទៅវិញ ប្រសិនបើទំហំដីពិតប្រាកដ លើសពីទំហំដែលបានបញ្ជាក់ នោះអ្នកលក់ដែលមិនបានដឹងអំពីការលើសទំហំនោះ ហើយពុំមានកំហុសក្នុងការមិនបានដឹងនោះអាចទាមទារឲ្យអ្នកទិញបន្ថែម

[៤៧] មាត្រា៥៤៦ កថាខណ្ឌទី១, ក្រមរដ្ឋប្បវេណី, លេខនស/រកម/១២០៧/០៣០ចុះថ្ងៃទី៨, ធ្នូ, ២០០៧។

តម្លៃដីដែលលើសនោះបាន លើកលែងតែមានការព្រមព្រៀងផ្សេងរវាងភាគី[៤៨] ។

ហើយចំពោះដីដែលបានកំណត់ជាក់លាក់ណាមួយ ក្នុងករណីដែលការលក់ទិញត្រូវបានធ្វើឡើងដោយបញ្ជាក់ទំហំ និង កំណត់តែតម្លៃដីទាំងមូល[៤៩] ទោះបីជាទំហំដីនោះមិនគ្រប់នឹងទំហំដែលបានបញ្ជាក់ក៏ដោយ ក៏អ្នកទិញមិនអាចទាមទារឲ្យអ្នកលក់ផ្តល់តាវកាលិកនូវផ្នែកដែលខ្វះ ឬ បន្ថយនូវតម្លៃដីនោះទៅតាមទំហំដីដែលខ្វះ ឬ រំលាយកិច្ចសន្យា ឬ ទាមទារសំណងនៃការខូចខាតបានឡើយ ។ ប៉ុន្តែ មិនត្រូវយកអនុវត្តឡើយចំពោះករណីដែលអ្នកលក់បានដឹងអំពីការខ្វះទំហំដីនោះ ឬ ករណីដែលអ្នកលក់បានធានានូវទំហំដីនោះ ឬ ករណីដែលទំហំខ្វះនោះច្រើនជាង ១ ភាគ ២០[៥០] ។ ផ្ទុយទៅវិញចំ-ពោះដីដែលបានកំណត់ជាក់លាក់ណាមួយ ក្នុងករណីដែលការលក់ទិញ ត្រូវបានធ្វើឡើងដោយបញ្ជាក់ទំហំ និង កំណត់តែតម្លៃដីទាំងមូល ទោះបីជាតាមការពិតទំហំដីដែលមាននោះលើសពីទំហំដែលបានបញ្ជាក់ក៏ដោយ ក៏អ្នកលក់មិនអាចទាមទារឲ្យអ្នកទិញបន្ថែមតម្លៃដីបានឡើយ។ ប៉ុន្តែករណីនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលទំហំលើសនោះច្រើនជាង ១ ភាគ ២០ ហើយអ្នកលក់មិនបានដឹងអំពីការលើសទំហំ និង ពុំមានកំហុសក្នុងការមិនបានដឹងនោះ[៥១] ។ ហើយក្នុងករណី ដែលអ្នកលក់ទាមទារបន្ថែមតម្លៃ អ្នកទិញអាចរំលាយកិច្ចសន្យាបាន[៥២] ។

ចំពោះព្រំដីវិញ មិនថាតែអចលនវត្ថុមានប័ណ្ណកម្មសិទ្ធិ ឬ អចលនវត្ថុគ្មានប័ណ្ណកម្មនោះទេ អ្នកទិញត្រូវត្រួតពិនិត្យមើល ថាតើដីនៅជុំវិញអចលនវត្ថុនោះ មានទំនាក់ទំនងយ៉ាងដូចម្តេចជាមួយនឹងដីជាប់ព្រំ? តើរបង ឬ ព្រំអចលនវត្ថុបានកំណត់យ៉ាងច្បាស់លាស់ដែរ ឬទេ? ប្រសិនបើមិនទាន់កំណត់បានច្បាស់លាស់ទេ អ្នកទិញគួរស្នើឲ្យអ្នកលក់ធ្វើការវាស់វែងកំណត់ព្រំដីឲ្យបានច្បាស់លាស់មុននឹងចុះកិច្ចសន្យាលក់ទិញ ហើយការវាស់វែងកំណត់ព្រំដីនោះ ត្រូវធ្វើឡើងដោយមានវត្តមានអាជ្ញា-ធរដែនដីដឹងលឺ[៥៣] ។

[៤៨]មាត្រា៥៤៦ កថាខណ្ឌទី២, ក្រមរដ្ឋប្បវេណី, លេខនស/រកម/១២០៧/០៣០ចុះថ្ងៃទី៨, ធ្នូ,២០០៧។

[៤៩]ការកំណត់តម្លៃដីទាំងមូលដូច្នេះវា គឺមានការលំបាកក្នុងការគណនាគំលាតតម្លៃរវាងទំហំដីពិតប្រាកដ និង ទំហំដែលបានបញ្ជាក់។

[៥០] មាត្រា៥៤៦ កថាខណ្ឌទី៣, ក្រមរដ្ឋប្បវេណី, លេខនស/រកម/១២០៧/០៣០ ចុះថ្ងៃទី៨, ធ្នូ, ២០០៧។

[៥១]មាត្រា៥៤៦ កថាខណ្ឌទី៤, ក្រមរដ្ឋប្បវេណី, លេខនស/រកម/១២០៧/០៣០ ចុះថ្ងៃទី៨, ធ្នូ, ២០០៧។

[៥២]មាត្រា៥៤៦ កថាខណ្ឌទី៥, ក្រមរដ្ឋប្បវេណី, លេខនស/រកម/១២០៧/០៣០ ចុះថ្ងៃទី៨, ធ្នូ,២០០៧។

[៥៣]ទំព័រទី៤ សៀវភៅរបស់លោកសាស្ត្រាចារ្យ បណ្ឌិត ហាប់ ផល្លី ស្តីពីការលក់ និងទិញនៅកម្ពុជា។

### ២.២. ការត្រួតពិនិត្យអគារសហកម្មសិទ្ធិ

នៅក្នុងករណីដែលអគារសហកម្មសិទ្ធិបានសាងសង់រួចរាល់ហើយ ការត្រួតពិនិត្យអគារសហកម្មសិទ្ធិក៏វាមិនមានលក្ខណៈខុសគ្នាអីទៅនឹងដីធ្លីប៉ុន្មានដែរ យើងត្រូវធ្វើការត្រួតពិនិត្យទៅលើទំហំនៃអគារ ថាតើត្រឹមត្រូវទៅតាមការផ្សព្វផ្សាយពាណិជ្ជកម្ម ឬ គំរូដែរ ឬទេ? ហើយណាមួយអ្នកទិញគួរត្រួតពិនិត្យនៅសំណង់នៃអគារសហកម្មសិទ្ធិផងដែរ ថាតើបានសាងសង់ត្រឹមត្រូវទៅតាមស្តង់ដាដែលយើងចង់បាន ឬ តាមច្បាប់កំណត់ហើយឬនៅ។

មួយវិញទៀតនោះចំពោះអគារសហកម្មសិទ្ធិដែលបានសាងសង់រួចរាល់ហើយក្តី និងមិនទាន់បានសាងសង់រួចនៅឡើយក្តី ឬមានត្រឹមតែគម្រោងអភិវឌ្ឍអចលនវត្ថុក្តីអ្នកទិញក៏ត្រូវធ្វើការត្រួតពិនិត្យនៅចំណុចមួយចំនួនផ្សេងទៀតផងដែរ ដើម្បីឲ្យមានការជឿទុកចិត្ត និងមិនមានការបោកប្រាស់ អ្នកទិញគួរស្នើសុំទៅអ្នកលក់ដើម្បីធ្វើការត្រួតពិនិត្យផងដែរនៅលើអាជ្ញាប័ណ្ណ ថាតើមានដែរ ឬទេ និងកាលបរិច្ឆេទសុពលភាពអាជ្ញាប័ណ្ណមានរយៈពេលប៉ុន្មាន ហើយថាតើបុគ្គលអភិវឌ្ឍអចលនវត្ថុ[៥៤]នោះមានភាពស្របច្បាប់ដែរ ឬទេ ហើយចុងក្រោយនោះ ថាតើបុគ្គលអភិវឌ្ឍអចលនវត្ថុនោះបានធ្វើការបង់ពន្ធជូនរដ្ឋរួចរាល់ហើយឬនៅ។ បើសិនជានៅ យើងគួរតែស្នើសុំឲ្យអ្នកលក់ធ្វើការគិតគូរពន្ធទាំងឡាយជូនរដ្ឋឲ្យហើយជាមុនសិន មុននឹងធ្វើការចុះកិច្ចសន្យា។

### ២.៣. ការត្រួតពិនិត្យដីចំណីផ្លូវ និងចំណីផ្លូវរថភ្លើង

ក្នុងចំណុចនេះ អ្នកទិញគួរតែធ្វើការត្រួតពិនិត្យចំពោះដីចំណីផ្លូវផងដែរ ពីព្រោះដីធ្លីមួយចំនួនតែងតែនៅជាប់នឹងផ្លូវសាធារណៈរបស់រដ្ឋ ដូចនេះអ្នកទិញដែលមានបំណងចង់ទិញដី ឬ អគារសហ-កម្មសិទ្ធិត្រូវតែមានការពិនិត្យមើលនូវចំណីផ្លូវនេះផងដែរ ប៉ុន្តែចំពោះអគារសហកម្មសិទ្ធិវិញវាមិនសូវជាមានបញ្ហា ចោទនោះទេ ដោយសារតែអគារសហកម្មសិទ្ធិ មុននឹងធ្វើការសាងសង់ គឺមានការសុំការអនុញ្ញាតសាងសង់បានត្រឹមត្រូវ ទើបគេធ្វើការអនុញ្ញាតឲ្យសាងសង់។ ដូចនេះយើងនឹងសិក្សាតែទៅលើការត្រួតពិនិត្យដីធ្លីតែប៉ុណ្ណោះ ថាតើដីនោះមានជាប់ចំណែកផ្លូវ ឬ ចំណីផ្លូវរថភ្លើងដែរ ឬទេ?

ក្នុងករណីដែលដីនោះមានជាប់នឹងចំណីផ្លូវ ឬ ចំណីផ្លូវរថភ្លើងនោះ អ្នកទិញគួរធ្វើការកាត់ចំ-

---

[៥៤] បុគ្គលអភិវឌ្ឍអចលនវត្ថុ សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលពាក់ព័ន្ធទៅនឹងការអភិវឌ្ឍអចលនវត្ថុ ឬសំដៅដល់ដែលដាក់ទុនវិនិយោគលើការសាងសង់អគារសហកម្មសិទ្ធិ ក្នុងគោលបំណងសម្រាប់លក់ ឬ ជួល។

ណែកនៃដីដែលប៉ះពាល់នោះឲ្យហើយ មុននឹងធ្វើការទិញអចលនវត្ថុនោះ។ ហើយចម្ងាយដីអ្នកទិញត្រូវកាត់ចំពោះដីចំណីផ្លូវ ឬ ចំណីរថភ្លើងនោះ អ្នកទិញអាចពិនិត្យមើលនៅក្នុងប្រកាសលេខ ០៦ ប្រ/ក របស់រាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី២៧ ខែ កញ្ញា ឆ្នាំ ១៩៩៩ដែលបានកំណត់ប្រវែងដូចខាងក្រោម[៥៥] ៖

– ផ្លូវជាតិមានលេខខ្ទង់ ដូចជាលេខ ២, ៣, ៦, ៧ ចម្ងាយ ២៥ ម៉ែត្រពីសងខាងអ័ក្សផ្លូវលើកលែងផ្លូវជាតិលេខ ១,៤,៥ ចម្ងាយ ៣០ ម៉ែត្រពីសងខាងអ័ក្សផ្លូវ

– ផ្លូវជាតិមានលេខពីរខ្ទង់ ដូចជាលេខ១១, ២២, ៦៤, ៧៨, ចម្ងាយ ២៥ម៉ែត្រពីសងខាងអ័ក្សផ្លូវ។

– ផ្លូវខេត្ត ចម្ងាយ ២០ ម៉ែត្រពីសងខាងអ័ក្សផ្លូវ

– ផ្លូវឃុំ ចម្ងាយ ១៥ ម៉ែត្រពីសងខាងអ័ក្សផ្លូវ

– ផ្លូវរថភ្លើង ចម្ងាយ ២០ ម៉ែត្រពីសងខាងអ័ក្សផ្លូវ ចំពោះទីក្រុងទីរួមខេត្ត និងទីប្រជុំជន

– ផ្លូវរថភ្លើង ចម្ងាយ ៣០ ម៉ែត្រពីសងខាងអ័ក្សផ្លូវ ចំពោះផ្លូវដែកដែលបិតនៅក្រុង

– និងផ្លូវរថភ្លើង ចម្ងាយ ១០០ ម៉ែត្រពីសងខាងអ័ក្សផ្លូវ ចំពោះផ្លូវដែកក្នុងតំបន់ព្រៃភ្នំដែលមានថ្មរមៀលធ្លាក់ ឬតំបន់ព្រៃខ្ពស់។

[៥៥]ប្រកាសស្តីពីការអនុវត្តគោការណ៍ដីចំណីផ្លូវជាតិ ផ្លូវខេត្ត ផ្លូវឃុំ ផ្លូវរថភ្លើងនៅទូទាំងព្រះរាជាណាចក្រកម្ពុជាលេខ៩៦១ សហវ, ០៦ មេសា ២០០០។

# ជំពូកទី២
# ដំណាក់កាលចុះកិច្ចសន្យាលក់ទិញអចលនវត្ថុ

បន្ទាប់ពីបានយល់ដឹងអំពីសិទ្ធិ និងករណីយកិច្ចរបស់ភាគី និងបានធ្វើការចរចា ព្រមទាំងបានធ្វើការត្រួតពិនិត្យអចលនវត្ថុរួចរាល់អស់ហើយនៅក្នុងដំណាក់កាលដំបូងមុនការចុះកិច្ចសន្យា ឥឡូវគឺ ដល់ពេលត្រូវនិយាយអំពីការចុះកិច្ចសន្យា។ នៅពេលនិយាយអំពីការចុះកិច្ចសន្យា ជាធម្មតា គឺត្រូវតែ មានការចាប់ផ្ដើមពីចំណុចដំបូងមក។ ជាក់ស្ដែងក្នុងការចុះកិច្ចសន្យាលក់ទិញអចលនវត្ថុ ក៏មានលក្ខណៈ ដូចគ្នាផងដែរ គឺមុននឹងមានការចុះកិច្ចសន្យាលក់ទិញនោះត្រូវមានដំណាក់កាលដំបូង គឺការង្កើតកិច្ចសន្យា (ផ្នែកទី១) និង បន្ទាប់មកត្រូវដល់ការអនុវត្តកិច្ចសន្យាលក់ទិញអចលនវត្ថុដែលមានសុពលភាព (ផ្នែកទី២) ។

## ផ្នែកទី ១ ៖ ការបង្កើតកិច្ចសន្យាលក់ទិញអចលនវត្ថុ

ជាការពិត ការបង្កើតកិច្ចសន្យាលក់ទិញអចលនវត្ថុមួយកើតមានឡើងវាបានឆ្លងកាត់នូវដំណាក់កាលជាច្រើនរបស់វា ដើម្បីអោយកិច្ចសន្យានោះមានសុពលភាពពេញលេញអាចយកទៅអនុវត្តបាន និងមានអនុភាពគតិយុត្តតាមផ្លូវច្បាប់។ ដើម្បីអោយកិច្ចសន្យាមួយមានសុពលភាពពេញលេញភាគីត្រូវគោរពលក្ខខណ្ឌពីរ ៖ ដែលលក្ខខណ្ឌទី១ គឺលក្ខខណ្ឌគ្រឹះ (កថាខណ្ឌទី១) និងលក្ខខណ្ឌទី២ គឺលក្ខខណ្ឌទម្រង់ (កថាខណ្ឌទី២) ។

### កថាខណ្ឌទី ១ ៖ លក្ខខណ្ឌគ្រឹះ

នៅក្នុងកិច្ចសន្យាលក់ទិញអចលនវត្ថុលក្ខខណ្ឌគ្រឹះ ជាលក្ខខណ្ឌដ៏សំខាន់ដើម្បីឲ្យកិច្ចសន្យមានសុពលភាពពេញលេញដែលនៅក្នុងនោះត្រូវគោរពនូវគោលការណ៍៣ (បី) ៖ ការព្រមព្រៀង (១.១) សមត្ថភាព (១.២) និងកម្មវត្ថុ (១.៣) ។

#### ១.១. ការព្រមព្រៀង

ការព្រមព្រៀងជាលក្ខខណ្ឌមួយយ៉ាងសំខាន់ក្នុងកាបង្កើតកិច្ចសន្យា មុននឹងកើតមាននូវកិច្ចសន្យានេះឡើងភាគីនៃកិច្ចសន្យាត្រូវបង្ហាញឆន្ទៈយល់ព្រមក្នុងការទទួលយក និងអនុវត្តតាមលក្ខខណ្ឌដែលមាននៅក្នុងកិច្ចសន្យានោះ។ ការព្រមព្រៀងអាចធ្វើឡើងដោយឯកតោភាគី គឺជាសកម្មភាពដែលបង្កើត កែប្រែ ឬ រំលត់នូវកាតព្វកិច្ច ដោយបង្ហាញឆន្ទៈនៃការចាត់ចែងទ្រព្យដោយភាគីម្ខាង ឬ ដោយ

អនុវត្តសិទ្ធិដែលបានទទួលតាមកិច្ចសន្យា ឬ តាមបញ្ញត្តិនៃច្បាប់ [៥៦]។ ប៉ុន្តែ ចំពោះកិច្ចសន្យាលក់ទិញ វិញការបង្កើតកិច្ចសន្យាការព្រមព្រៀងមាន អានុភាពទៅបានលុះត្រាតែមានការព្រមព្រៀងគ្នាទៅវិញទៅមករវាងគូភាគីទាំងសងខាងដែលត្រូវតែជាអ្នកស្នើឬឯម្ខាងទៀតត្រូវតែទទួលយកនូវសំណើរនោះ។ អ្នកស្នើរបង្ហាញឆន្ទៈរបស់ខ្លួនតាមរយៈសំណើឯអ្នកទទួលយកនូវ សំណើបង្ហាញឆន្ទៈរបស់ខ្លួនតាមរយៈស្វីការ ។

### ១.១.១. សំណើ

សំណើ គឺជាការបង្ហាញឆន្ទៈភ្ជាប់ខ្លួនជាមួយ និងចំណងគតិយុត្តដើម្បីសុំបង្កើតកិច្ចសន្យា[៥៧]។ ក្នុងករណីដែលគូភាគីម្ខាងទៀតផ្តល់ស្វីការចំពោះសំណើនេះ នោះកិច្ចសន្យាត្រូវបានកំណត់ថា បានបង្កើតឡើងដោយសំណើ និងស្វីការត្រូវគ្នា [៥៨]។

ឧទាហរណ៍ ៖ លោក (ក) ចង់លក់ដីចំការធូរ៉េនរបស់គាត់នៅឯខេត្តកំពតដើម្បីយកទៅទិញដីចំការដូងប្រេងនៅក្រុងព្រះសីហនុ ។ គាត់បានដាក់ផ្លាកដីលក់ហៅថាសំណើ ។ ក្នុងករណី បើមានអ្នកយល់ព្រមទទួលយកសំណើនោះ កិច្ចសន្យាលក់ដីនឹងត្រូវបានបង្កើតនូវអនុភាពចំពោះភាគីនៃកិច្ច-សន្យា ។ ដោយឡែកសំណើក្នុងន័យនេះខុសពីអ្វីដែលគេនិយាយថាហេតុដែលអញ្ជើញឲ្យធ្វើសំណើ ។

ប្រសិនបើអ្នកទិញផ្ញើរទូរសា ឬ និយាយថាខ្ញុំចង់ទិញដីប្រភេទនេះក្នុងចំណោមដីដែលក្រុមហ៊ុនបានបង្ហោះ។ ការសម្តែងឆន្ទៈ**ខ្ញុំចង់ទិញដីប្រភេទនេះ**ត្រូវបានចាត់ទុកជាសំណើ។ កិច្ចសន្យានឹងត្រូវបានបង្កើតឡើងកាលបើក្រុមហ៊ុន (ក) ឆ្លើយតបយល់ព្រមលក់ដីនោះដែលគេឆ្លើយតប យល់ព្រម នេះត្រូវចាត់ទុកថាជាស្វីការ ។ កាលដែលកំណត់ដូច្នោះមកពីអ្នកលក់មិនបានបង្ហោះអចលនវត្ថុគំរូក្រោមឆន្ទៈភ្ជាប់ខ្លួនជាមួយនឹងចំណងគតិយុត្ត ក្នុងករណីដែលមានស្វីការរបស់ភាគីម្ខាងទៀតចំពោះសំណើនេះទេ ។ ផ្ទុយមកវិញ បើការបង្ហោះអចលនត្ថុគំរូ ជាកិច្ចសន្យាលក់វិញ នោះកិច្ចសន្យាលក់ទិញនឹងត្រូវបានបង្កើតភ្លាម នៅពេលដែលអ្នកទិញបង្ហាញឆន្ទៈ **ខ្ញុំចង់ទិញដីនេះ** ជាស្វីការបានដល់អ្នកលក់ ។ ហើយបើយើងកំណត់យ៉ាងនេះមែនករណីអ្នកលក់គ្មាន ពុំទាន់មាន ឬ បានលក់អស់ដីប្រភេទនេះ នោះអ្នកលក់ និងក្លាយជាអ្នកមិនអនុវត្តកិច្ចសន្យា។ មូលហេតុបែបនេះហើយបានជាយើងកំណត់ថាការបង្ហោះអចលនវត្ថុគំរូតាមគេហទំព័រនេះ គឺជាហេតុដែលអញ្ជើញអោយធ្វើសំណើ ។

សរុបសេចក្តីមក សំណើ គឺជាការសុំបង្កើតកិច្ចសន្យាដែលធ្វើឡើងដោយការបង្ហាញឆន្ទៈឯក-

[៥៦] មាត្រា៣១២, ក្រមរដ្ឋប្បវេណី, លេខនស/រកម/១២០៧/០៣០ចុះថ្ងៃទី៨, ធ្នូ, ២០០៧។

[៥៧] មាត្រា៣៣៧ កថាខណ្ឌទី១, ក្រមរដ្ឋប្បវេណី, លេខនស/រកម/១២០៧/០៣០ ចុះថ្ងៃទី៨, ធ្នូ,២០០៧។

[៥៨] មាត្រា៣៣៦ កថាខណ្ឌទី១, ក្រមរដ្ឋប្បវេណី, លេខនស/រកម/១២០៧/០៣០ ចុះថ្ងៃទី៨, ធ្នូ,២០០៧។

តោភាគីនៃសំណើការី។ ហើយការសុំបង្កើតកិច្ចសន្យា និងកើតមានឡើងកាលបើសំណើត្រូវបានទទួលយកដោយភាគីម្ខាងទៀតនៃកិច្ចសន្យា។ ផ្ទុយទៅវិញ ភាគីម្ខាងទៀតមិនឆ្លើយតបទទួលយកសំណើទេនោះ ស្នើការក៏ពុំកើតមានហើយកិច្ចសន្យាក៏ពុំកើតឡើងដែរ ។

### ក. លក្ខខណ្ឌបង្កើតអានុភាពនៃសំណើ

សំណើអាចមានអានុភាពទៅបានកាលបើសំណើនោះបានទៅដល់ភាគីម្ខាងទៀត[៥៩]។ ដើម្បីអោយភាគីម្ខាងទៀតព្រមព្រៀងតាមការសុំបង្កើតកិច្ចសន្យាអ្នកស្នើត្រូវតែ សម្ដែងឆន្ទៈស្មោះត្រង់ពិតប្រាកដកុំក្លែងធ្វើពត់ ឬ បន្លំចំពោះភាគីទទួលសំណើ។ អ្នកស្នើសុំត្រូវប្រាប់ពីគោលបំណងនៃកាស្នើសុំនោះទៅអោយភាគីទទួលសំណើបានដឹងពីមូលហេតុ និងខ្លឹមសារច្បាស់លាស់ក្នុងសំណើរបស់ខ្លួនព្រមទាំងជូនដំណឹងជាក់លាក់អំពីពេលវេលាចាប់ផ្ដើម និងបញ្ចប់ទៅវិញនៃកិច្ចសន្យាលក់ទិញនោះ ។

#### ក.១. ឆន្ទៈក្នុងការស្នើ

អ្នកស្នើសុំ ឬសំណើការី គឺជាអ្នកដែលសំដែងឆន្ទៈមុនគេក្នុងការសុំបង្កើតកិច្ចសន្យាទៅកាន់ភាគីម្ខាងទៀតនៃកិច្ចសន្យា។ ការសំដែងឆន្ទៈនៃសំណើការី គឺជាការបង្ហាញឆន្ទៈភ្ជាប់ខ្លួន ជាមួយនិងចំណងគតិយុត្តដោយឯកតោភាគី គ្មានអានុភាពចាប់បង្ខំអោយបុគ្គលណាម្នាក់ដាច់ខាតត្រូវតែ ទទួលយកសំណើព្រមបង្កើតកិច្ចសន្យាជាមួយខ្លួននោះទេ ។

ឧទាហរណ៍ ៖ លោក (ក) មានបំណងចង់ពង្រីកដីកសិដ្ឋានរបស់ខ្លួនដែលនៅជាប់ និងដីរបស់លោក (ខ)។ ហេតុនេះលោក (ក) បានទៅទិញដីលោក (ខ) ដែលការសួរនេះហៅថា **ការធ្វើសំណើ** ។ ក្នុងករណីនេះ បើ លោក (ខ) បដិសេធមិនព្រមលក់ដីនោះទេ នោះលោក (ក) ក៏មិនអាចបង្ខំ លោ(ខ) អោយលក់ដីមកខ្លួនបានទេ ។

សរុបសេចក្ដីមក សំណើការីត្រូវបង្ហាញឆន្ទៈភ្ជាប់ខ្លួនជាមួយ និងចំណងគតិយុត្តថា ពិតជាចង់បង្កើតកិច្ចសន្យាតាមរយៈសំណើទៅកាន់ភាគីម្ខាងទៀតនៃកិច្ចសន្យាពិតប្រាកដមែន ។

#### ក.២. ខ្លឹមសារច្បាស់លាស់

បន្ទាប់ពីការបង្ហាញឆន្ទៈក្នុងការស្នើសំណើការី ត្រូវតែកំណត់ខ្លឹមសារនៃសំណើអោយបានច្បាស់លាស់ពីវត្ថុបំណង ថាតើអ្វីទៅជាកម្មវត្ថុនៃការស្នើ តើកម្មវត្ថុនោះស្របច្បាប់ដែរ ឬទេ ចាប់ផ្ដើម និងបញ្ចប់នៅពេលណា ឬ ទីកន្លែងចាប់ផ្ដើម និងបញ្ចប់ទៅវិញនៅទីណា? ផ្ទុយទៅវិញបើសំណើមានអត្ថន័យផ្ទុយនឹងបញ្ញត្តិដែលបានអនុវត្តដោយបង្ខំ ឬផ្ទុយនឹងសណ្ដាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ល្អ

[៥៩] មាត្រា៣៣៧ កថាខណ្ឌទី២, ក្រមរដ្ឋប្បវេណី,លេខនស/រកម/១២០៧/០៣០ ចុះថ្ងៃទី៨, ធ្នូ, ២០០៧។

នោះសំណើត្រូវចាត់ទុកជាមោឃៈ ទោះបីជាសំណើត្រូវទទួលដោយស្ទីការក៏ដោយ[៦០] ។ មានន័យថា ខ្លឹមសារនៃសំណើដែលអនុវត្តដោយបង្ខំ គឺជាបញ្ញត្តិដែលបដិសេធអានុភាពនៃសកម្មភាព ពីព្រោះសំណើបែបនេះ បានកម្រិតទំហំនៃសេរីភាពក្នុងកិច្ចសន្យាចំពោះចំណុចដែលបានចែងក្នុងបញ្ញត្តិច្បាប់ ។

ចំពោះខ្លឹមសារ ថាតើកិច្ចសន្យាមួយបង្កើតឡើង វាបានបញ្ញត្តិអត្ថន័យដោយបង្ខំឬយ៉ាងណា គឺអាស្រ័យលើការបកស្រាយច្បាប់ ឬ បញ្ញត្តិនោះប៉ុណ្ណោះ ។ សំណើការីក៏អាចបន្ថែមកាតព្វកិច្ចឯកតោភាគីនៃកិច្ចសន្យាអោយអនុវត្តកិច្ចសន្យាផ្សេងពីច្បាប់បានកំណត់ផងដែរដើម្បីការពារ ឬថែរក្សាផលប្រយោជន៍របស់ខ្លួនបានអោយតែខ្លឹមសារដែលចែងនោះមិនផ្ទុយនឹងច្បាប់ ឬ បញ្ញត្តិណាមួយដែលមានចែងក្នុងក្រមរដ្ឋប្បវេណី ឬ ច្បាប់ពិសេសទាក់ទងនឹងកម្មវត្ថុនៃកិច្ចសន្យា។

ហេតុនេះហើយមុន និងធ្វើកិច្ចសន្យាភាគីនៃកិច្ចសន្យាត្រូវសរសេរខ្លឹមសារអោយបានច្បាស់លាស់ និង ដាក់លក្ខខណ្ឌ អោយបានត្រឹមត្រូវតាមច្បាប់។ ទោះបីគ្មានបញ្ញត្តិអនុវត្តដោយបង្ខំក៏ដោយកិច្ចសន្យាត្រូវចាត់ទុក ជាមោឃៈដែរ ប្រសិនបើអត្ថន័យណាមួយក្នុងកិច្ចសន្យាសរសេរបំពាន និងសណ្តាប់ធ្នាប់សារធារណៈ និងទំនៀមទំលាប់ល្អរបស់សង្គម[៦១] ។

### ក.៣. ជូនដំណឹងទៅភាគីម្ខាងទៀត

ដើម្បីអោយសំណើ បង្កើតអានុភាពបានភាគីអ្នកស្នើត្រូវជូនដំណឹងទៅអោយភាគីម្ខាងទៀតបានដឹងពីសំណើនោះ ជាមុនសិន ពីព្រោះកាលបើភាគីម្ខាងទៀតពុំទទួលបាននូវដំណឹងអំពីសំណើ តែបែជាសំណើមានអានុភាព នោះនាំអោយភាគីម្ខាងទៀតដែលពុំទាន់ទទួលបានដំណឹងអំពីសំណើនោះ និងខាតបង់ប្រយោជន៍។ ផ្ទុយមកវិញដោយយោងតាមគោលការណ៍ទូទៅនៃក្រមរដ្ឋប្បវេណីបុគ្គលនីមួយៗត្រូវតែធានានូវស្វ័យភាពខាងឆន្ទៈពោល គឺពុំអាចមានបុគ្គលណាម្នាក់មកអះអាងចំពោះខ្លួននូវទំនាក់ទំនង និងសកម្មភាពណាមួយទាំងខ្លួនពុំបានដឹងនោះទេ ។

### ខ. ការបាត់បង់អានុភាពនៃសំណើ

យោងទៅតាមគោលការណ៍ទាក់ទង់ និងពេលវេលានៃការបង្ហាញឆន្ទៈ សំណើមានអានុភាព នៅពេលដែលសំណើនោះបានដល់ភាគីម្ខាងទៀត ។ ផ្ទុយទៅវិញអានុភាពនៃសំណើមិនត្រូវកើតឡើយ ប្រសិនបើការជូនដំណឹងអំពីការដកសំណើ ត្រូវបានបញ្ជូនដល់ភាគីម្ខាងទៀតមុនពេល ឬ នៅពេលដំណាលគ្នានៃការជូនដំណឹងអំពីសំណើនោះ។ ករណីនេះ ទោះបីជាអានុភាពនៃការដកសំណើត្រូវបានទទួលស្គាល់ក៏ដោយ ក៏ពុំអាចអោយភាគីម្ខាងទៀតខូចប្រយោជន៍ដែរពីព្រោះភាគីម្ខាងទៀត ពុំទាន់បាន

---

[៦០] មាត្រា៣៣៧ កថាខណ្ឌទី២, ក្រមរដ្ឋប្បវេណី, លេខនស/រកម/១២០៧/០៣០ ចុះថ្ងៃទី៨, ធ្នូ,២០០៧។

[៦១] មាត្រា៣៥៥ កថាខណ្ឌទី១, ក្រមរដ្ឋប្បវេណី, លេខនស/រកម/១២០៧/០៣០ ចុះថ្ងៃទី៨, ធ្នូ,២០០៧។

ធ្វើអ្វីនៅឡើយទេ ដោយហេតុថាសំណើ និងការដកសំណើបានទៅដល់ដំណាលគ្នា ។ ម៉្យាងវិញទៀត សំណើក៏មិនអាចមានអានុភាពបានដែរ ប្រសិនបើមានការជូនដំណឹងនៃការបដិសេធសំណើ ឬពុំមានការឆ្លើយតបអំពីការទទួលយកសំណើនោះទេ ។

**ខ.១. ការដកសំណើវិញ**

ការដកសំណើធ្វើឡើង ដោយភាគីអ្នកស្នើទៅកាន់ភាគីម្ខាងទៀតដោយមានគោលបំណងទប់-ស្កាត់អានុភាពមិនអោយសំណើអនុវត្តបាន។ ប៉ុន្តែការជូនដំណឹងនៃការដកសំណើនេះដាច់ខាតត្រូវធ្វើឡើងមុនពេលដែលសំណើទៅដល់ ឬ នៅពេលជាមួយគ្នា និងសំណើបានទៅដល់ភាគីម្ខាងទៀត[៦២]។ ដូចគ្នានេះដែរ ចំពោះការដកសំណើដោយគ្មានកំណត់អំឡុងពេលដែលស្ទីការ អាចមានអនុភាពទៅបានកាលបើការជូនដំណឹងនៃការដកសំណើនេះ បានទៅដល់មុនពេលដែលភាគីម្ខាងទៀតជូនដំណឹងអំពីស្ទីការ[៦៣]។ តែទោះបីជាយ៉ាងណាក៏ដោយប្រសិនបើសំណើត្រូវបានធ្វើឡើងដោយកំណត់អំឡុងពេ-លសម្រាប់ស្ទីការនោះការដកសំណើពុំអាចធ្វើទៅបានឡើយ[៦៤]។ ករណីនេះនៅពេលដែលអំឡុងពេ-លនៃស្ទីការបានផុតរលត់សំណើ និងត្រូវបាត់បង់អានុភាពដោយខ្លួនឯងដោយអ្នកស្នើពុំចាំបាច់ធ្វើការដកសំណើនោះទេ ។

ឧទាហរណ៍ទី១ ៖ លោក (ក) បានពឹងពាក់មេធាវីអោយទៅសួរទិញដីរបស់លោក (ខ) ។ មុនពេលលោក មេធាវី មិនទាន់បានទៅផង លោក (ក) ក៏ផ្លាស់ប្តូរចិត្តប្រាប់ទៅមេធាវី មិនទិញដីនោះវិញ។ ដូចនេះ ការដកសំណើធ្វើមុនពេលដែលសំណើទៅដល់ភាគីម្ខាងទៀតបែបនេះត្រូវចាត់ទុកថាការដកសំណើមានអានុភាព ។ ដូចគ្នានេះដែរ ការដកសំណើ និងទទួលបានអានុភាពប្រសិនបើ លោក (ក) បានជូនដំណឹងការដកសំណើទៅលោកមេធាវី ខណៈពេលដែលលោកមេធាវី កំពុងតែសាកសួរទិញដីពីលោក (ខ) ។

ឧទាហរណ៍ទី២ ៖ លោក (ក) បានទុករយៈពេល២សប្តាហ៍ឲ្យលោក (ខ) សម្រាប់គិតពិចារណាថាព្រមលក់ដីនោះឬទេ ។ ក្នុងអំឡុងពេល២សប្តាហ៍មិនទាន់បានបញ្ចប់ប្រសិនបើ លោក (ក) ចង់ផ្លាស់ប្តូរចិត្តដកសំណើមកវិញនោះពុំអាចធ្វើទៅបានទេ ។ លោក (ក) ត្រូវរងចាំរយៈពេលដែលគាត់បានកំ-ណត់ផុតរលត់សិន ទើបអានុភាពនៃការដកសំណើអាចធ្វើទៅបាន ។

---

[៦២]មាត្រា ៣៣៧ កថាខណ្ឌទី២, ក្រមរដ្ឋប្បវេណី,លេខនស/រកម/១២០៧/០៣០ ចុះថ្ងៃទី៨, ធ្នូ, ២០០៧។

[៦៣]មាត្រា៣៣៩ កថាខណ្ឌ ទី១, ក្រមរដ្ឋប្បវេណី,លេខនស/រកម/១២០៧/០៣០ ចុះថ្ងៃទី៨, ធ្នូ, ២០០៧។

[៦៤]មាត្រា ៣៣៨, ក្រមរដ្ឋប្បវេណី,លេខនស/រកម/១២០៧/០៣០ ចុះថ្ងៃទី៨, ធ្នូ, ២០០៧។

### ខ.២. ការបដិសេធសំណើ

ការបដិសេធសំណើ គឺជាការបង្ហាញឆន្ទៈច្រានចោលចំពោះសំណើរបស់អ្នកទទួលសំណើ។ ការបដិសេធចំពោះសំណើនេះ គឺលក្ខខណ្ឌជាក់លាក់មួយនៃការរំលត់នូវអានុភាពនៃសំណើ។ បើមើលទៅលើក្រមរដ្ឋប្បវេណីនៃការបដិសេធសំណើអាចមានពីរបែប គឺការផ្តល់ដំណឹងអំពីការបដិសេធចំ-ពោះសំណើដោយបង្ហាញឆន្ទៈលុបចោលសំណើ គឺជាការបដិសេធចំពោះសំណើដោយដាច់ខាតដោយពុំទទួលយកនូវចំណុចណាមួយនៃសំណើនោះទេ ដូចជាភាគី (ក) ស្នើសុំទិញដីភាគី (ខ) ក្នុងតម្លៃ២០០-០០០ដុល្លាតែភាគី (ខ) មិនព្រមលក់ដីនោះទេទោះក្នុងតម្លៃណាក៏ដោយ ។ រីឯការធ្វើសំណើតបវិញ គឺជាការបដិសេធចំពោះចំណុចពិចារណាមួយនៃសំណើដើម។ ឧទាហរណ៍ភាគី (ក) ស្នើសុំទិញដីភាគី (ខ) ក្នុងតម្លៃ ២០០០០០ ដុល្លា ពីភាគី (ខ) គាត់ព្រមលក់ដីតែមិនមែនក្នុងតម្លៃ ២០០០០០ ដុល្លានោះទេ ដោយប្រាប់ទៅអ្នកស្នើវិញថាលក់ក្នុងតម្លៃ ២៥០០០០ ដុល្លា ។

### ១.១.២. ស្ទីការ

ស្ទីការ គឺជាការបង្ហាញឆន្ទៈឆ្លើយតបចំពោះសំណើដែលភាគីម្ខាងទៀតបានស្នើ[៦៥] ។ ករណីបើគ្មានសំណើនោះទេ ប្រសិនបើបុគ្គលម្នាក់បានបង្ហាញឆន្ទៈណាមួយទៅកាន់ភាគីម្ខាងទៀតនោះការបង្ហាញឆន្ទៈនេះពុំមែន ជាស្ទីការទេតែគេបានបកស្រាថាជាសំណើទៅវិញ។ តួយ៉ាងដូចនៅក្នុង ឧទាហរណ៍ខាងលើមានស្រាប់លោក (ខ) ពុំដែលបានបង្ហាញឆន្ទៈថាគាត់ចង់លក់ដីម្តងណានោះឡើយតែលោក (ក) បានមកសួរទិញដីដែលគាត់មានជាប់ព្រំដីរបស់លោក (ក) ។ ការបង្ហាញឆន្ទៈចង់ទិញពុំមានជាការផ្តល់ស្ទីការនោះទេ តែជាការជូនដំណឹងអំពីការដាក់សំណើ។ ដោយឡែកបើសិនជាលោក(ខ) បានដាក់លក្ខខណ្ឌលើសំណើសុំទិញដីរបស់លោក (ក) ឬ ក៏គាត់បានកែប្រែសារធាតុផ្សេងនៃសំណើនោះ ស្ទីការលែងក្លាយជាស្ទីការគ្មានសុពលភាពទៀតហើយ តែវាបានក្លាយជាសំណើថ្មីទៅវិញ[៦៦]។ មានន័យថាលោក (ក) ពេលនេះលែងជាអ្នកធ្វើសំណើទៀតហើយ តែគាត់ប្រែក្លាយជាអ្នកទទួលសំណើវិញ ហើយសំណើថ្មីនោះនឹងមានអានុភាពនៅពេលដែលលោក (ក) យល់ព្រមទទួលសំណើថ្មីដែលកើតចេញពីការដាក់លក្ខខណ្ឌ ឬ ការកែប្រែសារធាតុនៃសំណើដើម ។

[៦៥] មាត្រា៣៣៧ កថាខណ្ឌទី៤, ក្រមរដ្ឋប្បវេណី, លេខនស/រកម/១២០៧/០៣០ ចុះថ្ងៃទី៨, ធ្នូ,២០០៧។

[៦៦] មាត្រា៣៤២, ក្រមរដ្ឋប្បវេណី, លេខនស/រកម/១២០៧/០៣០ ចុះថ្ងៃទី៨, ធ្នូ,២០០៧។

### ក. លក្ខខណ្ឌបង្កើតអានុភាពនៃស្ទីការ

អានុភាពនៃស្ទីការកើតមាននៅពេលដែលស្ទីការនោះ បានទៅដល់អ្នកស្នើ។ មួយវិញទៀតស្ទី-ការនោះត្រូវតែមានខ្លឹមសារនៃសារធាតុដូចគ្នា ឬ ត្រូវគ្នា ។

#### ក.១. ត្រូវនឹងសំណើ

ស្ទីការដែលមានលក្ខខណ្ឌត្រូវនឹងសំណើ គឺជាស្ទីការដែលឆ្លើយតបទទួលយកនូវកម្មវត្ថុតែមួយដែលសំណើបានស្នើឲ្យ។ មានន័យថាបើសំណើជាការស្នើសុំទិញអចលនវត្ថុមួយកន្លែងដែលមានទីតាំងកំណត់ជាក់លាក់ណាមួយដោយកំណត់យ៉ាងច្បាស់នៅក្នុងសំណើ ដែលភាគីម្ខាងបានផ្ញើរមកដល់ដៃភាគីម្ខាងទៀត ហើយភាគីម្ខាងទៀតត្រូវជូនដំណឹងតាមរយៈស្ទីការទៅគេវិញដោយកំណត់ថា ខ្លួនយល់ព្រម ឬ មិនយល់ព្រមលក់ ហើយដែលស្ទីការសំខាន់បំផុត គឺត្រូវឆ្លើយតបទៅនឹងកម្មវត្ថុនៃសំណើដែលភាគីម្ខាងនោះបានស្នើមកពោល គឺសំដៅដល់កម្មវត្ថុតែមួយ ជាអចលនវត្ថុដែលបានកំណត់ក្នុងសំណើនោះ។

ឧទាហរណ៍ ៖ ដដែលបើលោក (ខ) យល់ព្រមលក់ដីដែលគាត់មាននៅជាប់នឹងដីលោក (ក) ឲ្យទៅលោក (ក) តាមការស្នើសុំរបស់លោក (ក) នោះយើងចាត់ទុកស្ទីការត្រូវនឹងសំណើ។

#### ក.២. បានដល់អ្នកស្នើ

បានដល់អ្នកស្នើ សំដៅដល់ស្ទីការដែលស្ទីការនោះបានដល់ដៃរបស់អ្នកស្នើ។ យើងបានដឹងរួចមកហើយថាកិច្ចសន្យាមានរួចហើយនូវសំណើ គឺរង់ចាំតែស្ទីការមកដល់តែប៉ុណ្ណោះដូច្នោះនៅពេលណាដែលសំណើ និងស្ទីការបានជួបគ្នា ហើយនៅពេលនេះកិច្ចសន្យាមានរួចហើយនូវសំណើ គឺរង់ចាំតែស្ទីការមកដល់តែប៉ុណ្ណោះ ដូច្នោះនៅពេលដែលស្ទីការមកដល់ដៃអ្នកស្នើភ្លាម ស្ទីការនោះ នឹងត្រូវមានអានុភាពអនុវត្តភ្លាម ទើបយើងអាចទាញបានថា កិច្ចសន្យាត្រូវបានបង្កើតឡើងដោយសារតែសំ-ណើក៏មានអានុភាពឯស្ទីការក៏មានអានុភាព ។ ដោយហេតុថា ស្ទីការក៏គោរពតាមគោលការណ៍ដែលការបង្ហាញឆន្ទៈមានអានុភាពនៅពេលដែលការបង្ហាញឆន្ទៈ នោះទៅដល់ភាគីម្ខាងទៀត ដូចគ្នាទៅនឹងសំណើដែរ ។

### ខ. សកម្មភាពដែលចាត់ទុកថាជាស្ទីការ

ស្ទីការមិនប្រាកដទាល់តែនិយាយថាព្រមទើបអាចបង្កើតការព្រមព្រៀងនោះទេ ពីព្រោះច្បាប់ពុំបានកំណត់នូវមធ្យោបាយនៃការផ្តល់ស្ទីការនោះទេ ។ ដូច្នោះ ស្ទីការក្នុងការអាចស្តែងឡើងគ្រប់សកម្មភាពទាំងអស់ដូចជា ការធ្វើជាលិខិតលាយលក្ខណ៍អក្សរ ការទទួលប្រាក់កក់ជាដើម។

### ១.១.៣. ការព្រមព្រៀងដោយពិតប្រាកដ

ការបង្ហាញឆន្ទៈដោយស្មោះត្រង់ ដោយសេរី និងមិនមានវិការៈ គឺជាការព្រមព្រៀងដោយពិតប្រាកដ។ ការបង្ហាញឆន្ទៈដោយពិតប្រាកដ និងបង្កើតឲ្យមានអានុភាពចំពោះភាគីទាំងសងខាងនៃកិច្ចសន្យាតែបើកិច្ចសន្យាមានវិការៈវិញ កិច្ចសន្យានឹងត្រូវបដិសេធអានុភាពនៃការបង្ហាញឆន្ទៈ។ មានន័យថាភាគីដែលយល់ព្រមចុះកិច្ចសន្យា គឺគិតខុសពីកម្មវត្ថុដែលខ្លួនរំពឹងថានឹងត្រូវទទួលបាន ឬ ផ្តល់ឲ្យភាគីម្ខាងទៀត ហើយវាក៏អាចជាការយល់ច្រឡំមួយទៅលើ បុគ្គលដែលចុះកិច្ចសន្យានោះផងដែរ ។ វិការៈដែលភាគីនៃកិច្ចសន្យាគួរជៀសវាង និងមិនត្រូវបង្កើតក្នុងកិច្ចសន្យាមានដូចជា៖ ការភាន់ច្រឡំ (ក) ការឆបោក (ខ) ព័ត៌មានមិនពិត (គ) ការរំលោភបំពានលើស្ថានភាព (ឃ) ការគំរាមកំហែង (ង) ការកេងយកចំនេញហួសហេតុ (ច) បបនីយផ្លូវចិត្ត (ឆ) និងការបង្ហាញឆន្ទៈមិនពិត (ជ) ទាំងនេះ គឺជាការប្រែប្រួល ប្រាសចាកខុសភាពប្រក្រតីនៃសុចរិតភាពក្នុងការបង្កើតកិច្ចសន្យា ។

#### ក. ការភាន់ច្រឡំ

ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ បានកំណត់អនុញ្ញាតអោយមានការលុបចោលនូវកិច្ចសន្យាក្នុងករណីភាគីម្ខាងទៀតបានស្ថិតក្នុងស្ថានភាពដែលអាចដឹងអំពីការភាន់ច្រឡំនូវ ចំណុចសំខាន់ៗនៃកិច្ចសន្យា[៦៧]។ ការភាន់ច្រឡំ ត្រូវចាត់ទុកថា ជាមូលហេតុនៃការបដិសេធអានុភាពនៃការបង្ហាញឆន្ទៈ ឬ កិច្ចសន្យា ។

#### ក.១. ការភាន់ច្រឡំដោយភាគីម្ខាងអំពីស្ថានភាព

ភាគីដែលបង្ហាញឆន្ទៈដោយមានការភាន់ច្រឡំអាចលុបចោលកិច្ចសន្យាបាន។ ការលុបចោលកិច្ចសន្យា គឺធ្វើអោយភាគីនៃកិច្ចសន្យារួចផុតពីកាតព្វកិច្ចដែលត្រូវអនុវត្ត តែក៏ធ្វើអោយខូចដល់ភាគីម្ខាង ទៀតខាតបង់ផលដែលខ្លួនទទួលបានប្រយោជន៍ កាលបើការភាន់ច្រឡំនេះបង្កឡើងដោយភាគីម្ខាង ឯភាគីម្ខាងទៀតពុំបានដឹងពីស្ថានភាពដែលអាច ជាហេតុធ្វើអោយមានការភាន់ច្រឡំ ។

ឧទាហរណ៍ ៖ លោក កក្កដា មានដីឡូត៍ពីរជាប់គ្នា គឺ (ក) និង (ខ) ដែលមានដីឡូត៍ (ខ) នៅជាប់និងដីឡូត៍របស់អ្នកស្រី វិច្ឆិការ គឺ (គ) ។ អ្នកស្រីវិច្ឆិការ មានបំណងចង់ទិញដីឡូត៍ (ខ) ដែលនៅជាប់និងព្រំប្រទល់ដីរបស់អ្នកស្រី ដើម្បីពង្រីកដីចំការមៀនរបស់គាត់បន្ថែម តែដោយការភាន់ច្រឡំ អ្នកស្រីវិច្ឆិការ ពុំបានដឹងថា លោក កក្កដា មានដីឡូត៍ពីរជាប់គ្នា អ្នកស្រីវិច្ឆិការ ក៏បានចុះកិច្ចសន្យាជាមួយ និងលោក កក្កដា ទិញដីឡូត៍ (ក) ដោយខុសពីវត្ថុបំណងរបស់គាត់ទៅវិញ ។

[៦៧] មាត្រា៣៨៦ កថាខណ្ឌទី២, ក្រមរដ្ឋប្បវេណី, លេខនស/រកម/១២០៧/០៣០ ចុះថ្ងៃទី៨, ធ្នូ,២០០៧។

ដោយយោងតាមអង្គហេតុខាងលើ យើងឃើញថា អ្នកស្រីវិច្ឆិការ គឺពុំមានឆន្ទៈចង់ទិញដីឡូត៍ (ក) ទេ ដីដែលគាត់ចង់ទិញនោះ គឺដីឡូត៍ (ខ) ឯនោះ ។ ករណីនេះបើ អ្នកស្រីវិច្ឆិការ ចង់លុបចោលកិច្ចសន្យាទិញដីពីលោកកក្កដាបាន ទាល់តែអ្នកស្រីវិច្ឆិការ បង្ហាញភស្តុតាងណាមួយមកបញ្ជាក់ថាគាត់ពិត ជាមានការភាន់ច្រឡំ ឬ លោក កក្កដា អាចនឹងដឹងពីការភាន់ច្រឡំនេះ ។

**ក.២. ការភាន់ច្រឡំដោយអត្តនោម័តនៃភាគីម្ខាង**

ការភាន់ច្រឡំក៏អាចកើតមានឡើងតាមរយៈ ការបង្ហាញឆន្ទៈអត្តនោម័តថាសំខាន់ ឬ ជាចំណុចដែលខ្លួនយល់ឃើញថាសំខាន់ក្នុងកិច្ចសន្យា ករណីនេះភាគីដែលបានច្រឡំអាចលុបចោលកិច្ចសន្យាបានកាលបើភាគីម្ខាងទៀតបានស្ថិតក្នុងស្ថានភាពដែលអាចដឹងអំពីភាពសំខាន់នៃចំណុចនេះ។ ការភាន់ច្រឡំដោយអត្តនោម័តបែបនេះងាយកើតមានក្នុងករណី ២ គឺ: **ការអត្តនោម័តដោយភាគីភាន់ច្រឡំ** ថាចំណុចនេះ ឬ ចំណុចនោះ ជាចំណុចសំខាន់ក្នុងកិច្ចសន្យាឯកឯងដែរ ជាធម្មតាមិនសំខាន់ ឯករណីការភាន់ច្រឡំមួយទៀត គឺ: **ការភាន់ច្រឡំអំពីមូលហេតុ** ។

ឧទាហរណ៍ ៖ មុនចុះកិច្ចសន្យា ជាមួយក្រុមហ៊ុន (ក) ទិញផ្ទះមួយកន្លែងក្នុងបុរី ដែលមានទីតាំងនៅសង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ ។ លោក (ខ) បានប្រាប់ក្រុមហ៊ុន (ក) ថាលោកពេញចិត្តនឹងមកទិញផ្ទះដូចគ្នាបេះបិទ និងផ្ទះក្នុងបុរីរបស់ក្រុមហ៊ុន (ក) នៅក្នុងខេត្តសៀមរាប ។ ក្រោយពីចុះកិច្ចសន្យាទិញផ្ទះក្នុងបុរីនោះហើយលោក (ខ) បានទៅមើលផ្ទះដែលខ្លួនបានទិញគាត់មើលឃើញថាផ្ទះនោះ គឺពិតជាដូចគ្នាបេះបិទទៅនឹងផ្ទះដែលគាត់ស្រលាញ់ តែអ្វីដែលគាត់មិនសប្បាយចិត្តនោះគឺម៉ូតបង្កាន់ដៃ រានផ្ទះខាងមុខ ខុសពីផ្ទះដែលគាត់ពេញចិត្ត។ ហេតុនេះ លោក (ខ) ចង់លុបចោលនូវកិច្ចសន្យានោះវិញ ។ នេះ គឺអាចជាមូលហេតុដែលនាំឲ្យកិច្ចសន្យាត្រូវបានលុបចោលដែរកាលបើភាគីនៃកិច្ចសន្យា បានយល់ឃើញថាចំណុចនេះ ឬ ចំណុចនោះសំខាន់ក្នុងកិច្ចសន្យា នោះភាគីរងគ្រោះពីការភាន់ច្រឡំ អាចលុបចោលបាន ។ យ៉ាងណាវិញហេតុផល គឺវាមិនត្រូវទេបើអនុញ្ញាតដោយ ងាយស្រួលបែបនេះ ពីព្រោះថាវាអាចធ្វើអោយខូចប្រយោជន៍របស់ភាគីម្ខាងទៀត ។ ការភាន់ច្រឡំបែបនេះហៅថាការអត្តនោម័តដោយភាគីភាន់ច្រឡំ ថាអ្វីមួយសំខាន់តែធាតុពិតជាទូទៅវាអាចនឹងមិនសំខាន់ ។

**ខ. ការឆបោក**

ការឆបោក គឺជាអំពើបន្លំចំពោះបុគ្គលបង្ហាញឆន្ទៈ ដោយបុគ្គលប្រព្រឹត្តប្រើឧបាយកលទុច្ចរិតដើម្បីអោយបុគ្គលបង្ហាញឆន្ទៈខូចប្រយោជន៍ ។ ប្រសិនបើការបង្ហាញឆន្ទៈត្រូវធ្វើដោយមានការឆបោកប្រព្រឹត្តដោយភាគីម្ខាងទៀត ឬ តតិយជននោះ សិទ្ធិលុបចោលកិច្ចសន្យានឹងត្រូវបានផ្តល់អោយអ្នកបង្ហាញឆន្ទៈដោយហេតុ ថាការបង្ហាញឆន្ទៈនោះមានវិការៈ ។ ក្នុងករណីការឆបោកកើតចេញពីភាគីម្ខាង

ទៀតនៃកិច្ចសន្យា នោះការលុបចោលផលនៃកិច្ចសន្យត្រូវបានអនុញ្ញាតដោយគ្មានការស្មុគស្មាញ។ ប៉ុន្តែ បើសិនជាការឆបោកនោះ ជាអំពើប្រព្រឹត្តដោយតតិយជនវិញនោះ និងមានចំណោទមួយត្រូវយកមកពិចារណាថា តើភាគីម្ខាងទៀតដែលធ្វើកិច្ចសន្យា ជាមួយអ្នកបង្ហាញឆន្ទៈដោយមានវិការៈបានដឹង ឬអាចដឹងពីការឆបោកនោះ ឬទេ ?

ឧទាហរណ៍៖ លោក (ក) បានបន្លំឋានៈជាមេធាវីធ្វើកិច្ចសន្យាទិញដីពីលោក (ខ) ឲ្យទៅលោក (គ) ក្នុងតម្លៃ៨ពាន់ដុល្លា ដោយកំណត់ថ្ងៃប្រគល់ប្រាក់ ២សប្តាហ៍គិតចាប់ពីថ្ងៃចុះកិច្ចសន្យាលក់ទិញដី។ ដោយការមមាញឹក និង មុខរបររកស៊ីផង និងជឿទុកចិត្តលើមេធាវី (ក) ផង លោក (គ) បានប្រគល់ប្រាក់គ្រប់ចំនួនឲ្យទៅលោកមេធាវី (ក) យកទៅទិញដី លោក (ខ) និងរត់ឯកសារជូនគាត់ ។ តែដោយលោក (ក) ជាជនទុច្ចរិត ក្លែងបន្លំខ្លួន ជាមេធាវី ក្រោយពីទទួលបានប្រាក់ហើយ លោក (ក) ក៏បានយកប្រាក់នោះរត់បាត់ ។ យោងតាមអង្គហេតុខាងលើលោក (គ) បានបង្កើតកិច្ចសន្យាជាមួយលោក (ខ) ដោយការឆបោករបស់ លោក (ក) ដែលតាំងខ្លួនបន្លំ ជាមេធាវី បង្កើតកិច្ចសន្យាលក់ទិញពីលោក (ខ) ទៅអោយ លោក (គ) ។

ក្នុងករណីនេះប្រសិនបើលោក (គ) ចង់លុបចោលកិច្ចសន្យានោះ គឺគាត់ពុំអាចធ្វើទៅបាននោះទេ កាលបើលោក (ខ) ជាជនទុច្ចរិត គ្មានកំហុសពីការឆបោកនោះ[៦៨]។ មានន័យថា ការលុបចោលកិច្ច-សន្យាដែលធ្វើឡើងដោយការឆបោករបស់តតិយជន នឹងត្រូវបានអនុញ្ញាត លុះត្រាតែភាគីម្ខាងទៀត លោក (ខ) បានដឹង ឬ អាចដឹងអំពីការឆបោកនោះ[៦៩]។

### គ. ព័ត៌មានមិនពិត

សិទ្ធិលុបចោលកិច្ចសន្យា ត្រូវបានផ្តល់ឲ្យអ្នកបង្ហាញឆន្ទៈ ករណីការបង្ហាញឆន្ទៈធ្វើឡើងដោយសារតែការផ្តល់ព័ត៌មានមិនពិត តាមរយៈភាគីម្ខាងទៀតនៃកិច្ចសន្យា ។ នៅក្នុងករណីដែលភាគីម្ខាងទៀតបង្ហាញព័ត៌មានមិនពិតដោយចេតនានេះនឹងក្លាយទៅជាឆបោក ហើយប្រសិនបើអ្នកបង្ហាញឆន្ទៈមានការភាន់ច្រឡំ ហេតុដូច្នោះការលុបចោលកិច្ចសន្យាអាចអនុញ្ញាតដោយហេតុផល នៃការភាន់ច្រឡំ។ ការលុបចោលនៃកិច្ចសន្យាអាចអនុញ្ញាតទៅបាន លុះត្រាតែការភាន់ច្រឡំនោះទាក់ទង និងចំណុចសំខាន់ក្នុងកិច្ចសន្យា និងភាគីម្ខាងទៀតមានលទ្ធភាពក្នុងការដឹងអំពីការភាន់ច្រឡំ[៧០]។ លើសពីនេះទៅទៀត ភាគីដែលបង្ហាញឆន្ទៈដោយជឿជាក់ថា ហេតុទាំងនោះជាការពិត មិនគ្រាន់តែត្រូវបាន

[៦៨]មាត្រា ៣៤៧ កថាខណ្ឌទី៣, ក្រមរដ្ឋប្បវេណី,លេខនស/រកម/១២០៧/០៣០ ចុះថ្ងៃទី៨, ធ្នូ, ២០០៧។

[៦៩]មាត្រា៣៤៧ កថាខណ្ឌ ទី២, ក្រមរដ្ឋប្បវេណី,លេខនស/រកម/១២០៧/០៣០ ចុះថ្ងៃទី៨, ធ្នូ, ២០០៧។

[៧០]មាត្រា ៣៤៦ កថាខណ្ឌ ទី១, ក្រមរដ្ឋប្បវេណី,លេខនស/រកម/១២០៧/០៣០ ចុះថ្ងៃទី៨, ធ្នូ, ២០០៧។

អនុញ្ញាតឲ្យលុបចោលនៃកិច្ចសន្យានោះទេ តែក៏មានសិទ្ធិទាមទានូវសំណងនៃការខូចខាត ដែលនៅសល់ក្រោយកិច្ចសន្យាបានដែរ ឬ ក៏ទុកកិច្ចសន្យាអោយមានអានុភាពបន្តតែទាមទារនូវសំណងនៃការខូចខាតដែលកើតមានដោយភាគីបង្ហាញព័ត៌មានមិនពិត។ ចំពោះទំហំនៃការខូចខាតវិញ គឺពិតជាមានការលំបាកក្នុងការកំណត់ថាតើវាមានទំហំខូចខាតប៉ុណ្ណា គឺអាស្រ័យលើការបកស្រាយតាមរយៈគតិយុត្តិសាស្ត្រ និងទ្រឹស្តីនាពេលអនុវត្តរឿងហេតុជាក់លាក់[៧១]។ ផ្ទុយទៅវិញការលុបចោលកិច្ចសន្យាមិនអាចធ្វើទៅបានទេប្រសិនបើតតិយជន ជាជនសុច្ចរិតហើយគ្មានកំហុសពីព័ត៌មានមិនពិត។ មានន័យថាតតីយជន គឺមិនបានដឹងហេតុផលនៃព័ត៌មានមិនពិតនោះទេ ហេតុដូច្នោះប្រសិនបើការលុបចោលកិច្ចសន្យាត្រូវបានអនុញ្ញាត្តនោះ និងនាំឲ្យតតិយជនខូចប្រយោជន៍[៧២]។

**ឃ. ការរំលោភបំពានលើស្ថានភាព**

ភាគីនៃកិច្ចសន្យាដែលបង្ហាញឆន្ទៈមានវិការៈ ដោយការរំលោភបំពានលើស្ថានភាពពីភាគីម្ខាងទៀតនៃកិច្ចសន្យាអាចធ្វើការលុបចោលកិច្ចសន្យានោះបាន ។ ការរំលោភបំពានលើស្ថានភាព គឺសំដៅទៅលើការប្រើមិនត្រឹមត្រូវនូវឋានៈ ដែលមានអនុភាពជាងភាគីម្ខាងទៀតរំលោភបំពានមកលើភាគីបង្ហាញឆន្ទៈតាមរយៈផ្នែកសេដ្ឋកិច្ច ឬ ផ្នែកសង្គម ឬ ក៏ប្រើដោយមិនត្រឹមត្រូវនូវស្ថានភាពផ្សេងៗទៀត ដូច-ជា៖ ភាពចាំបាច់ ភាពពឹងពាក់ ការធ្វើសកម្មភាពភ្លាមៗ ដែលខ្វះការពិចារណា ស្ថានភាពខាងប្រាជ្ញាមិនប្រក្រតី ឬភាពខ្វះខាតបទពិសោធន៍ ដែលធ្វើអោយភាគីបង្ហាញឆន្ទៈមិនអាចតបវិញបាន។ ទោះបីក-រណីមិនមាន ជាការគំរាមកំហែងក៏ដោយតែអ្នកបង្ហាញឆន្ទៈត្រូវបានបង្ខំឲ្យបង្ហាញឆន្ទៈខុសពីបំណងដែលខ្លួនចង់ធ្វើផ្អែកតាមសកម្មភាពរំលោភបំពានលើស្ថានភាព នៅពេលធ្វើកិច្ចសន្យាបែបនេះការលុបចោលកិច្ចសន្យាត្រូវបានអនុញ្ញាត ក្នុងករណីដែលមានការប្រើដោយមិនត្រឹមត្រូវនូវស្ថានភាពប៉ុណ្ណោះនោះទេ ។

ឧទាហរណ៍៖ លោក (ក) ជាកសិករដែលរស់នូវអាស្រ័យផល ជាមួយដីស្រែមួយកន្លែងទំហំ ២ ហិចតា ។ ថ្ងៃមួយលោក (ក) បានទៅខ្ចីលុយ លោក (ខ) ១លានរៀលដើម្បីយកប្រពន្ធទៅមន្ទីរពេទ្យឆ្លងទន្លេជាប្រញាប់។ ខណៈពេលលោក (ខ) ព្រមឲ្យលោក (ក) ខ្ចីលុយតែដាក់លក្ខខណ្ឌឲ្យលោកដាក់ដីស្រែបញ្ចាំ ក្នុងរយៈពេល ២ថ្ងៃ បើលោក (ក) ពុំមានលុយសងនោះទេ ដីនោះ និងត្រូវបានមកជាដីកម្មសិទ្ធិរបស់លោក (ខ) ។ ក្រោយពីសិក្សាលើអង្គហេតុខាងលើយើងឃើញថាលោក (ខ) ជាភាគីរំលោភបំពានលើស្ថានភាពឆ្លៀតឪកាសនៅពេលដែលលោក (ក) ទៅពឹងពាក់សុំខ្ចីលុយលោក (ខ)

---

[៧១]មាត្រា៣៨៨ កថាខណ្ឌ ទី២, ក្រមរដ្ឋប្បវេណី,លេខនស/រកម/១២០៧/០៣០ ចុះថ្ងៃទី៨, ធ្នូ, ២០០៧។

[៧២]មាត្រា ៣៨៨ កថាខណ្ឌ ទី៣, ក្រមរដ្ឋប្បវេណី,លេខនស/រកម/១២០៧/០៣០ ចុះថ្ងៃទី៨, ធ្នូ, ២០០៧។

បានដាក់គំនាបឲ្យលោក (ក) យកដីស្រែមកបញ្ចាំពិសេសធ្វើការកំណត់រយៈពេល ខ្លីក្នុងការសងប្តូរួម ទាំងទំហំដី និង ចំនួនលុយដែល លោក(ខ)ខ្ចីមានទំហំខុសគ្នាទៀតនោះ។ ហេតុដូចនេះកិច្ចសន្យាដែលកើតឡើងពីស្ថានភាពរំលោភបំពានលើស្ថានភាពនៅពេលធ្វើកិច្ចសន្យាបែបនេះ ការលុបចោលកិច្ចសន្យាត្រូវបានអនុញ្ញាតក្នុងករណីដែលមានការប្រើដោយមិនត្រឹមត្រូវនូវស្ថានភាព ។

### ង. ការគម្រាមកំហែង

ការព្រមព្រៀងនឹងគ្មានសុពលភាពនោះទេ ដែលអ្នកបង្ហាញឆន្ទៈធ្វើឡើងដោយមានការគម្រាមកំហែងពីសំណាក់ភាគីម្ខាងទៀត ឬ ពីសំណាក់តតិយជន[៧៣] ។ ដោយហេតុថា អ្នកបង្ហាញឆន្ទៈគ្មានបំណងបង្កើតកិច្ចសន្យា ។ ការគម្រាមកំហែងនេះ អាចធ្វើឡើងក្រោមសកម្មភាពពីរ គឺតាមរយៈការគម្រាមកំហែងលើរូបរាងកាយដូចជា ការផ្តល់គំនៀប និង ការសង្កត់សង្កិនផ្លូវចិត្តរបស់អ្នកបង្ហាញឆន្ទៈយ៉ាងអាក្រក់ ជាញឹកញាប់សកម្មភាពបែបហ្នឹង តែងតែកើតមានក្នុងសង្គមខ្មែរបច្ចុប្បន្ន ។ ការគម្រាមកំហែងដែលធ្វើឡើងដោយតតិយជនខុសគ្នាពីករណីឆបោក ដោយហេតុថា ការអនុញ្ញាតឲ្យលុបចោលនេះ គឺគ្មានលក្ខខណ្ឌបន្ថែមនោះទេ ទោះបីជា ភាគីម្ខាងទៀតគ្មានលទ្ធភាពក្នុងការដឹងអំពីការគម្រាមកំហែងក៏ដោយ។ ក្នុងន័យនេះច្បាប់ គឺការពារចំពោះអ្នកបង្ហាញឆន្ទៈ ដោយការគម្រាមកំហែងពីសំណាក់តតិយជនជាង ការពារផលប្រយោជន៍ឲ្យភាគីម្ខាងទៀតនៃកិច្ចសន្យា ទោះបីជាបុគ្គលនេះជាជនសុច្ចរិតក៏ដោយ ពីព្រោះបើយើងពិចារណា ទៅលើទំហំនៃការរងគ្រោះរបស់អ្នកបង្ហាញឆន្ទៈដោយការគម្រាមកំហែង គឺមានលក្ខណៈធ្ងន់ធ្ងរអាក្រក់ ខ្លាំងណាស់ ។

ឧទាហរណ៍៖ លោក (គ) បានចាប់កូនស្រីរបស់លោក (ខ) ដើម្បីគម្រាមអោយយល់ព្រមចុះកិច្ចសន្យាលក់ដីឯកជនរបស់រដ្ឋមួយកន្លែងទំហំ ៩០ ហិចតា ទៅអោយអ្នកតំណាងប្រទេស (គ) ។ ផ្អែកទៅលើស្ថានភាពគម្រាមកំហែងយ៉ាងធ្ងន់ធ្ងរបែបនេះ លោក (ខ) អាចបង្ហាញឆន្ទៈលុបចោលកិច្ចសន្យាព្រមលក់ដីនោះបានដោយគ្មានលក្ខខណ្ឌទោះបី ជាភាគីម្ខាងទៀតនៃកិច្ចសន្យា លោក (គ) មិនបានដឹងអំពីការគម្រាមកំហែងនេះក៏ដោយ ។

### ច. ការកេងយកចំណេញហួសហេតុ

ការកេងយកចំណេញហួសហេតុ ដោយភាគីម្ខាងបានឆ្លៀតឱកាសកេងយកចំណេញយ៉ាងសន្ធឹកសន្ធាប់ពីកិច្ចសន្យាខណៈពេលដែលភាគីម្ខាងទៀតកំពុងតែជួបប្រទះការលំបាក ខាងផ្នែកសេដ្ឋកិច្ច ឬ ភាពល្ងង់ ឬ ខ្វះបទពិសោធន៍ទាំងនេះ ជាមូលហេតុនាំឲ្យកិច្ចសន្យាអាចលុបចោលបាន[៧៤]។ ជាទូ-

[៧៣]មាត្រា៣៥០, ក្រមរដ្ឋប្បវេណី,លេខនស/រកម/១២០៧/០៣០ ចុះថ្ងៃទី៨, ធ្នូ, ២០០៧។

[៧៤]មាត្រា៣៥១, ក្រមរដ្ឋប្បវេណី,លេខនស/រកម/១២០៧/០៣០ ចុះថ្ងៃទី៨, ធ្នូ, ២០០៧។

ទៅសកម្មភាពបែបនេះយើងតែងតែឃើញកើតមាននៅ លើប្រជាជនក្រីក្រនៅតាមជនបទ ជាជាងនៅក្នុងទីក្រុង។ ជាពិសេសក្នុងមុខជំនួញដែលភាគីម្ខាងហៅថា អាជីវករបានឆ្លៀតឱកាសកេងយកចំណេ-ញហួសហេតុពីអ្នកទិញ ឬ អ្នកប្រើប្រាស់។ ប៉ុន្តែបើយើងអនុញ្ញាតឲ្យមានការលុបចោលកិច្ចសន្យាងាយស្រួលពេកហាក់បីដូចជា កិច្ចសន្យាពុំមានតម្លៃ។ ដើម្បីអោយការលុបចោលកិច្ចសន្យាអាចធ្វើទៅបានចាំបាច់ត្រូវតែពិនិត្យថា តើកិច្ចសន្យានោះធ្វើឡើងដោយការគេងយកចំណេញហួសហេតុ ឬ យ៉ាងណា។ ការកេងយកចំណេញហួសហេតុ គឺពុំបានកំណត់និយមន័យ ឬ ទំហំណាមួយជាគោលការណ៍ក្នុងក្រមរដ្ឋប្បវេណីខ្មែរឆ្នាំ ២០០៧ នោះទេ ហេតុនេះចាំបាច់ឲ្យមានការវិនិច្ឆ័យតាមរយៈការប្រើយុត្តិ-សាស្ត្រអនុលោមតាមពេលវេលា និងស្ថានភាព។ គួរពិចារណាផងដែរថា បញ្ញត្តិដែលចែងពីការកេងយក ចំណេញហួសហេតុនេះស្រដៀងទៅ នឹងបញ្ញត្តិស្តីពីការរំលោភបំពានលើស្ថានភាពដែរតែអ្វីដែលខុសគ្នា គឺទំហំនៃការបង្ខំភាគីម្ខាងទៀត។ ការកេងចំណេញហួសហេតុមានទំហំតូចជាងការរំលោភបំពាន លើស្ថានភាពពីព្រោះថា បើយើងនិយាយពីអំពើដែលភាគីម្ខាងទៀតនៃកិច្ចសន្យាប្រើមកលើភាគីបង្ហាញឆន្ទៈដោយការរំលោភបំពានលើស្ថានភាព គឺមិនបានទុកឱកាសឲ្យភាគីដែលត្រូវបានរំលោភបំពានធ្វើការប្រឆាំងតបទេ ។

**ឆ. បបនីយផ្លូវចិត្ត**

បបនីយផ្លូវចិត្ត គឺជាការបង្ហាញឆន្ទៈដែលធ្វើអោយដឹងថា ការបង្ហាញឆន្ទៈនោះមិនពិតទេ ។ កិច្ចសន្យាមិនត្រូវបានរារាំងអានុភាពឡើយ ប្រសិនបើកិច្ចសន្យាត្រូវបានបង្កើតឡើងដោយការបង្ហាញឆន្ទៈដែលភាគីដឹងថាខុសឆន្ទៈរបស់ខ្លួន។ តែអ្នកបង្ហាញឆន្ទៈនោះអាចបដិសេធការអនុវត្តកិច្ចសន្យាបានក្នុងករណីដែលភាគីម្ខាងទៀតក៏ដឹងថា ការបង្ហាញឆន្ទៈនោះខុសពី ការពិតរបស់អ្នកបង្ហាញឆន្ទៈ[៧៥]។ ក្នុងករណី នេះមិនមានន័យថា កិច្ចសន្យាត្រូវបានបដិសេធអានុភាពនោះទេ ។ ការបង្ហាញឆន្ទៈដែលធ្វើឡើងដោយបបនីយផ្លូវចិត្ត ជាការបង្ហាញឆន្ទៈមិនពិតរបស់ភាគីអ្នកបង្ហាញឆន្ទៈ ដូចនេះវាជា ការបង្ហាញឆន្ទៈដែលមានវិការៈលុបចោលបានក៏ប៉ុន្តែក្នុងករណីនេះកិច្ចសន្យា គឺមិនអនុញ្ញាតឲ្យលុបចោលបានទេទោះភាគីម្ខាងទៀតបានដឹងថាបង្ហាញឆន្ទៈមិនពិតរបស់អ្នកបង្ហាញឆន្ទៈក៏ដោយ ក៏សុពលភាពនៃកិច្ចសន្យាត្រូវកើតឡើងដែរ ពីព្រោះថាការបង្ហាញឆន្ទៈមិនពិតដែលកើតចេញពីអ្នកបង្ហាញឆន្ទៈមិនពិត គឺមិនចាំបាច់មានការការពារខាងការបង្ហាញឆន្ទៈរបស់ភាគីនេះឡើយ ។

[៧៥] មាត្រា៣៥២, ក្រមរដ្ឋប្បវេណី,លេខនស/រកម/១២០៧/០៣០ ចុះថ្ងៃទី៨, ធ្នូ, ២០០៧។

### ជ. ការបង្ហាញឆន្ទៈមិនពិត

ដើម្បីបង្កើតកិច្ចសន្យានោះ ភាគីនៃកិច្ចសន្យាត្រូវតែសំដែងឆន្ទៈត្រូវគ្នាព្រមបង្កើត និងអនុវត្តតាមគ្រប់ចំណុច ឬ ប្រការដែលមានចងភ្ជាប់ជាកាតព្វកិច្ចសន្យាគោរព និងធ្វើតាម ។ លើសពីនេះទៅទៀត ក្រមរដ្ឋប្បវេណីក៏បានបញ្ញត្តិក្នុងមាត្រាមួយចំនួនថា ដើម្បីឲ្យកិច្ចសន្យាមួយមានសុពលភាពលុះត្រាតែកិច្ចសន្យានោះ ធ្វើឡើងដោយការបង្ហាញឆន្ទៈគ្មានវិការៈពុំដូចនោះទេកិច្ចសន្យានឹងត្រូវបានលុបចោល។ ក្នុងក្រមនេះក៏បានបញ្ញត្តិផងដែរថា ការបង្ហាញឆន្ទៈមិនពិតដែលធ្វើឡើងដោយឃុបឃិតជាមួយភាគីម្ខាងទៀត នឹងជាមូលហេតុនាំឲ្យកិច្ចសន្យាត្រូវចាត់ទុក ជាមោឃៈភាព[៧៦]។ មូលហេតុដែលច្បាប់បញ្ញត្តិបែបនេះ ពីព្រោះតែចង់ការពារផលប្រយោជន៍អោយតតិយជនដែលជាជនសុចរិតមិន បានដឹងពីការបង្ហាញឆន្ទៈមិនពិតប្រាកដរបស់ភាគីខាងលើនោះឡើយ បើតតិយជននេះបានដឹងទំនង ជាតតីយជននេះមិនព្រមបង្កើតកិច្ចសន្យានេះឡើងដែរ។ ផ្ទុយទៅវិញបើតតីយជននេះបានដឹងហើយតែនៅតែព្រមបង្កើតកិច្ចសន្យាបែបនេះឡើងទៀតនោះ កិច្ចសន្យាត្រូវចាត់ទុកមានអានុភាព ។

### ១.២. សមត្ថភាព

សមត្ថភាព គឺជាអំណាច ឬ លទ្ធភាពចុះកិច្ចសន្យាបានចំពោះភាគីនៃកិច្ចសន្យា ។ តាមលក្ខខណ្ឌសុពលភាព នៃកិច្ចសន្យាបានកំណត់យ៉ាងច្បាស់ពីសមត្ថភាពរបស់បុគ្គលដែលអាចចុះកិច្ចសន្យាបាននាំឲ្យកិច្ចសន្យាមួយត្រឹមត្រូវស្របច្បាប់ និងមានសុពលភាពពេញលេញ ។

យោងតាមការប្រកាសអំពីគោលការណ៍នៃសមត្ថភាពទទួលសិទ្ធិ រូបវន្តបុគ្គលគ្រប់រូបមានសិទ្ធិសេរីទទួលបានភាពជាម្ចាស់នៃសិទ្ធិ និងកាតព្វកិច្ចរបស់ខ្លួនពេញលេញក្នុងការធ្វើសកម្មភាពលើកលែងតែសមត្ថភាពមួយចំនួនដែលច្បាប់បានកម្រិតសមត្ថភាពបុគ្គលនោះប៉ុណ្ណោះ[៧៧]។ ជាទូទៅពាក្យសមត្ថភាពត្រូវបានគេប្រើសំដៅទៅលើបុគ្គលពីរ គឺបុគ្គលដែលមានសមត្ថភាពក្នុងការធ្វើសកម្មភាព គឺមិនត្រូវបានផ្តល់សិទ្ធិពេញលេញឲ្យបុគ្គលនោះ ធ្វើសកម្មភាពលើគ្រប់វិស័យបានទេ លើកលែងតែសកម្មភាពទាក់ទង និងជីវភាពរស់នៅប្រចាំថ្ងៃ។ ជាក់ស្តែងបុគ្គលទាំងនោះសំដៅលើអនីតិជនជននៅក្រោមអាណាព្យាបាលទូទៅនិងជននៅក្រោមហិតូបត្ថម្ភ[៧៨]។

ក្រោយពីបានសិក្សាអំពីសមត្ថភាពរបស់បុគ្គលរួចមក ចំពោះសមត្ថភាពបុគ្គលដែលទាក់ទង

---

[៧៦] មាត្រា ៣៥៣, ក្រមរដ្ឋប្បវេណី,លេខនស/រកម/១២០៧/០៣០ ចុះថ្ងៃទី៨, ធ្នូ, ២០០៧។

[៧៧] មាត្រា ៦ , ក្រមរដ្ឋប្បវេណី,លេខនស/រកម/១២០៧/០៣០ ចុះថ្ងៃទី៨, ធ្នូ, ២០០៧។

[៧៨] មាត្រា១៦, ក្រមរដ្ឋប្បវេណី,លេខនស/រកម/១២០៧/០៣០ ចុះថ្ងៃទី៨, ធ្នូ, ២០០៧។

នឹងការធ្វើកិច្ចសន្យាលក់ទិញអចលនវត្ថុវិញ យើងបានបែងចែកសមត្ថភាពបុគ្គលទាំងនោះជា ៣ (បី) រួមមាន ៖ បុគ្គលកម្រិតសមត្ថភាពទទួលសិទ្ធិធ្វើកិច្ចសន្យា (១.២.១) បុគ្គលស្ថិតក្នុងស្ថានភាពខ្វះសមត្ថភាព (១.២.២) និង បុគ្គលគ្មានសមត្ថភាពធ្វើកិច្ចសន្យា (១.២.៣) ដោយយើងមិនរាប់បញ្ចូលបុគ្គលមានសមត្ថភាព ពេញលេញក្នុងការធ្វើកិច្ចសន្យានោះទេ ។ បុគ្គលទាំងនេះត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើកិច្ចសន្យាធំដុំជាអាទ៍កិច្ចសន្យាលក់ទិញអចលនវត្ថុ។ តើហេតុអ្វីបានជាបុគ្គលទាំងបីខាងលើត្រូវបានកម្រិតសមត្ថភាព និងគ្មានសមត្ថភាពធ្វើកិច្ចសន្យាលក់ទិញអចលនវត្ថុបែបនេះ ?

### ១.២.១. បុគ្គលកម្រិតសមត្ថភាពទទួលសិទ្ធិធ្វើកិច្ចសន្យា

យោងតាមគោលការណ៍សមត្ថភាពនៃសមត្ថភាពទទួលសិទ្ធិ បុគ្គលគ្រប់រូបមានសិទ្ធិសេរីភាពក្នុងការធ្វើសកម្មភាព ដោយមិនមានការរើសអើងពូជសាសន៍ ពណ៌សម្បុរ ឬ និន្នាការនយោបាយ សាសនា ការងារ ឈ្មោះជាដើមនោះឡើយ លើកលែងតែច្បាប់បានបញ្ញត្តិ ។ មានតែរូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានសញ្ជាតិជាខ្មែរទេទើបមានសិទ្ធិជាម្ចាស់កម្មសិទ្ធិលើដីធ្លី[៧៩]។ ឧទារហរណ៍៖ ចំពោះជនបរទេស គឺមានការកម្រិតសមត្ថភាពមួយចំនួនដូចជា៖ មិនអាចទទួលបាន ឬកាន់កាប់នូវសិទ្ធិធ្វើលទ្ធកម្មនូវសិទ្ធិមួយចំនួនបានឡើយបើមានបញ្ញត្តិចែង។ តួយ៉ាងសមត្ថភាពលក់ ឬ ទិញទ្រព្យជាអចលនវត្ថុដោយជនបរទេសត្រូវហាមឃាត់[៨០]។

### ១.២.២. បុគ្គលស្ថិតក្នុងស្ថានភាពខ្វះសមត្ថភាពធ្វើកិច្ចសន្យា

យោងតាមគោលការណ៍ស្ដីពីសមត្ថភាពខាងឆន្ទៈ ទោះបីមិនមែនជាជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាពក៏ដោយ ក៏អាចលុបចោលបាននូវសកម្មភាពដែលបានធ្វើឡើងក្នុងស្ថានភាពខ្វះសមត្ថភាពក្នុងការយល់ដឹង និងក្នុងការវិនិច្ឆ័យអំពីលទ្ធភាពតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួនបានដែរ ។ តួយ៉ាងសកម្មភាពធ្វើកិច្ចសន្យានៃជនស្ថិតក្នុងស្ថានភាពស្រវឹង ឬ ប្រើថ្នាំអាចលុបចោលកិច្ចសន្យាបានដោយមូលហេតុ សមត្ថភាពក្នុងការវិនិច្ឆ័យលទ្ធភាពតាមផ្លូវច្បាប់ថយចុះយ៉ាងខ្លាំង[៨១]។ ឧទាហរណ៍ ៖ លោក (ក) បានធ្វើកិច្ចសន្យាព្រមលក់ដីលំនៅស្ថានរបស់ខ្លួនក្នុងស្ថានភាពស្រវឹងជាខ្លាំងឲ្យទៅលោក (ខ) ។ ស្ថានភាពស្រវឹងបែបនេះ គឺស្ថានភាពខ្វះសមត្ថភាពបើអនុញ្ញាតឲ្យកិច្ចសន្យានេះមានសុពលភាព នោះហានិភ័យចំពោះភាគីខ្វះសមត្ថភាព និងកើតមានឡើង។ ហេតុដូច្នេះរបបស្ដីពីស្ថានភាពនៃឆន្ទៈ គឺយកមកប្រើសម្រាប់ការពារកុំអោយមានការខូចខាតប្រយោជន៍តាមរយៈកិច្ច

[៧៩] មាត្រា៨៩,ក្រមរដ្ឋប្បវេណី,លេខនស/រកម/១២០៧/០៣០ចុះថ្ងៃទី៨,ធ្នូ,២០០៧។

[៨០] មាត្រា ៦៦ នៃច្បាប់ភូមិបាល ឆ្នាំ ២០០១,លេខនស/រកម/០៨-០១/ចុះថ្ងៃទី៣០,សីហា,២០០១។

[៨១] មាត្រា ១៧ , ក្រមរដ្ឋប្បវេណី,លេខនស/រកម/១២០៧/០៣០ ចុះថ្ងៃទី៨, ធ្នូ, ២០០៧។

សន្យាលក់ទិញខណៈដែលសមត្ថភាព នៃបុគ្គលនោះចុះអន់ថយខ្លាំងដូចដែលបានពន្យល់ខាងលើនេះ

សរុបសេចក្តីមក បុគ្គលដែលស្ថិតក្នុងស្ថានភាពខ្វះសមត្ថភាព ត្រូវចាត់ទុកជាបុគ្គលដែលច្បាប់មិនទទួលស្គាល់ឆន្ទៈក្នុងការសម្រេចចិត្ត ថាមានសុពលភាពទេ និងអាចលុបចោលកិច្ចសន្យាលក់ទិញនោះបាន ដោយមូលហេតុសមត្ថភាពក្នុងការវិនិច្ឆ័យលទ្ធភាពតាមផ្លូវច្បាប់មានវិការៈ ។

**១.២.៣. បុគ្គលគ្មានសមត្ថភាពធ្វើកិច្ចសន្យា**

ផ្អែកតាមការបកស្រាយសមត្ថភាពទាក់ទង និងការធ្វើកិច្ចសន្យានៃបុគ្គលទាំងពីរខាងលើមានលក្ខខណ្ឌខុសប្លែកគ្នា ដោយបុគ្គលទី១ច្បាប់បដិសេធក្នុងការផ្តល់សិទ្ធិធ្វើកិច្ចសន្យាលក់ទិញអចលនវត្ថុ ឬ ឯបុគ្គលទី២ ជាបុគ្គលមានសមត្ថភាពពេញលេញធ្វើកិច្ចសន្យា តែត្រូវបានសន្មត់ថាខ្វះសមត្ថភាពខណៈដែលការវិនិច្ឆ័យតាមផ្លូវច្បាប់ចុះអន់ថយជាខ្លាំង។ ដោយឡែកបុគ្គលទី៣ក៏ជាបុគ្គលដែលច្បាប់បញ្ញត្តិថាគ្មានសមត្ថភាពធ្វើកិច្ចសន្យាដែរ ដោយមូលហេតុនៃអាយុ វិបត្តិផ្នែកស្មារតីខ្វះសមត្ថភាពយល់ដឹង នឹងវិនិច្ឆ័យលទ្ធភាពតាមផ្លូវច្បាប់ជាដើម ។ ចំពោះអនីតិជន ជនស្ថិតនៅក្រោមអាព្យាបាលទូទៅ និង ជនស្ថិតក្រោមហិតូបត្ថម្ភត្រូវចាត់ទុកថា ជាបុគ្គលគ្មានសមត្ថភាពធ្វើកិច្ចសន្យា ហើយអាចលុបចោល-លកិច្ចសន្យានោះវិញ ។

**ក. ចំពោះអនីតិជន**

ការទិញនំចំណី ឬ វត្ថុប្រើប្រាស់រាល់ថ្ងៃកំប៉ិកកំប៉ុកជាអាទិ៍ ដែលជាសកម្មភាពទាក់ទង និងជីវ-ភាពរស់នៅប្រចាំថ្ងៃ គឺត្រូវប្រគល់ឲ្យអនីតិជនជាអ្នកសម្រេច[៨២]។ ចំពោះបញ្ញត្តិពិសេសខ្លះៗមានជាអាទិ៍ការចាត់ចែងទ្រព្យសម្បត្តិ[៨៣] និងការប្រកបអាជីវកម្មដោយឯករាជ្យ[៨៤]។ ដែលទទួលបានការយល់ព្រមពីអ្នកមានសិទ្ធិអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនត្រូវចាត់ទុកថា មានសុពលភាពពេញលេញក្នុងទំហំនៃការផ្តល់ឲ្យ។ ប៉ុន្តែ ចំពោះករណីដែលអនីតិជនជាអ្នកនៅក្រោមអាណា-ព្យាបាលទូទៅ ទោះបីមានការយល់ព្រមពីអ្នកមានសិទ្ធិយល់ព្រមក៏ដោយ ក៏សកម្មភាពរបស់អនីតិជននោះអាចលុបចោលបានដែរ[៨៥]។

ជាគោលការណ៍សកម្មភាពធ្វើកិច្ចសន្យាលក់ទិញអចលនវត្ថុ ត្រូវធ្វើឡើងដោយសមត្ថជនដែលមានសមត្ថភាពឯករាជ្យខាងអំពើទើបកិច្ចសន្យាមានអានុភាពអនុវត្តចំពោះភាគី នៃកិច្ចសន្យា។ ប៉ុន្តែក្នុង

---

[៨២]មាត្រា ១៤ , ក្រមរដ្ឋប្បវេណី,លេខនស/រកម/១២០៧/០៣០ ចុះថ្ងៃទី៨, ធ្នូ, ២០០៧។

[៨៣]មាត្រា១៩, ក្រមរដ្ឋប្បវេណី,លេខនស/រកម/១២០៧/០៣០ ចុះថ្ងៃទី៨, ធ្នូ, ២០០៧។

[៨៤]មាត្រា២០,ក្រមរដ្ឋប្បវេណី,លេខនស/រកម/១២០៧/០៣០ ចុះថ្ងៃទី៨, ធ្នូ, ២០០៧។

[៨៥]មាត្រា ២៦ , ក្រមរដ្ឋប្បវេណី,លេខនស/រកម/១២០៧/០៣០ ចុះថ្ងៃទី៨, ធ្នូ, ២០០៧។

ករណីនេះអនីតិជនក៏អាចធ្វើកិច្ចសន្យាបានដែលតាមរយៈអ្នកតំណាង ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬ ក៏អនីតិជនសាមីខ្លួន ។

ឧទាហរណ៍ ៖ ការបង្កើតកិច្ចសន្យាទទួលប្រទានកម្មដោយពុំមានបន្ទុក[៨៦]។ សកម្មភាពដែលទទួលសិទ្ធិបែបនេះ ជាកិច្ចសន្យាមានសុពលភាពពេញលេញដោយវា ជាសកម្មភាពផ្តល់ផលប្រយោជន៍ខាងផ្នែកសេដ្ឋកិច្ចដល់អនីតិជន ។

### ខ. ចំពោះជននៅក្រោមអាណាព្យាបាលទូទៅ

ជាទូទៅដើម្បីឲ្យជនណាមួយស្ថិតនៅក្រោមអាណាព្យាបាលទូទៅ ច្បាប់បញ្ញត្តិឲ្យមានការដាក់ពាក្យសុំឲ្យប្រកាសអាព្យាបាលទូទៅពីសាមីខ្លួន សហព័ទ្ធ ញាតិស្ថិតក្នុង ៤ (បួន) ថ្នាក់ អ្នកអាណាព្យាបាលសម្រាប់អនីតិជន អ្នកត្រួតពិនិត្យ អ្នកអាណាព្យាបាលសម្រាប់អនីតិជនហិតូបត្ថម្ភកៈ មេឃុំ ឬ ចៅសង្កាត់នៃលំនៅស្ថានរបស់ជននោះ ឬ តំណាងអយ្យការជាអាទិ៍ ទៅតុលាការដើម្បីតុលាការពិនិត្យមើលស្ថានភាពវិនិច្ឆ័យប្រកាសអាណាព្យាបាលទូទៅ ដោយមានរួមបញ្ចូលសមាសភាពអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលទូទៅ។ ការដាក់ពាក្យសុំនោះអាចធ្វើទៅបានលុះត្រាតែជនដែលបានសុំឲ្យប្រកាសអាណាព្យាបាលទូទៅនោះ ជាជនស្ថិតក្នុងស្ថានភាពជានិរន្តខ្វះសមត្ថភាពក្នុងការយល់ដឹង និងវិនិច្ឆ័យដោយសារតែវិបត្តិផ្នែកបញ្ញាស្មារតី និងជាអនីតិជនមានអាយុយ៉ាងតិច ១៥ ឆ្នាំ[៨៧]។

ឧទាហរណ៍ ៖ ជនដែលមិនអាចទៅទិញឥវ៉ាន់ប្រចាំថ្ងៃដោយខ្លួនឯងបានជនដែលមិនអាចដឹងអ្វីៗកើតឡើង ជារៀងរាល់ថ្ងៃ (ឈ្មោះ គ្រួសារ ទីកន្លែង ដែលខ្លួនរស់នៅជាដើម) និងជនដែលធ្លាក់ក្នុងស្ថានភាពជាមនុស្សរុក្ខជាតិ (ស្ថានភាពស្លាប់ខួរក្បាល) ។ រាល់សកម្មភាពដែលកើតចេញពីជនទាំងនេះច្បាប់បានកំណត់ ថាគ្មានសុពលភាពអាចលុបចោលបានទោះបីក្នុងទំហំមានការអនុញ្ញាតពីអាណាព្យាបាលទូទៅក៏ដោយលើកលែងតែសកម្មភាពទាក់ទង និងជីវភាពរស់នៅប្រចាំថ្ងៃ [៨៨]។ ចំណែកឯការលុបចោលការប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅ និងត្រូវបានអនុញ្ញាតប្រសិនបើខ្វះសមត្ថភាពខាងឆន្ទៈរបស់ជននោះ មានស្ថានភាពល្អឡើងវិញព្រមទាំងមានការដាក់ពាក្យសុំ លុបចោលការប្រកាសចាប់ផ្តើមអាព្យាបាលទូទៅពីសាមីខ្លួន ឬពីគ្រួសារ[៨៩]។

ក្រោយពីធ្វើការពន្យល់អំពីជននៅក្រោមអាព្យាបាលទូទៅរួចមក យើងអាចសន្និដ្ឋានបានថាជន

[៨៦]មាត្រា៥៦៥ ឡើងទៅ, ក្រមរដ្ឋប្បវេណី,លេខនស/រកម/១២០៧/០៣០ ចុះថ្ងៃទី៨, ធ្នូ, ២០០៧។

[៨៧] មាត្រា ២៤ , ក្រមរដ្ឋប្បវេណី,លេខនស/រកម/១២០៧/០៣០ ចុះថ្ងៃទី៨, ធ្នូ, ២០០៧។

[៨៨]មាត្រា២៦, ក្រមរដ្ឋប្បវេណី,លេខនស/រកម/១២០៧/០៣០ ចុះថ្ងៃទី៨, ធ្នូ, ២០០៧។

[៨៩]មាត្រា២៧,ក្រមរដ្ឋប្បវេណី,លេខនស/រកម/១២០៧/០៣០ ចុះថ្ងៃទី៨, ធ្នូ, ២០០៧។

ដែលស្ថិតក្នុងស្ថានភាពបែបនេះ គឺគ្មានសមត្ថភាពក្នុងការធ្វើសកម្មភាព ឬ ធ្វើកិច្ចសន្យាណាមួយបានទេក្រៅពីសកម្មភាពទាក់ទង និងជីវភាពរស់នៅប្រចាំថ្ងៃ ។ យោងតាមរបបអាណាព្យាបាលទូទៅរាល់សកម្មភាពដែលធ្វើឡើងដោយជននៅក្រោមអាណាព្យាបាលទូទៅ អាចលុបចោលបានទោះបីមានការអនុញ្ញាតពីអ្នកអាណាព្យាបាលទូទៅក៏ដោយ ក៏ចាត់ទុកថាគ្មានសុពលភាពដែរ ។

### គ. ចំពោះជននៅក្រោមហិតូបត្ថម្ភ

របបហិតូបត្ថម្ភត្រូវបានផ្ដល់ឲ្យជនដែលមានសមត្ថភាពតិចតួចពេកក្នុងការយល់ដឹង និងវិនិច្ឆ័យដោយសារវិបត្តិផ្នែកស្មារតី[៩០] តាមរយៈពាក្យសុំពីសាមីខ្លួន សហព័ទ្ធ ញាតិដែលស្ថិតក្នុង ៤ (បួន) ថ្នាក់ អាណាព្យាបាល អ្នកត្រួតពិនិត្យអាណាព្យាបាល មេឃុំ ឬ ចៅសង្កាត់ នៃលំនៅឋានរបស់ជននោះ ឬ តំណាងអយ្យការដើម្បីដាក់ជូនតុលាការពិនិត្យនៅស្ថានភាព និង វិនិច្ឆ័យអំពីការចាប់ផ្ដើមហិតូបត្ថម្ភ ព្រមទាំងធ្វើការជ្រើសតាំងជនដែលសមស្របធ្វើជាហិតូបត្ថម្ភកៈ ហើយពុំនូវការដាក់កំហិតអាយុជនស្ថិតនៅក្រោមហិតូបត្ថម្ភ ក្នុងការដាក់ពាក្យសុំដូចជននៅក្រោមអាណាព្យាបាលទូទៅនោះទេ[៩១]។ ដោយសារតែជននៅក្រោមហិតូបត្ថម្ភមានស្ថានភាពយល់ដឹង ជាងជននៅក្រោមអាណាព្យាបាលទូទៅពេល គឺអាចទិញរបស់របរសម្រាប់ជីវភាពប្រចាំថ្ងៃ ដូចជា ៖ បាយសម្ល ទឹក របស់របរសម្រាប់លេងតិចតួចកំប៉ិកកំប៉ុក និងអាចធ្វើកិច្ចសន្យាសំខាន់ៗមួយចំនួនដោយឯកឯងបានតែត្រូវមានការយល់ព្រមពីហិតូបត្ថម្ភកៈ បើពុំនោះទេកិច្ចសន្យាអាចលុបចោលបានដោយសាមីខ្លួន ឬ ហិតូបត្ថម្ភកៈ[៩២] ។ម្យ៉ាងវិញទៀត ក្នុងករណីជននៅ ក្រោមហិតូបត្ថម្ភបានវិលមករកស្ថានភាពល្អឡើងវិញនោះការកម្រិតសមត្ថភាព និងការលុបចោលការចាប់ផ្ដើមហិតូបត្ថម្ភអាចធ្វើបានតាមរយៈអ្នកអាណាព្យាបាលសម្រាប់អនីតិជន និងអ្នកត្រូវពិនិត្យអាណាព្យាបាលសម្រាប់អនីតិជន ជាការគ្រប់គ្រងពីព្រោះពុំមានករណីដែលក្រោម ហិតូបត្ថម្ភផង និងនៅក្រោមអាណាព្យាបាលទូទៅផងនោះទេ ។

ឧទាហរណ៍១ ៖ កុមារី (ង) មានវិបត្តិផ្នែកបញ្ញាស្មារតី មានសមត្ថភាពត្រឹមតែអាចធ្វើសកម្មភាពតិចតួចទាក់ទង នឹងជីវភាពប្រចាំថ្ងៃតែប៉ុណ្ណោះ។ ថ្ងៃមួយហិតូបត្ថម្ភកៈមិននៅផ្ទះ លោកស្រី (ច) បានទៅបបួលកុមារី (ង) ឲ្យផ្ដិតមេដៃយល់ព្រមផ្ទេរសិទ្ធិនៃកម្មសិទ្ធិលើដីស្រែនៅខេត្តកំពតឲ្យទៅលោកស្រី ការផ្ទេរសិទ្ធិលើកម្មសិទ្ធិបែបនេះមិនអាចធ្វើទៅបានទេ ពីព្រោះសកម្មភាពនេះធ្វើឡើងមិនមានការយល់ព្រមពីហិតូបត្ថម្ភកៈ ។

---

[៩០]មាត្រា ២៨ , ក្រមរដ្ឋប្បវេណី,លេខនស/រកម/១២០៧/០៣០ ចុះថ្ងៃទី៨, ធ្នូ, ២០០៧។

[៩១]មាត្រា២៩, ក្រមរដ្ឋប្បវេណី,លេខនស/រកម/១២០៧/០៣០ ចុះថ្ងៃទី៨, ធ្នូ, ២០០៧។

[៩២]មាត្រា៣០,ក្រមរដ្ឋប្បវេណី,លេខនស/រកម/១២០៧/០៣០ ចុះថ្ងៃទី៨, ធ្នូ, ២០០៧។

ឧទាហរណ៍៧ ៖ កម្មវត្ថុដដែលតែអ្នកដែលធ្វើកិច្ចសន្យាជាហិតូបត្ថម្ភក: និងលោកស្រី (ច) ដោយមិនមែន ជាបំណងរបស់ កុមារី (ង) នោះទេ ។ ករណីនេះកិច្ចសន្យាក៏អាចលុបចោលបានដែរ ពីព្រោះថាហិតូបត្ថម្ភក:មិនមែន ជាអ្នកតំណាងដែលច្បាប់បានកំណត់ទេ។ មានន័យថា ហិតូបត្ថម្ភក:មានសិទ្ធិអំណាចផ្តល់នូវការយល់ព្រមចំពោះសកម្មភាព ដែលជននៅក្រោមហិតូបត្ថម្ភមិនអាចធ្វើដោយឯករាជ្យបាន មិនមែនជាការផ្តល់សិទ្ធិអំណាចឲ្យប្រើ ជាអ្នកតំណាងសាមីខ្លួនដូចជា អ្នកមានសិទ្ធិអំណាចមេបា ឬ អាណាព្យាបាលនោះទេ[៩៣]។ យោងតាមការបកស្រាយខាងលើនេះយើងឃើញថាជននៅក្រោមហិតូបត្ថម្ភជាជនមានសមត្ថភាពតិចតួចក្នុងការយល់ដឹងពោល គឺប្រសើជាងជននៅក្រោមអាណាព្យាបាលទូទៅតែបន្តិចប៉ុណ្ណោះ។ ដូច្នោះជននៅក្រោមហិតូបត្ថម្ភត្រូវបានច្បាប់បញ្ញត្តិថា គ្មានសមត្ថភាពក្នុងការធ្វើ កិច្ចសន្យាពិសេសៗដោយខ្លួនឯងបានទេ ត្រូវមានជំនួយពីហិតូបត្ថម្ភក:ក្នុងការយល់ព្រមទើបកិច្ចសន្យា នោះមានសុពលភាពដូចជា កិច្ចសន្យាលក់ទិញអចលនត្ថុជាដើម ។

### ១.២.៤. បុគ្គលដែលមិនអាចក្លាយជាអ្នកលក់បាន

ដោយយោងតាមច្បាប់ភូមិបាល នៃព្រះរាជាណាចក្រកម្ពុជាបានចែងអំពីបុគ្គលដែលមានសញ្ជាតិខ្មែរ និង មានសមត្ថភាពចុះកិច្ចសន្យាអាចលក់ ឬ ទិញទ្រព្យជាអចលនវត្ថុបាន។ មួយវិញទៀត បានកំណត់អំពីបុគ្គលដែលមិនអាចលក់បានមានដូចជា ៖

បុគ្គលដែលមិនមែនជាកម្មសិទ្ធិករនៃទ្រព្យដែលត្រូវលក់

- កម្មសិទ្ធិករនៃទ្រព្យអវិភាគដោយគ្មានការយល់ព្រមពីកម្មសិទ្ធិករ អវិភាគផ្សេងទៀត
- បុគ្គលដែលមានអចលនវត្ថុជាកម្មវត្ថុនៃការរឹបអូស[៩៤]។
- សហាព័ទ្ធមិនអាចលក់ទ្រព្យរួម ឲ្យទៅសហាព័ទ្ធរបស់ខ្លួនបានឡើយ ឬ លក់ឲ្យអ្នកដទៃដោយគ្មានការយល់ព្រមពីសហាព័ទ្ធម្ខាងទៀត[៩៥]។

### ១.២.៥. បុគ្គលដែលមិនអាចក្លាយជាអ្នកទិញបាន

បុគ្គលដែលមិនអាចក្លាយជាអ្នកទិញបាន គឺជាបុគ្គលដែលបានកំណត់នៅក្នុងច្បាប់មានដូចជាអ្នកឲ្យគ្រប់គ្រងទ្រព្យសម្បត្តិតាមច្បាប់ តាមផ្លូវតុលាការ ឬ តាមកិច្ចសន្យា មិនអាចក្លាយជាអ្នកទិញ ឬជាអ្នកទិញដោយការលក់ដោយបង្ខំ នូវទ្រព្យសម្បត្តិដែលខ្លួនបានទទួលភារកិច្ចលក់ដោយផ្ទាល់ខ្លួន ឬតាមរយ:អន្តរការីបានឡើយ។ ចំពោះមន្ត្រីរាជការដែលទទួលបន្ទុកចាត់ការ ការលក់ដោយបង្ខំ ឬទទួល

---

[៩៣]មាត្រា៣០ ,ក្រមរដ្ឋប្បវេណី,លេខនស/រកម/១២០៧/០៣០ ចុះថ្ងៃទី៨, ធ្នូ, ២០០៧។

[៩៤]មាត្រា៦៦, ក្រមរដ្ឋប្បវេណី,លេខនស/រកម/១២០៧/០៣០ ចុះថ្ងៃទី៨, ធ្នូ, ២០០៧។

[៩៥]មាត្រា៦៧,ក្រមរដ្ឋប្បវេណី,លេខនស/រកម/១២០៧/០៣០ ចុះថ្ងៃទី៨, ធ្នូ, ២០០៧។

បន្ទុកគ្រប់គ្រងការលក់ដោយបង្ខំនេះក៏មិនអាចក្លាយជា អ្នកទិញបានដែរ[៩៦]។ ចៅក្រម ព្រះរាជអាជ្ញា ក្រឡាបញ្ជី ឬ មន្ត្រីតុលាការផ្សេងទៀតមិនអាចក្លាយជាអ្នកទិញឬ ជាអ្នកទិញដោយការលក់បង្ខំដោយផ្ទាល់ខ្លួន ឬ តាមរយៈអន្តរការីនូវវត្ថុ ឬ សិទ្ធិដែលជាកម្មវត្ថុនៃវិវាទដែលកំពុងចាត់ការនៅតុលាការដែលខ្លួនបំពេញភារកិច្ចបានទេ ។ ចំណែកឯមេធាវី ឬ សារការីក៏មិនអាចក្លាយជាអ្នកទិញ ឬជាអ្នកទិញដោយការលក់ដោយបង្ខំនូវវត្ថុ ឬ សិទ្ធិដែលទាក់ទងនឹងរឿងក្តីដែលខ្លួនទទួលបន្ទុកនោះបានទេ[៩៧]។

អាណាព្យាបាលមិនអាចទិញរបស់កូនកំព្រា ជាអនីតិជនដែលស្ថិតនៅក្រោមអាណាព្យាបាលរបស់ខ្លួនបានទេ ។ ហិតូបត្ថម្ភកៈមិនអាចទិញទ្រព្យដែលខ្លួនគ្រប់គ្រង ។

### ១.៣. កម្មវត្ថុ

កម្មវត្ថុនៃកិច្ចសន្យា គឺជាលក្ខខណ្ឌដ៏សំខាន់មួយដើម្បីឲ្យកិច្ចសន្យាលក់ទិញអចលនវត្ថុមានសុ-ពលភាព។

ក្រៅពីការព្រមព្រៀង និងសមត្ថភាព ដែលជាលក្ខខណ្ឌគ្រឹះក្នុងការបង្កើតកិច្ចសន្យា កម្មវត្ថុក៏ជាធាតុសារវន្តមួយផងដែរ ក្នុងចំណោមលក្ខខណ្ឌគ្រឹះដែលធ្វើឲ្យកិច្ចសន្យាអាចបង្កើតឡើងបាន ។ កម្មវត្ថុត្រូវបានកំណត់ ជាលក្ខខណ្ឌតម្រូវសម្រាប់សុពលភាពក្នុងការបង្កើតកិច្ចសន្យា ។

ទស្សនៈនីតិវិទូ ជាច្រើនបានផ្តល់ទ្រឹស្តីអំពី កម្មវត្ថុនៃកិច្ចសន្យា ជាពីរអត្ថន័យផ្សេងគ្នា ។ ទ្រឹស្តីទីមួយ ផ្តល់និយមន័យថា **កម្មវត្ថុនៃកិច្ចសន្យា** គឺជាកម្មវត្ថុនៃកាតព្វកិច្ចដែលជាតាវកាលិក និងកម្មវត្ថុនៃតាវកាលិក ជាវត្ថុដែលជាប់នឹងតាវកាលិកនោះ ។ ផ្ទុយទៅវិញ ទ្រឹស្តីទីពីរផ្តល់និយមន័យថា **កម្មវត្ថុនៃកិច្ចសន្យា** សំដៅទៅលើ កាតព្វកិច្ចគតិយុត្តដែលស្វែងរក ដែលចង់បានដោយគូភាគី[៩៨]។ លើសពីនេះទៅទៀតសិទ្ធិប្រត្យក្ស ឬ សិទ្ធិភណ្ឌិត ក៏អាចជាកម្មវត្ថុនៃការលក់បានដែរ តាមរយៈការធ្វើលទ្ធកម្មនៃកម្មសិទ្ធិលើអចលនវត្ថុ ។

ចំពោះកម្មវត្ថុក្នុងកិច្ចសន្យាលក់ទិញអចលវត្ថុ ដាច់ខាតត្រូវតែមិនផ្ទុយនឹងបញ្ញត្តិអនុវត្តដោយបង្ខំ (១.៣.១) មិនត្រូវផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ល្អ (១.៣.២) និងកម្មវត្ថុជាក់លាក់ (១.៣.៣) ។

---

[៩៦]មាត្រា៥២៤ ,ក្រមរដ្ឋប្បវេណី,លេខនស/រកម/១២០៧/០៣០ ចុះថ្ងៃទី៨, ធ្នូ, ២០០៧។

[៩៧]មាត្រា៥២៦ ,ក្រមរដ្ឋប្បវេណី,លេខនស/រកម/១២០៧/០៣០ ចុះថ្ងៃទី៨, ធ្នូ, ២០០៧។

[៩៨]ផ្នែកទី៣ កម្មវត្ថុ នៃជំពូកទី១ ស្ថាបនៈលក្ខខណ្ឌនៃកិច្ចសន្យា (សៀវភៅមេរៀន នីតិកិច្ចសន្យា បោះពុម្ពឆ្នាំ ២០១៣ ដោយ ស្រាស្ត្រាចារ្យ ជិន វណ្ណា៉ សាស្ត្រាចារ្យនីតិពាណិជ្ជ នឹង នីតិរដ្ឋប្បវេណី)។

### ១.៣.១. មិនត្រូវផ្ទុយនឹងបញ្ញត្តិអនុវត្តដោយបង្ខំ

បញ្ញត្តិអនុវត្តដោយបង្ខំ គឺជាបញ្ញត្តិទាំងឡាយណាដែលភាគីនៃកិច្ចសន្យាមិនអាចធ្វើការព្រមព្រៀងផ្ទុយពីបញ្ញត្តិនេះបានឡើយ ជាក់ស្តែងចំពោះកិច្ចសន្យាលក់ទិញអចលនវត្ថុដែលភាគីម្ខាងទទួលករណីយកិច្ចធ្វើអនុប្បទាននូវកម្មសិទ្ធិលើអចលនវត្ថុ ឬ ករណីយកិច្ចធ្វើលទ្ធកម្មនូវសិទ្ធិលើអចលនវត្ថុនឹងមានអានុភាពលុះត្រាតែបានធ្វើលិខិតយថាភូត[៩៩]។ ដូចនេះភាគីនៃកិច្ចសន្យាលក់ទិញអចលនវត្ថុមិនអាចធ្វើការព្រមព្រៀងគ្នាផ្សេងទៀតក្រៅពីបញ្ញត្តិនេះបានឡើយ ។

### ១.៣.២. មិនផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ល្អ

កម្មវត្ថុនៃកិច្ចសន្យាលក់ទិញដែលអាចយកទៅអនុវត្តបាន លុះត្រាតែកម្មវត្ថុនោះស្របនឹងច្បាប់បានកំណត់ ឬ ច្បាប់មិនបានហាមឃាត់ ។ ផ្ទុយទៅវិញកម្មវត្ថុដែលផ្ទុយ និងបញ្ញត្តិដោយបង្ខំ ឬផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ល្អចាត់ទុកជាមោឃៈ[១០០] ។ ទោះបីកិច្ចសន្យាលក់ទិញនោះភាគីនៃកិច្ចសន្យាបានបង្ហាញឆន្ទៈព្រមព្រៀងបង្កើតវាដោយគ្មានវិការៈក៏ដោយ ក៏កិច្ចសន្យានោះត្រូវទុកជាមោឃៈដែរ ។ ឧទាហរណ៍ ៖ កិច្ចសន្យាលក់ទិញទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ការលួចបន្លំឆបោក លក់ទិញទ្រព្យសម្បត្តិដែលជាកម្មសិទ្ធិរបស់អ្នកដទៃ ហើយសកម្មភាពទាំងនេះជនណាក៏អាចអះអាងនូវមោឃៈភាពនៃកិច្ចសន្យានោះបានដែរ[១០១] ។

### ១.៣.៣. កម្មវត្ថុជាក់លាក់

ភាគីនៃកិច្ចសន្យាមានលទ្ធភាពកំណត់កម្មវត្ថុជាក់លាក់ដែលមាននាពេលបច្ចុប្បន្ន និងវត្ថុដែលមាននាពេលអនាគត តាមរយៈលទ្ធភាពក្នុងការធ្វើលទ្ធកម្ម ។ ក្នុងករណី វត្ថុដែលជាកម្មវត្ថុនៃកិច្ចសន្យាបានបាត់បង់ ឬ ខូចខាតទាំងស្រុង ពុំអាចស្រោចស្រង់បាន នោះភាគីអ្នកទិញ អាចទាមទារនូវសំណងខូចខាតពីភាគីអ្នកលក់បាន ដោយសារកំហុសកើតចេញពីភាគីអ្នកលក់ ឬ អាចលុបចោលកិច្ចសន្យានោះបាន[១០២] ។

ឧទាហរណ៍ ៖ លោក (ខ) ធ្វើកិច្ចសន្យាព្រមលក់ផ្ទះមួយល្វែងដែលគាត់កំពុងរស់នៅឲ្យទៅលោក (គ) ។ ផ្ទះមួយល្វែងដែល លោក (ខ) កំពុងរស់នៅ ហៅថា កម្មវត្ថុជាក់លាក់មាននាពេលបច្ចុប្បន្ន។ ត្រូវបានចាត់ទុកជាកម្មវត្ថុជាក់លាក់ដែលមាននាពេលបច្ចុប្បន្ន លុះណាវត្ថុនោះយើងអាចមើល

[៩៩] មាត្រា ៣៣៦ , ក្រមរដ្ឋប្បវេណី,លេខនស/រកម/១២០៧/០៣០ ចុះថ្ងៃទី៨, ធ្នូ, ២០០៧។

[១០០] មាត្រា៣៥៤, ក្រមរដ្ឋប្បវេណី,លេខនស/រកម/១២០៧/០៣០ ចុះថ្ងៃទី៨, ធ្នូ, ២០០៧។

[១០១] មាត្រា៣៥៧,ក្រមរដ្ឋប្បវេណី,លេខនស/រកម/១២០៧/០៣០ ចុះថ្ងៃទី៨, ធ្នូ, ២០០៧។

[១០២] មាត្រា៥៤៥ , ក្រមរដ្ឋប្បវេណី,លេខនស/រកម/១២០៧/០៣០ ចុះថ្ងៃទី៨, ធ្នូ, ២០០៧។

ឃើញមាននាពេលបច្ចុប្បន្ន ។ ខុសពីវត្ថុដែលមាននាពេលអនាគត គឺវត្ថុមិនទាន់កើតមាននាពេលលក់ តែភាគីនៃកិច្ចសន្យាជឿជាក់ថាវានឹងកើតមាននាពេលអនាគត ។

### កថាខណ្ឌទី ២ ៖ លក្ខខណ្ឌទម្រង់

ក្រោយពីបានយល់ដឹងអំពីលក្ខខណ្ឌគ្រឹះរួចរាល់អស់ហើយ នៅក្នុងកិច្ចសន្យាលក់ទិញអចលនវត្ថុក៏នៅមានលក្ខខណ្ឌមួយទៀតដែលយើងត្រូវយល់ដឹង គឺលក្ខខណ្ឌទម្រង់។ ចំពោះលក្ខខណ្ឌទម្រង់នៃកិច្ចសន្យាលក់ទិញអចលនវត្ថុ គឺជាលក្ខខណ្ឌមួយដ៏សំខាន់ដែលធ្វើឲ្យកិច្ចសន្យាមានសុពលភាព និងអាច យកទៅតតាំងជាមួយតតិយជនបាន។ ផ្ទុយមកវិញកិច្ចសន្យាលក់ទិញអចលនវត្ថុមិនអាចធ្វើជាលិខិត- ឯកជន ឬ ដោយផ្ទាល់មាត់បានទេដែលចាំបាច់ត្រូវតែធ្វើឡើងជាលាយលក្ខណ៍អក្សរ ។

ជាគោលការណ៍ ការបង្កើតកិច្ចសន្យាលក់ទិញអាចធ្វើទៅបាន លុះត្រាតែមានការព្រមព្រៀងរវាងភាគីនៃកិច្ចសន្យា។ ជាធម្មតាយើងសង្កេតឃើញថា ការលក់ទិញភាគច្រើនមិនតម្រូវ ឲ្យដាច់ខាតត្រូវធ្វើជាទម្រង់ ឬ លិខិតស្នាមស្នុគស្មាញនោះទេ ។

ឧទាហរណ៍ ៖ លោក (ក) លក់សំបកកង់មួយ ឲ្យទៅកញ្ញា (ខ)។ ជាក់ស្តែងរូបភាពលក់ទិញបែបនេះ មិនចាំបាច់តម្រូវឲ្យសរសេរជាលិខិតស្នាមអ្វីនោះទេ គឺគ្រាន់តែអ្នកទិញប្រគល់ប្រាក់ទៅឲ្យអ្នកលក់បន្ទាប់មកអ្នកលក់បានប្រគល់សំបកកង់នោះទៅឲ្យខ្លួនជាការស្រេច ។

ប៉ុន្តែក្នុងករណីខ្លះ ដូចជាការលក់ទិញអចលនវត្ថុគូភាគីនៃកិច្ចសន្យាចាំបាច់ធ្វើជាទម្រង ឬ លិ-ខិតស្នាមត្រឹមត្រូវទើប ជាការប្រសើរដើម្បីការពារផលប្រយោជន៍ និងបញ្ចៀសជម្លោះដែលអាច និងកើតនៅពេលក្រោយ ។ ចំពោះលក្ខខណ្ឌទម្រង់មានលក្ខខណៈ ៣ (បី) ដែលយើងលើកយកមកនិ-យាយ ៖ លិខិតឯកជន (២.១) លិខិតយថាភូត (២.២) និង ការចុះបញ្ជី (២.៣) ។ ក្នុងចំណោមលក្ខខណ្ឌទាំង៣(បី) ភាគីមានសេរីភាពក្នុងការជ្រើសរើសយកលក្ខណ្ឌមួយណាមកប្រើ ក៏បានដែរសម្រាប់ជាលក្ខខណ្ឌបង្កើតកិច្ចសន្យា[១០៣]។ ក្រៅពីការធ្វើលិខិតជាលាយលក្ខណ៍អក្សរភាគីក៏អាចយកទម្រងផ្សេងទៀត ដូចជា ការប្រគល់ប្រាក់កក់ជាដើម មកធ្វើជាលក្ខខណ្ឌសម្រាប់បង្កើតកិច្ចសន្យាលក់ទិញនេះបានដែរ ។

#### ២.១. លិខិតឯកជន

ការបង្កើតកិច្ចសន្យាលក់ទិញអចលនវត្ថុដូច ដែលបានរៀបរាប់ខាងលើរួចមកហើយថាយើងអាចធ្វើជា លិខិតយថាភូតក៏បាន ឬ ធ្វើជាលិខិតឯកជនក៏បាន ។ ឥឡូវយើងកំណត់ថាភាគីនៃកិច្ចសន្យា

[១០៣]មាត្រា៣៥៦ , ក្រមរដ្ឋប្បវេណី,លេខនស/រកម/១២០៧/០៣០ ចុះថ្ងៃទី៨, ធ្នូ, ២០០៧។

ជ្រើសរើសយកប្រភេទលិខិតឯកជនសម្រាប់ជាលក្ខខណ្ឌបង្កើតកិច្ចសន្យា។ លិខិតឯកជន គឺជាលិខិតទាំងឡាយណាដែលបង្កើតឡើងដោយបុគ្គលឯកជនដោយមានចុះហត្ថលេខាឬស្នាមមេដៃ។ លិខិតប្រភេទនេះងាយប្រឈមនឹងហានិភ័យខ្ពស់ ងាយធ្វើឲ្យភាគីនៃកិច្ចសន្យានោះខាតនូវប្រយោជន៍មិនអាចតតាំងនឹងតតិយជនបានដោយហេតុថា សុពលភាពនៃកិច្ចសន្យាមិនទទួលស្គាល់ដោយច្បាប់។ ដូច្នេះភាគីនៃកិច្ចសន្យាដែលជ្រើសរើសយកលិខិតឯកជនមកបង្កើតកិច្ចសន្យាលក់ទិញអចលនវត្ថុ គឺអាចនឹងទទួលរងការខូចខាតនូវប្រយោជន៍ខ្ពស់ ហេតុនេះ គួរកប្បីជ្រើសរើសប្រភេទលិខិតយថាភូតទើបប្រសើរជាង ។

### ២.២. លិខិតយថាភូត

លិខិតយថាភូត គឺជាលិខិតទាំងឡាយដែលបានធ្វើឡើងតាមទម្រង់ច្បាប់ដែលបានកំណត់ហើយបានធ្វើដោយអាជ្ញាធរមានសមត្ថកិច្ច ក្នុងគោលបំណង់ដើម្បីផ្ទេរកម្មសិទ្ធិនៃអចលនវត្ថុទៅឲ្យបុគ្គលផ្សេងទៀត។ ម្យ៉ាងវិញទៀតកិច្ចសន្យាលក់ទិញអចលនវត្ថុមានអានុភាពនឹងជាលក្ខខណ្ឌក្នុងការតតាំងជាមួយតតិយជនបានគូភាគីត្រូវធ្វើជាលិខិតយថាភូតដូចបានកំណត់ក្នុងមាត្រា ៣៣៦ (ការបង្កើតកិច្ចសន្យាដោយសំណើ និងស្ទីការ) មាត្រា៥១៦ (ការបង្កើតកិច្ចសន្យាលក់ទិញ) និងមាត្រា៥៦២ (អានុភាពនៃការចាត់ចែងហ៊ីប៉ូតែក) នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ ។

### ២.៣. ការចុះបញ្ជី

ជាគោលការណ៍ទូទៅ កិច្ចសន្យាលក់ទិញមានអានុភាពត្រឹមការព្រមព្រៀងក៏ប៉ុន្តែចំពោះកិច្ចសន្យាលក់ទិញអចលនវត្ថុច្បាប់បានកំណត់យ៉ាងជាក់ច្បាស់ត្រូវតែមានការចុះបញ្ជី។ ការចុះបញ្ជីនេះជាលក្ខខណ្ឌចាំបាច់បំផុតដែលអាចឲ្យអ្នកទិញទទួលបានសិទ្ធិ ជាម្ចាស់ពេញលេញនឹងអាចអះអាងតតាំងចំពោះតតិយជនបាន។ ការចុះបញ្ជី គឺជារឿងមួយសំខាន់ទាំងគូភាគី និងរដ្ឋ ព្រោះវានឹងធ្វើឲ្យគូភាគីទទួលបាននូវភាពប្រាកដប្រាជា និងច្បាស់លាស់ក្នុងការអនុវត្តច្បាប់ដោយមិនភ័យព្រួយប្រឈមមុខនិងបញ្ហានៅថ្ងៃក្រោយ រីឯរដ្ឋវិញទទួលបាននូវការបង់ពន្ធ អាចវាយតម្លៃនៃប្រវត្តិដីធ្លីបានដែរ ។

## ផ្នែកទី ២ ៖ ការអនុវត្តកិច្ចសន្យាលក់ទិញអចលនវត្ថុ

បន្ទាប់ពីភាគីនៃកិច្ចសន្យាលក់ទិញអចលនវត្ថុ បានព្រមព្រៀងគ្នាក្នុងការបង្កើតកិច្ចសន្យាលក់ទិញមក វានាំឲ្យមានអានុភាពគតិយុត្តិរវាងអ្នកលក់ និងអ្នកទិញដែលត្រូវមានករណីយកិច្ចមួយចំនួន

ដែលត្រូវបំពេញចំពោះភាគី។ ឥឡូវដល់ពេលដែលត្រូវនិយាយអំពីការអនុវត្តកិច្ចសន្យាហើយ នៅពេលដែលនិយាយអំពីការអនុវត្តកិច្ចសន្យា ជាទូទៅ គឺត្រូវតែមានអានុភាពនៃកិច្ចសន្យា ជាក់ស្តែងក្នុងការអនុវត្តកិច្ចសន្យាលក់ទិញអចលនវត្ថុក៏មានលក្ខណៈដូចគ្នាផងដែរ គឺអនុភាពនៃកិច្ចសន្យា (កថាខណ្ឌទី១) អានុភាពនៃសិទ្ធិផ្សេងៗនៅក្នុងកិច្ចសន្យាលក់ទិញអចលនវត្ថុ (កថាខណ្ឌទី២) និងការតម្កល់ប្រាក់ និងទទួលប្រាក់កក់ថ្លៃអចលនវត្ថុ (កថាខណ្ឌទី៣) ។

## កថាខណ្ឌទី ១ ៖ អានុភាពនៃកិច្ចសន្យា

កិច្ចសន្យាកើតឡើងរវាងឆន្ទៈរបស់មនុស្សពីរនាក់ ឬ ច្រើននាក់បានព្រមព្រៀងគ្នាក្នុងការបង្កើតកិច្ចសន្យាដូចនេះ ការអនុវត្តនៃកិច្ចសន្យានេះមានអានុភាពតែគូភាគីដែលបានព្រមព្រៀងក្នុងកិច្ចសន្យាតែប៉ុណ្ណោះ។ មួយវិញទៀត កិច្ចសន្យានេះក៏មានឥទ្ធិពលខ្លះៗទៅដល់តតិយជនផងដែរដូចជាការដាក់កំហិតទៅលើថៅក្រមនៅពេលមានជម្លោះនៃកិច្ចសន្យាកើតមានឡើងផងដែរ។ ចំពោះអនុភាពនៃកិច្ចសន្យានេះវាមានអានុភាពកិច្ចសន្យារវាងគូភាគី(១.១)និងអានុភាពនៃកិច្ចសន្យាចំពោះតតិយជន(១.២)។

### ១.១. អានុភាពកិច្ចសន្យារវាងគូភាគី

ក្រោយពីភាគីទាំងសងខាងបានចុះកិច្ចសន្យាលក់ទិញហើយ នោះកិច្ចសន្យានេះនឹងមានចំណងគតិយុត្តិរវាងគូភាគី (អ្នកទិញ និងអ្នកលក់) ព្រមទាំងតម្រូវឲ្យគូភាគីអនុវត្តជាដាច់ខាតបើមិនព្រមអនុវត្តនាំឲ្យភាគីនោះទទួលរងនូវទណ្ឌកម្ម ។ ម្យ៉ាងវិញទៀតភាគីនៃកិច្ចសន្យាមិនអាចកែប្រែកិច្ចសន្យាដោយឯកតោភាគីបានឡើយ បន្ទាប់ពីកិច្ចសន្យាលក់ទិញនេះមានសុពលភាព ។

#### ១.១.១. អានុភាពបង្កើតកាតព្វកិច្ចឲ្យភាគីអនុវត្ត

កិច្ចសន្យាកើតចេញពីការព្រមព្រៀងរបស់គូភាគីដូចនេះកិច្ចសន្យា គឺជាច្បាប់របស់គូភាគីពោលគឺអាចអនុវត្តបានតែចំពោះភាគីដែលបានចុះកិច្ចសន្យាតែប៉ុណ្ណោះ។ ម្យ៉ាងវិញទៀតកិច្ចសន្យា គឺជាចំណងគតិយុត្តរវាងគូភាគីមានន័យថា នៅពេលដែលភាគីម្ខាងមិនអនុវត្តតាមកិច្ចសន្យាភាគីម្ខាងទៀតអាចប្តឹងទៅតុលាការដើម្បីបង្ខំឲ្យភាគីម្ខាងទៀតអនុវត្តតាម ឬ មួយក៏តម្រូវបង់សំណងចំពោះការខូចខាតជំនួសឲ្យការធ្វើសកម្មភាពដែលបានសន្យាពីដំបូងទី ។

### ១.១.២. ភាពមិនអាចកែប្រែបាននៃកិច្ចសន្យា

ជាគោលការណ៍ កិច្ចសន្យាមិនអាចត្រូវបានកែប្រែឡើយទោះបីជាក្រោមរូបភាពណាក៏ដោយ ។ ក៏ប៉ុន្តែ រាល់ការកែប្រែអាចមានអានុភាព លុះត្រាតែមានការព្រមព្រៀងរបស់គូភាគីទាំងសងខាង (ស្វ័យភាពខាងឆន្ទៈ) ។ នេះជាគោលការណ៍ដ៏សំខាន់មួយនៅក្នុងកិច្ចសន្យា។ អាស្រ័យហេតុនេះប្រសិនបើគូភាគីបានធ្វើការព្រមព្រៀងយ៉ាងណាក៏ដោយក៏គេត្រូវតែអនុវត្តតាមទោះបីជាស្ថានភាពសេដ្ឋកិច្ចមានការប្រែប្រួលនៅថ្ងៃក្រោយក្តី។ លើកលែងតែមានការព្រមព្រៀងនោះផ្ទុយ និងបទបញ្ញត្តិដោយបង្ខំ។

**អញ្ញត្រកម្ម** ៖ ការកែប្រែកិច្ចសន្យាដោយឯកតោភាគីតាមការព្រមព្រៀង ក្នុងករណីមួយចំនួនដោយមានការព្រមព្រៀងគ្នាជាមុន ការកែប្រែដោយឯកតោភាគីអាចធ្វើទៅកើតតាមផ្លូវច្បាប់។ គូភាគីអាចកំណត់បាននៅក្នុងកិច្ចសន្យារបស់ខ្លួននូវ "ខ" ម្យ៉ាងដែលគេឲ្យឈ្មោះថា **ខវិសោធនកម្ម**។ ក្នុងករណីនេះភាគីខ្លួនឯង ជាអ្នកកំណត់លក្ខខណ្ឌមួយចំនួនអនុញ្ញាតឲ្យភាគីរងគ្រោះណាមួយស្នើសុំធ្វើការកែប្រែកិច្ចសន្យាដោយឯកតោភាគី ដោយផ្អែកលើស្ថានភាពជាក់ស្តែង ហើយបើភាគីម្ខាងទៀតមិនព្រមតាមការស្នើសុំទេខ្លួនមានសិទ្ធិសុំរំលាយកិច្ចសន្យា ក៏ប៉ុន្តែការស្នើសុំនេះត្រូវមាន ហេតុផលគ្រប់គ្រាន់។ ទោះជាគ្មានច្បាប់ចែងក៏ដោយ ក៏គោលការណ៍ស្វ័យភាពខាងឆន្ទៈបានអនុញ្ញាតឲ្យភាគីចុះក្នុងកិច្ចសន្យានូវ "ខ" មួយ ដែលតាមនោះភាគីណាម្នាក់អាចនឹងផ្តាច់កិច្ចសន្យាដោយឯកតោភាគីបាននៅពេលដែលខ្លួនមានបំណងផ្តលជាថ្នូរមកវិញនូវទឹកប្រាក់មួយចំនួនសម្រាប់ភាគីម្ខាងទៀត។

### ១.២. អានុភាពនៃកិច្ចសន្យាចំពោះតតិយជន

ក្រោយពីមានអានុភាពចំពោះភាគីនៃកិច្ចសន្យានោះ កិច្ចសន្យាលក់ទិញនេះ ក៏មានអានុភាពចំពោះតតិយជនមួយចំនួនផងដែរ គឺមានចំពោះចៅក្រម និងចំពោះប្រតិសិទ្ធិ។ ក៏ប៉ុន្តែអានុភាពចំពោះចៅក្រមនេះ មិនសំដៅទៅលើការបង្ខំចៅក្រមឲ្យអនុវត្តទៅតាមខ្លឹមសារដែលគូភាគីបានសន្យាគ្នានោះទេ តែអានុភាពមួយនេះសម្រាប់ការពារនៅពេលមានវិវាទកើតឡើងតែប៉ុណ្ណោះ។

#### ១.២.១. ដាក់កម្រិតចំពោះចៅក្រម

ចៅក្រមមានតួនាទីយ៉ាងសំខាន់នៅក្នុងការប្រតិបត្តិកិច្ចសន្យា ជាពិសេសនៅពេលដែលមានវិវាទកើតឡើង។ ជាគោលការណ៍ចៅក្រមមានសមត្ថកិច្ចធ្វើការបកស្រាយកិច្ចសន្យាក្នុងករណីដែលកិច្ចសន្យានោះ មានន័យមិនច្បាស់លាស់ហើយការបកស្រាយនេះត្រូវតាមទម្លាប់ប្រើ ឬ តាមទំនៀមទម្លាប់នៃទីកន្លែងដែលធ្វើកិច្ចសន្យា ។

ចៅក្រមមិនអាចធ្វើការបកស្រាយកិច្ចសន្យាឲ្យខុសពីឆន្ទៈព្រមព្រៀងរបស់គូភាគីបានទេ ហើយ

ថៅក្រមក៏គ្មានសិទ្ធិក្នុងការកែប្រែនូវ អ្វីដែលគូភាគីបានព្រមព្រៀងគ្នានោះឡើយ។ រាល់ការបកស្រាយកិច្ចសន្យាត្រូវបានធ្វើឡើងជាប្រយោជន៍ដល់ភាគីកូនបំណុល ។

### ១.២.២. អានុភាពនៃកិច្ចសន្យាចំពោះប្រតិសិទ្ធិសាកល

ប្រតិសិទ្ធិ គឺជាបុគ្គលដែលទទួលបន្តនូវសិទ្ធិ និងកាតព្វកិច្ចទូទៅរបស់អ្នកដទៃ។ ចំណែកឯប្រតិសិទ្ធិសាកលនោះ គឺសំដៅទៅលើទាយាទរបស់ភាគីណាមួយនៃកិច្ចសន្យា។ ប្រតិសិទ្ធិសាកលអាចទទួលរងនូវកាតព្វកិច្ចដែលកើតឡើងពីកិច្ចសន្យារបស់ឪពុកម្តាយខ្លួនដែលជាភាគី នៃកិច្ចសន្យាផងដែរ។ តែកាតព្វកិច្ចនេះអាចកើតចេញពីភាគី នៃកិច្ចសន្យាដោយមានការព្រមព្រៀងគ្នា និងកំណត់ក្នុងកិច្ចសន្យាថា ប្រសិនបើភាគីណាមួយក្នុងកិច្ចសន្យាបានជួប និងគ្រោះថ្នាក់អ្វីមួយដែលអាចបណ្តាលឲ្យរងគ្រោះថ្នាក់ដល់ជីវិតនោះទាយាទរបស់ភាគីនោះ ជាអ្នកទទួលបន្ទុក។ ក្នុងករណីនេះទើបទាយាទអាចអនុវត្តកិច្ចសន្យានោះបន្តបាន។ ឧទាហរណ៍ ៖ ភាគីពីរនាក់បានចុះកិច្ចសន្យាលក់ទិញផ្ទះហើយបានសន្យាគ្នានៅក្នុងកិច្ចសន្យានោះថា បើភាគីណាមួយនៃកិច្ចសន្យាទទួលរងនូវគ្រោះថ្នាក់អ្វីមួយនោះនាំឲ្យប្រតិសិទ្ធិសាកលជាអ្នកអនុវត្តបន្តចំពោះកិច្ចសន្យានេះ ។

## កថាខណ្ឌទី ២ ៖ អានុភាពនៃសិទ្ធិផ្សេងៗនៅក្នុងកិច្ចសន្យាលក់ទិញអចលនវត្ថុ

ក្រៅពីសិទ្ធិ និងករណីយកិច្ចភាគីទាំងសង់ខាងមានសិទ្ធិមួយចំនួនផ្សេងក្រៅពីសិទ្ធិខាងលើគឺសិទ្ធិអ្នកតំណាង និងអាណត្តិ។ ឥឡូវដល់ពេលដែលត្រូវនិយាយអំពីសិទ្ធិអ្នកតំណាង និងអាណត្តិបើគ្មានសិទ្ធិនេះទេ វានឹងមានផលវិបាកមួយចំនួនដែលទាក់ទងទៅនឹងរូបវន្តបុគ្គលផ្ទាល់ និងនីតិបុគ្គល (មានក្រុមហ៊ុនសហគ្រាសជាដើម)។ មូលហេតុដែលមានផលវិបាកចំពោះនីតិបុគ្គល ព្រោះនីតិបុគ្គលគឺជាការសន្មត់របស់ច្បាប់។ ចំពោះការចុះកិច្ចសន្យាតាមរយៈអ្នកតំណាង និងអាណត្តិនោះត្រូវលើកពីរចំណុចមកបកស្រាយ ៖ ការចុះកិច្ចសន្យាតាមរយៈអ្នកតំណាង (២.១) និងការចុះកិច្ចសន្យាដោយអាណត្តិ (២.២) ។

### ២.១. ការចុះកិច្ចសន្យាតាមរយៈអ្នកតំណាង

ការតំណាង សំដៅទៅលើទំនាក់ទំនងគតិយុត្តដែលអានុភាពនៃកិច្ចសន្យាត្រូវមានចំពោះម្ចាស់សិទ្ធិផ្ទាល់ ក្នុងករណីដែលអ្នកតំណាងធ្វើកិច្ចសន្យាជាមួយភាគីម្ខាងទៀតដោយបង្ហាញថា ការធ្វើកិច្ចសន្យានោះ គឺធ្វើសម្រាប់តែម្ចាស់សិទ្ធិក្នុងទំហំនៃសិទ្ធិតំណាង[១០៩] ។ អ្នកលក់ និងអ្នកទិញអាចចុះកិច្ច

[១០៩]មាត្រា៣៦៩, ក្រមរដ្ឋប្បវេណី,លេខនស/រកម/១២០៧/០៣០ ចុះថ្ងៃទី៨, ធ្នូ, ២០០៧។

សន្យាដោយខ្លួនឯងបានក្នុងការធ្វើកិច្ចសន្យាលក់ទិញអចលនវត្ថុ ឬ តាមរយៈអ្នកតំណាងរបស់ខ្លួនក្នុងការចុះកិច្ចសន្យាជំនួសដោយធ្វើសកម្មភាពគតិយុត្ត សម្រាប់ភាគីណាមួយដែល បានផ្តល់សិទ្ធិតំណាងនោះក្នុងនាមម្ចាស់សិទ្ធិផ្ទាល់។ ម្យ៉ាងវិញទៀតការចុះកិច្ចសន្យាតាមរយៈអ្នកតំណាងអានុភាព នៃកិច្ចសន្យាលក់ទិញដែលអ្នកតំណាងបានចុះកិច្ចសន្យា ជាមួយភាគីម្ខាងទៀត គឺមានអានុភាពផ្ទាល់ទៅលើម្ចាស់សិទ្ធិតែម្តង។ សិទ្ធិតំណាងកើតមានឡើងដោយកិច្ចសន្យារវាងម្ចាស់សិទ្ធិ និងអ្នកតំណាង ឬដោយបញ្ញត្តិនៃច្បាប់[១០៥] ។

### ២.១.១. ទំហំនៃសិទ្ធិតំណាង

អ្នកតំណាង គឺជាចំណងគតិយុត្តិដែលកើតឡើងរវាងម្ចាស់សិទ្ធិ និងអ្នកតំណាង។ កិច្ចសន្យានេះកើតឡើងដោយឈរលើគោលការណ៍ស្វ័យភាពនៃឆន្ទៈ យើងម្នាក់អាចបង្កើតទំនាក់ទំនងគតិយុត្តិជាមួយគ្នាទៅតាមឆន្ទៈរបស់យើងម្នាក់ៗដោយសេរី។ ប៉ុន្តែវិសាលភាពនៃសកម្មភាពរបស់យើងម្នាក់ៗរមែងមានព្រំដែន ។

ទំហំនៃសិទ្ធិតំណាងត្រូវកំណត់ដោយកិច្ចសន្យា ឬ ត្រូវកើតឡើងដោយបញ្ញត្តិច្បាប់។ ក្នុងករ-ណីដែលសិទ្ធិតំណាងត្រូវកើតឡើងដោយបញ្ញត្តិច្បាប់ទំហំនៃសិទ្ធិតំណាងដោយច្បាប់នោះដែរ។

ឧទាហរណ៍៖ អ្នកតំណាងរបស់អសមត្ថជនឬអាណាព្យាបាលស្របច្បាប់របស់អនីតិជន គឺឪពុកម្តាយ។ ក្នុងករណីដែលសិទ្ធិអ្នកតំណាងកើតឡើងដោយកិច្ចសន្យានោះទំហំនៃសិទ្ធិតំណាងត្រូវកំណត់ដោយកិច្ចសន្យានោះ តែប្រសិនបើទំហំនៃសិទ្ធិតំណាងមិនបានកំណត់ទេ អ្នកតំណាងត្រូវមានសិទ្ធិចំ-ពោះអំពើថែរក្សា និងអំពើកែលម្អ[១០៦]។ ហេតុនេះហើយ អ្នកតំណាងមិនអាចធ្វើអ្វីទៅតាមចិត្តរបស់ខ្លួនបាននោះទេ ប្រសិនបើគ្មានការអនុញ្ញាតពីម្ចាស់សិទ្ធិ។ អ្នកតំណាងអាចចុះកិច្ចសន្យាជាមួយតតិយជនបានតែនៅក្នុងរង្វង់នៃដែនកំណត់មួយ ដែលបានកំណត់នៅក្នុងកិច្ចសន្យាអ្នកតំណាងតែប៉ុណ្ណោះ។ ឧទាហរណ៍៖ កម្មសិទ្ធិករបានប្រគល់សិទ្ធិទៅឲ្យអ្នកតំណាងលក់ដីចំនួន ១ (មួយ) ហិចតាទៅឲ្យលោក "ថា" ។ ចំនួន ១ (មួយ) ហិចតានៅក្នុងឧទារណ៍នេះ គឺជាទំហំដែលអ្នកផ្តល់សិទ្ធិបានកំណត់ទៅឲ្យអ្នកតំណាង។

### ២.១.២. ការរលត់សិទ្ធិតំណាង

បន្ទាប់ពីបានទទួលសិទ្ធិ ជាអ្នកតំណាងឲ្យម្ចាស់សិទ្ធិហើយនោះអ្នកតំណាង និងអាចបាត់បង់សិទ្ធិតំណាងនេះនៅពេលដែលខ្លួនបានបំពេញភារកិច្ចរួចរាល់ ឬ ដោយការរំលត់សិទ្ធិនេះដោយម្ចាស់

[១០៥]មាត្រា៣៦៥,ក្រមរដ្ឋប្បវេណី,លេខនស/រកម/១២០៧/០៣០ ចុះថ្ងៃទី៨, ធ្នូ, ២០០៧។

[១០៦]មាត្រា៣៦៦ ,ក្រមរដ្ឋប្បវេណី,លេខនស/រកម/១២០៧/០៣០ ចុះថ្ងៃទី៨, ធ្នូ, ២០០៧។

សិទ្ធិផ្ទាល់ដោយអ្នកតំណាងមានកំហុស ឬ ដោយមូលហេតុណាមួយ ។

មូលហេតុនៃការរលត់នៃសិទ្ធិតំណាង មានដូចខាងក្រោម ៖

– មរណភាពធនក្ស័យ ឬ ការរំលាយរបស់ម្ចាស់សិទ្ធិ

– មរណភាពធនក្ស័យ ឬ ការកម្រិតនូវសមត្ថភាពក្នុងការធ្វើសកម្មភាពរបស់អ្នកតំណាង ។

– ការបញ្ចប់អាណត្តិកិច្ចសន្យាការងារ ឬ ទំនាក់ទំនងគតិយុត្តផ្សេងទៀតដែលបានប្រគល់សិទ្ធិតំណាង ។

ការតំណាងដែលច្បាប់កំណត់ ត្រូវរលត់ដោយសារមូលហេតុដែលបានកំណត់ក្នុងច្បាប់ ។

## ២.២. ការចុះកិច្ចសន្យាដោយអាណត្តិ

នៅក្នុងក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧ មាត្រា៦៣៧ បានឲ្យនិយមន័យអាណត្តិ សំដៅទៅលើកិច្ចសន្យាមួយដែលភាគីម្ខាង ហៅថាអាណត្តិទាយកប្រគល់សិទ្ធិអំណាចឲ្យភាគីម្ខាងទៀត ហៅថាអាណត្តិគាហក:ធ្វើការចាត់ចែងកិច្ចការដើម្បីអាណត្តិទាយក[១០៧] ។ នៅក្នុងន័យនេះមានន័យថា កិច្ចសន្យាអាណត្តិ គឺជាកិច្ចសន្យាមួយដែលបុគ្គលម្នាក់ដែលមានសិទ្ធិអំណាច (អាណត្តិទាយក) ទទួលបាននូវសិទ្ធិនិងអំណាចដើម្បីធ្វើកិច្ចការងារទាំងឡាយជំនួសអាណត្តិទាយក។ អាណត្តិអាចធ្វើដោយការយកកម្រៃ ឬ មិនយកកម្រៃបាន។ បើពុំបានបង្ហាញឆន្ទៈអំពីការធ្វើដោយយកកម្រៃទេត្រូវសន្មត់ថាជាអាណត្តិដោយមិនយកកម្រៃ[១០៨] ។

### ២.២.១. អានុភាពនៃអាណត្តិ

យោងតាមមាត្រា ៦៣៧ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧ បានចែងថា "អាណត្តិ" សំដៅទៅលើកិច្ចសន្យាមួយ ដែលភាគីម្ខាងហៅថា អាណត្តិទាយកប្រគល់សិទ្ធិអំណាចឲ្យភាគីម្ខាងទៀតហៅថា អាណត្តិគាហក:ធ្វើការចាត់ចែងកិច្ចការដើម្បីអាណត្តិទាយក។

គូភាគីនៃកិច្ចសន្យាលក់ទិញអាចជ្រើសរើសអាណត្តិ ដើម្បីធ្វើការចុះកិច្ចសន្យាជំនួសខ្លួនបាន ហើយអានុភាពរបស់កិច្ចសន្យានេះមានអានុភាពទៅលើអាណត្តិទាយក។ ម្យ៉ាងវិញទៀត អាណត្តិទាយកត្រូវទទួលនូវហានិភ័យដែលទាក់ទង និងសកម្មភាពទាំងនោះ ព្រោះអាណត្តិ គឺភាគីទទួលសិទ្ធិទាំងស្រុងសម្រាប់ធ្វើសកម្មភាពក្នុងនាម និងដើម្បីផលប្រយោជន៍ឲ្យភាគីប្រគល់សិទ្ធិ។

---

[១០៧]មាត្រា៦៣៧,ក្រមរដ្ឋប្បវេណី,លេខនស/រកម/១២០៧/០៣០ ចុះថ្ងៃទី៨, ធ្នូ, ២០០៧។

[១០៨]មាត្រា៦៣៨, ក្រមរដ្ឋប្បវេណី,លេខនស/រកម/១២០៧/០៣០ ចុះថ្ងៃទី៨, ធ្នូ, ២០០៧។

### ២.២.២. ការបញ្ចប់អាណត្តិ

ភាគីនីមួយៗ អាចរំលាយកិច្ចសន្យាអាណត្តិ នៅពេលណាក៏បាន ហើយការរំលាយកិច្ចសន្យាអាណត្តិ មិនមានអានុភាពប្រតិសកម្មនោះទេ ពោលគឺអានុភាពរបស់វាកើតមានឡើងដោយឆ្ពោះទៅអនាគតតែប៉ុណ្ណោះ[១០៩] ។

ក្រៅពីការរំលាយកិច្ចសន្យាអាណត្តិនេះ មានមូលហេតុដែលនាំឲ្យបញ្ចប់កិច្ចសន្យាអាណត្តិមានដូចខាងក្រោម :

- អាណត្តិទាយក ឬ អាណត្តិគាហកបានទទួលមរណភាព
- អាណត្តិទាយក ឬ អាណត្តិគាហកត្រូវមានប្រកាសធនក្ស័យ
- អាណត្តិទាយក ឬ អាណត្តិគាហកដែលជានីតិបុគ្គលបានរលាយ
- អាណត្តិទាយកត្រូវបានទទួលការប្រកាសការចាប់ផ្តើមអាណាព្យាបាលទូទៅ ឬ ប្រកាសចាប់បានហិតូបត្ថម្ភ ។

## កថាខណ្ឌទី៣ ៖ ការតម្កល់ប្រាក់ និងការទទួលប្រាក់កក់ថ្លៃអចលនវត្ថុ

បន្ទាប់ពីបានសិក្សាអំពីអានុភាពនៃកិច្ចសន្យារួចមក ឥឡូវត្រូវយល់ដឹងអំពី ការតម្កល់ប្រាក់កក់ និងការទទួលប្រាក់កក់ថ្លៃអចលនវត្ថុ។ ចំពោះការតម្កល់ប្រាក់កក់ និងការទទួលប្រាក់កក់ថ្លៃអចនវត្ថុនេះ មានពីរ ៖ កាតម្កល់ប្រាក់នៅធនាគារ (៣.១) និងការប្រគល់និងទទួលប្រាក់កក់ (៣.២) ដើម្បីឲ្យការអនុវត្តកិច្ចសន្យាលក់ទិញអចលនវត្ថុមានអនុភាពដល់គូភាគី ។

### ៣.១. ការតម្កល់ប្រាក់នៅធនាគារ

នៅក្នុងករណីដែលភាគីនៃការលក់ទិញមានការបន្លំអំពីហានិភ័យ នៃការបង់ប្រាក់ថ្លៃអចលនវត្ថុពីអ្នកទិញអ្នកលក់អាចធ្វើការចរចារ និងសុំឲ្យអ្នកទិញធ្វើការដាក់តំកល់ប្រាក់ថ្លៃលក់អចលនវត្ថុទៅក្នុងប្រតិបត្តិការណ៍គណនីពិសេសមួយរបស់ធនាគារដែលគេហៅថា គណនីផ្តល់ការទុកចិត្ត (Trust Account)។ គណនីផ្តល់ការទុកចិត្ត (Trust Account) គឺជាប្រតិបត្តិការគណនីពិសេសមួយដែលធនាគារដើរតួនាទី ជាភ្នាក់ងាររក្សាប្រាក់ដែលភាគីបានដាក់ប្រាក់រហូតដល់កាលបរិច្ឆេទ ឬ រហូតដល់គូភាគីបានបំពេញនូវលក្ខខណ្ឌដែលគូភាគីបានកំណត់។ ប្រាក់ដែលបានដាក់តម្កល់នោះនឹងមិនត្រូវបានបើកទេបើទោះបីជាភាគីអ្នកទិញដែលជាអ្នកដាក់ប្រាក់ក៏ដោយ។

---

[១០៩] មាត្រា៦៤៧, ក្រមរដ្ឋប្បវេណី,លេខនស/រកម/១២០៧/០៣០ ចុះថ្ងៃទី៨, ធ្នូ, ២០០៧។

ការប្រើប្រាស់នូវគណនីនេះធ្វើឲ្យអ្នកលក់ទទួលបានសុវត្ថិភាពព្រោះថា នៅពេលដែលអ្នកលក់បានបំពេញកាតព្វកិច្ចផ្ទេរកម្មសិទ្ធិរួចភាគីទាំងពីរ និងជួបគ្នានៅធនាគារហើយ អ្នកលក់គ្រាន់តែធ្វើការប្រគល់នូវលិខិតផ្ទេរកម្មសិទ្ធិទៅឲ្យអ្នកទិញពេលនោះធនាគារ នឹងធ្វើការបើកប្រាក់ក្នុងគណនីឲ្យទៅអ្នកលក់តែម្តង។

### ៣.២. ការប្រគល់ និងទទួលប្រាក់កក់

នៅក្នុងតំណាក់កាលនៃការបង្កើតកិច្ចសន្យាលក់ទិញរវាងភាគីលក់ទិញ អ្នកទិញត្រូវតែប្រគល់នូវប្រាក់កក់ដែលខ្លួនបានព្រមព្រៀង និងសន្យាក្នុងតំណាក់កាលចរចាទៅឲ្យអ្នកលក់នាពេលចុះកិច្ចសន្យា។ ប្រាក់កក់នេះ គឺត្រូវធ្វើឡើងដោយដកនូវចំណែកពីចំនួនថ្លៃលក់អចលនវត្ថុទាំងអស់។ បន្ថែមពីលើនេះ នៅពេលដែលអ្នកទិញប្រគល់នូវប្រាក់កក់អ្នកទិញគួរបង្កើតជាលិខិតឯកជនមួយដែលប្រាប់ពីការបានប្រគល់រួចហើយនូវប្រាក់កក់ទៅឲ្យអ្នកលក់។ ធ្វើនេះដើម្បីយកលិខិតនេះមកបញ្ជាក់ថា អ្នកទិញបានប្រគល់រួចហើយនូវប្រាក់កក់ នឹងជាការបញ្ជាក់អំពីចំនួនប្រាក់កក់ដែលបានបង់ឲ្យទៅអ្នកទិញដើម្បីជាភាពងាយស្រួលទុកជាភស្តុតាងនៅពេលមានវិវាទ ឬ មានការរំលាយកិច្ចសន្យា។

# ជំពូកទី៣
# ដំណាក់កាលផ្ទេរអចលនវត្ថុ (ដោយការលក់ទិញ)

ក្រោយពីឆ្លងកាត់ដំណាក់កាលមុនការចុះកិច្ចសន្យា និងដំណាក់កាលចុះកិច្ចសន្យារួចរាល់អស់មក ឥឡូវឈានដល់ដំណាក់កាលនៃការផ្ទេរអចលនវត្ថុ (ដោយការលក់ទិញ) ។ ដំណាក់កាលផ្ទេរអចលនវត្ថុនេះ គឺជាដំណាក់កាលចុងក្រោយ ដែលគូភាគីធ្វើឡើងនៅក្នុងការផ្ទេរសិទ្ធិកម្មសិទ្ធិ និងសិទ្ធិកាន់កាន់ ឬសិទ្ធិផ្សេងទៀត ទៅឲ្យភាគីអ្នកទិញ ក្រោយពីការចុះកិច្ចសន្យាព្រមព្រៀងលក់ទិញអចលនវត្ថុរួចមក។ ជាញឹកញាប់ នៅក្នុងការលក់ទិញអចលនវត្ថុនៅក្នុងប្រទេសកម្ពុជាសព្វថ្ងៃ គឺទៅលើដីធ្លី និងអគារសហកម្មសិទ្ធិ ដែលនីតិវិធីនៅក្នុងការផ្ទេររវាងអចលនវត្ថុទាំងពីរនេះ គឺមានលក្ខណៈខុសគ្នាបន្តិចបន្តួច។ ដែលយើងនឹងធ្វើការសិក្សាទៅលើការផ្ទេរដីធ្លី (ផ្នែកទី១) និង ការផ្ទេរអគារសហកម្មសិទ្ធិ (ផ្នែកទី២) ។

## ផ្នែកទី១ ៖ ការផ្ទេរដីធ្លី

នៅក្នុងការលក់ទិញដីធ្លីនៅកម្ពុជាសព្វថ្ងៃនេះ មានការលក់ទិញដីធ្លីពីរប្រភេទ គឺការលក់ទិញទៅលើដីមានប័ណ្ណកម្មសិទ្ធិ (កថាខណ្ឌទី១) និងការលក់ទិញដីដែលមានគ្មានប័ណ្ណកម្មសិទ្ធិ ឬភោគៈ (កថាខណ្ឌទី២) ។ ហើយការទិញលក់រវាងដីទាំងពីរនេះ គឺមាននីតិវិធីខុសគ្នា ដោយដីមានប័ណ្ណកម្មសិទ្ធិត្រូវមានការចុះបញ្ជីផ្ទេរកម្មសិទ្ធិ ឬ កាត់ឈ្មោះនៅអង្គភាពសុរិយោដី ប៉ុន្តែចំពោះដីគ្មានប័ណ្ណកម្មសិទ្ធិវិញ គឺការផ្ទេរសិទ្ធិធ្វើនៅអាជ្ញាធរមូលដ្ឋាន និងដឹងឮត្រឹមតែអាជ្ញាធរមូលដ្ឋានតែប៉ុណ្ណោះ។

### កថាខណ្ឌទី១ ៖ ការផ្ទេរដីកម្មសិទ្ធិ

ការផ្ទេរដីកម្មសិទ្ធិ គឺជាការផ្ទេរកម្មសិទ្ធិដែលកើតចេញអំពីការព្រមព្រៀង តាមរយៈកិច្ចសន្យាលក់ទិញ[១១០] ។ ការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុដោយការព្រមព្រៀង មានអានុភាពលុះត្រាតែបានចុះបញ្ជី មានន័យថា ការចុះបញ្ជី គឺជាលក្ខខណ្ឌបង្កើតអានុភាពនៃការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុ[១១១]។ ការអនុវត្តសព្វថ្ងៃ កិច្ចសន្យាលក់ទិញស្ទើរតែទាំងស្រុង ត្រូវបានបង្កើតឡើងតាមរយៈលិខិតឯកជន (កិច្ច-

---

[១១០] មាត្រា៥១៥ ក្រមរដ្ឋប្បវេណី, លេខនស/រកម/១២០៧/០៣០ ចុះថ្ងៃទី៨, ធ្នូ, ២០០៧។

[១១១] មាត្រា១៣៥, ក្រមរដ្ឋប្បវេណី, លេខនស/រកម/១២០៧/០៣០ ចុះថ្ងៃទី៨, ធ្នូ, ២០០៧។

សន្យា ចែងអំពី កម្មវត្ថុ តម្លៃ និងខចែងផ្សេងទៀតដែលទាក់ទងនឹងសិទ្ធិ និងករណីយកិច្ចរបស់អ្នកលក់ និងអ្នកទិញ) បន្ទាប់មកដើម្បីអាចចុះបញ្ជីផ្ទេរកម្មសិទ្ធិបាន ភាគីនៃកិច្ចសន្យាត្រូវផ្តិតមេដៃលើលិខិតមួយដែលរៀបចំដោយមន្ត្រីសុរិយោដីហៅថា លិខិតលក់ផ្តាច់ (ចាត់ទុកជាលិខិតយថាភូតពីព្រោះមានការបញ្ជាក់ពីមន្ត្រីមានសមត្ថកិច្ច) បន្ទាប់មកនឹងចាប់ផ្តើមដំណើរការចុះបញ្ជីផ្ទេរកម្មសិទ្ធិ[១១២]។ នីតិវិធីនៃការចុះបញ្ជីផ្ទេរកម្មសិទ្ធិលើអលចនវត្ថុដោយការលក់ទិញនេះ ដូចជាបុគ្គលដែលដាក់ពាក្យសុំចុះបញ្ជី(១.១) ពាក្យសុំចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិ (១.២) អាជ្ញាធរមូលដ្ឋាន (១.៣) និង ស្ថាប័នមានសមត្ថកិច្ចក្នុងការចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិ (១.៤)[១១៣] ។

### ១.១. បុគ្គលដែលដាក់ពាក្យសុំចុះបញ្ជី

បុគ្គលដែលដាក់ពាក្យសុំចុះបញ្ជី គឺសំដៅទៅលើបុគ្គលមានសិទ្ធិចុះបញ្ជី (អ្នកទិញ) ឬ បុគ្គលមានកាតព្វកិច្ចចុះបញ្ជី (អ្នកលក់) ឬ បុគ្គលផ្សេងទៀតដែលត្រូវប្រើសិទ្ធិចុះបញ្ជី ឬ ត្រូវអនុវត្តកាតព្វកិច្ចចុះបញ្ជី[១១៤]។ អ្នកទិញ ឬបុគ្គលដែលមានសិទ្ធិចុះបញ្ជី គឺសំដៅទៅលើបុគ្គលដែលទទួលប្រយោជន៍ដោ-យផ្ទាល់ពីការចុះបញ្ជី[១១៥] និងអ្នកលក់ ឬបុគ្គលដែលមានកាតួកិច្ចចុះបញ្ជី គឺសំដៅទៅលើបុគ្គលដែលទទួលនូវការប៉ះពាល់ផលប្រយោជន៍ដោយផ្ទាល់ពីការចុះបញ្ជី[១១៦] ត្រូវដាក់ពាក្យសុំចុះបញ្ជីជាលាយលក្ខណអក្សររួមគ្នា ឬ តែភាគីម្ខាង ដោយមានភ្ជាប់មកជាមួយនូវឯកសារភ្ជាប់ដែលចាំបាច់ទៅស្ថាប័នមានសមត្ថកិច្ច គឺរដ្ឋបាលសុរិយោដីថ្នាក់រាជធានីខេត្ត ឬ រដ្ឋបាលសុរិយោដីថ្នាក់ក្រុង ស្រុក ខណ្ឌ ដែលអចលនវត្ថុតាំងនៅ[១១៧] ។ គោលគំនិតនៃ "គោលការណ៍ដាក់ពាក្យសុំរួមគ្នា" គឺសំដៅទៅលើការ

---

[១១២] សៀវភៅសិក្ខាសាលាពីការផ្ទេរអចលនវត្ថុដោយការលក់ទិញឧទ្ទេសនាមដោយ មេធាវីទេព បូផល និងមេធាវីរស់ អម្រិត។

[១១៣] ប្រកាសអន្តរក្រសួងស្តីពីនីតិវិធីនៃការចុះបញ្ជី អំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី ចុះថ្ងៃទី០៣ ខែ ឧសភា ឆ្នាំ ២០១១។

[១១៤] ប្រការ៤ កថា.៥ នៃប្រកាសអន្តរក្រសួងស្តីពីនីតិវិធីនៃការចុះបញ្ជីអំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី ចុះថ្ងៃទី០៣ ខែ ឧសភា ឆ្នាំ២០១១។

[១១៥] ប្រការ៤ កថា.៣ នៃប្រកាសអន្តរក្រសួងស្តីពីនីតិវិធីនៃការចុះបញ្ជី អំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី ចុះថ្ងៃទី០៣ ខែ ឧសភា ឆ្នាំ២០១១។

[១១៦] ប្រការ៤ កថា.៤ នៃប្រកាសអន្តរក្រសួងស្តីពីនីតិវិធីនៃការចុះបញ្ជី អំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី ចុះថ្ងៃទី០៣ ខែ ឧសភា ឆ្នាំ២០១១។

[១១៧] ប្រការ៥ កថា.១ នៃប្រកាសអន្តរក្រសួងស្តីពីនីតិវិធីនៃការចុះបញ្ជី អំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី ចុះថ្ងៃទី០៣ ខែ ឧសភា ឆ្នាំ២០១១។

ដាក់ពាក្យសុំចុះបញ្ជីរួមគ្នារវាងបុគ្គលដែលមានសិទ្ធិចុះបញ្ជី និងបុគ្គលដែលមានកាតព្វកិច្ចចុះបញ្ជី[១១៨]។ ចំណែកឯ ការដាក់ពាក្យសុំតែភាគីម្ខាង ឬ ដាក់ពាក្យសុំដាច់ដោយឡែកពីគ្នា មន្ត្រីចុះបញ្ជីត្រូវធ្វើការស្រាវជ្រាវផ្សេងទៀតក្រៅពីឯកសារដែលភាគីអ្នកដាក់ពាក្យសុំបានដាក់ចូលមក ហើយធ្វើការបញ្ជាក់អំពីខ្លឹមសារនៃការដាក់ពាក្យសុំថាត្រឹមត្រូវឬទេ ដែលការស្រាវជ្រាវបែបនេះអាចចំណាយពេលវេលាយូរហើយដំណើរការនៃការចុះបញ្ជីនឹងមិនអាចប្រព្រឹត្តទៅដោយឆាប់រហ័ស និងដោយរលូននោះទេ[១១៩]។ ដូច្នេះហើយ គោលគំនិតនៃការដាក់ពាក្យសុំរួមគ្នា គឺដើម្បីធានាឲ្យបាននូវភាពត្រឹមត្រូវនៃការដាក់ពាក្យសុំរួមគ្នាផង និងដើម្បីអាចធានាបាននូវភាពឆាប់រហ័សដោយការពិនិត្យជាលក្ខណៈទម្រង់នូវឯកសារ ពាក្យសុំដោយមន្ត្រីចុះបញ្ជីផងដែរ។

ការដាក់ពាក្យសុំចុះបញ្ជីក៏អាចធ្វើឡើងដោយអ្នកតំណាងបានដែរ[១២០] គឺមានន័យថាអ្នកតំណាងអាចដាក់ពាក្យសុំចុះបញ្ជី និងចុះហត្ថលេខាលើលិខិតស្នាមនានាដែលចាំបាច់ក្នុងការសុំចុះបញ្ជី ក្នុងនាម និងក្នុងផលប្រយោជន៍របស់អ្នកទិញ និង/ឬ អ្នកលក់បាន។ អ្នកតំណាងទាំងនោះមាន៣ ដូចជាអ្នកតំណាងរបស់នីតិបុគ្គល ដែលអាចជាអភិបាលក្រុមហ៊ុន អ្នកតំណាងដែលច្បាប់បានកំណត់មានដូចជាអ្នកអាណាព្យាបាលទូទៅ ឪពុកម្តាយ ឬ អាណាព្យាបាលរបស់អនីតិជន និងអ្នកតំណាងដោយអាណត្តិ[១២១] ដែលក្នុងករណីនេះ អាចជាមេធាវី មិត្តភក្តិ ឬ ហិតូបត្ថម្ភកៈ ជាដើម។

### ១.២. ពាក្យសុំចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិ

ពាក្យសុំចុះបញ្ជី អំពីសិទ្ធិប្រត្យក្សលើអចលនវត្ថុ ត្រូវធ្វើជាលាយលក្ខណ៍អក្សរដូចមានចែងក្នុងប្រការ៦នៃប្រកាសអន្តរក្រសួងស្តីពីនីតិវិធីនៃការចុះបញ្ជីអំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី ។ យោងតាមប្រកាសនេះ ទម្រង់នៃពាក្យសុំចុះបញ្ជី គឺមានពីរសណ្ឋានជាទម្រង់ពាក្យសុំទូទៅ និងទម្រង់

[១១៨] ប្រការ១០ កថា.១ នៃប្រកាសអន្តរក្រសួងស្តីពីនីតិវិធីនៃការចុះបញ្ជី អំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី ចុះថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ២០១១។

[១១៩] សៀវភៅសិក្ខាសាលាស្តីពីការផ្ទេរអចលនវត្ថុដោយការលក់ទិញឧទ្ទេសនាមដោយ មេធាវីទេព បូផល និងមេធាវីរស់ អម្រិត ទំព័រ៧។

[១២០] ប្រការ១០ កថា.៤ នៃប្រកាសអន្តរក្រសួងស្តីពីនីតិវិធីនៃការចុះបញ្ជី អំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី ចុះថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ២០១១។

[១២១] ប្រការ២០ នៃប្រកាសអន្តរក្រសួងស្តីពីនីតិវិធីនៃការចុះបញ្ជី អំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី ចុះថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ២០១១។

ពាក្យសុំទៅតាមប្រភេទនៃពាក្យសុំចុះបញ្ជី។

ទម្រង់ពាក្យសុំចុះបញ្ជីទូទៅដូចមានកំណត់នៅក្នុងប្រការ២៦ នៃប្រកាសនេះ ហើយទម្រង់នៃពាក្យសុំទាក់ទងនឹងការផ្ទេរកម្មសិទ្ធិមានកំណត់ក្នុងប្រការ ២៨នៃប្រកាសដដែល ដោយត្រូវសរសេរនូវចំណុចដូចខាងក្រោម៖

– ឈ្មោះប្រទេសជាផ្លូវការ

– បាវចនារដ្ឋបាលសុរិយោដីដែលអចលនវត្ថុតាំងនៅ

– គោលបំណងនៃពាក្យសុំចុះបញ្ជី "ការផ្ទេរកម្មសិទ្ធិទាំងមូល" ឬ " ការផ្ទេរកម្មសិទ្ធិមួយផ្នែក"

– មូលហេតុនៃពាក្យសុំចុះបញ្ជី និងកាលបរិច្ឆេទ ៖ "ការលក់" និង "កាលបរិច្ឆេទនៃកិច្ចសន្យាលក់ទិញ"

– ឈ្មោះ ឬ នាមករណ៍ និងអាស្រ័យដ្ឋានរបស់បុគ្គលមានសិទ្ធិចុះបញ្ជី និងបុគ្គលមានកាតព្វកិច្ចចុះបញ្ជី ៖ ឈ្មោះ ឬ នាមករណ៍, ថ្ងៃខែឆ្នាំកំណើត, ទីកន្លែងកំណើត, អាសយដ្ឋានទីកន្លែងស្នាក់នៅ, និងឈ្មោះ ឬនាមករណ៍របស់ឪពុកម្តាយរបស់បុគ្គលដែលមានសិទ្ធិចុះបញ្ជី និងបុគ្គលដែលមានកាតព្វកិច្ចចុះបញ្ជី"

– អត្តសញ្ញាណនៃអចលនវត្ថុ៖ "អាស្រ័យដ្ឋាននៃទីកន្លែង" និង "លេខប័ណ្ណឬលេខក្បាលដី"

– កាលបរិច្ឆេទនៃការដាក់ពាក្យសុំ ហត្ថលេខា ឬស្នាមម្រាមដៃរបស់បុគ្គលដែលដាក់ពាក្យសុំចុះបញ្ជី និង ឯកសារភ្ជាប់នៅក្នុងពាក្យសុំចុះបញ្ជី

ចំពោះឯកសារភ្ជាប់ជាមួយពាក្យសុំចុះបញ្ជីមានឯកសារសំខាន់ៗដូចជា៖

– ឯកសារដែលបញ្ជាក់អត្តសញ្ញាណរបស់បុគ្គលដែលបានដាក់ពាក្យសុំចុះបញ្ជី (ឧទាហរណ៍ អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន)

– ឯកសារដែលបញ្ជាក់អំពីមូលហេតុនៃការចុះបញ្ជី(ឧ. កិច្ចសន្យាលក់ទិញ និងកាលបរិច្ឆេទ)

– សាលក្រម ឬ សាលដីកាដែលចូលជាស្ថាពរ (ករណីដែលការដាក់ពាក្យសុំធ្វើឡើងដោយបុគ្គលម្ខាងតែម្នាក់ឯង) និង ប័ណ្ណកម្មសិទ្ធិ និង ឯកសារពាក់ព័ន្ធផ្សេងៗទៀតដែលកំណត់ដោយក្រសួងរៀបចំដែនដី នគរូ- បនីយកម្ម និងសំណង់។

### ១.៣. អាជ្ញាធរមូលដ្ឋាន

បន្ទាប់ពីបានបំពេញពាក្យសុំចុះបញ្ជីរួចហើយមកអាជ្ញាធរមូលដ្ឋាន គឺអភិបាលស្រុក-ខណ្ឌ មេ-ឃុំ ចៅសង្កាត់ជាអ្នកបញ្ជាក់លើលិខិតសញ្ញាផ្សេងៗ ដូចជាលិខិតលក់ផ្តាច់ជាអាទិ៍ ហើយក្នុងការបញ្ជា-

ក់នេះអភិបាលស្រុក-ខណ្ឌ ឬ មេឃុំ ចៅសង្កាត់ត្រូវយកចិត្តទុកដាក់ និងទទួលខុសត្រូវលើអត្តសញ្ញា-ណអចលនវត្ថុដែលជាកម្មវត្ថុនៃកិច្ចសន្យា និងអត្តសញ្ញាណគូភាគីនៃកិច្ចសន្យា[១២២] ។

បន្ទាប់ពីបានបញ្ជាក់លើលិខិតសញ្ញារួចហើយ បើលិខិតនោះបញ្ជាក់នៅឃុំសង្កាត់ មេឃុំ ចៅសង្កាត់ត្រូវយកលិខិតនោះទៅចុះក្នុងបញ្ជីមួយហៅថា សៀវភៅចុះលិខិតបញ្ជាក់ គឺត្រូវចុះលេខរៀង និងកាលបរិច្ឆេទនៃប្រតិបត្តិការរួចស្រង់លេខរៀង និងថ្ងៃ ខែ ឆ្នាំ ដាក់លើលិខិតដើមគ្រប់លិខិតបញ្ជាក់ដែលត្រូវប្រគល់ទៅឲ្យភាគីម្នាក់ៗ បន្ទាប់មកត្រូវចុះថ្ងៃ ខែ ឆ្នាំនៃលិខិត ចុះឈ្មោះព្រមទាំងទីលំនៅនៃភាគី ចុះប្រភពនៃលិខិត និងចុះកម្មវត្ថុនៃលិខិត បើលិខិតនោះទាក់ទងនឹងអចលនវត្ថុ សេចក្តីនៃលិ-ខិតត្រូវចម្លងចូលដោយសង្ខេបដាក់ក្នុងបញ្ជិកាមួយទៀត ហៅថា បញ្ជិកានៃលិខិតបញ្ជាក់អចលនវត្ថុសម្រាប់ឃុំ-សង្កាត់នីមួយៗ[១២៣] ។ បើលិខិតបញ្ជាក់អចលនវត្ថុដោយអភិបាលស្រុក-ខណ្ឌត្រូវបញ្ជូនទៅមេឃុំ ចៅសង្កាត់ដែលអចលនវត្ថុនោះស្ថិតនៅ ដើម្បីមេឃុំ ចៅសង្កាត់ចុះសេចក្តីបញ្ជាក់ក្នុងសៀវភៅចុះលិខិតបញ្ជាក់អចលនវត្ថុថែមទៀត[១២៤] ។

## ១.៤. ស្ថាប័នមានសមត្ថកិច្ចក្នុងការចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិ

ស្ថាប័នដែលមានសមត្ថកិច្ចទទួលពាក្យសុំចុះបញ្ជី អំពីសិទ្ធិប្រត្យក្សលើអចលនវត្ថុ គឺរដ្ឋបាលសុរិយោដីថ្នាក់រាជធានី ខេត្ត ឬ រដ្ឋបាលសុរិយោដីថ្នាក់ក្រុង ស្រុក ខណ្ឌតាំងនៅ...ហើយរដ្ឋបាលសុរិ-យោដីថ្នាក់រាជធានី-ខេត្ត ឬ រដ្ឋបាលសុរិយោដីថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវបង្កើតសៀវភៅទទួលពាក្យសុំចុះបញ្ជី អំពីសិទ្ធិប្រត្យក្សលើអចលនវត្ថុដាច់ដោយឡែកពីសៀវភៅទទួលពាក្យសុំផ្សេងៗទៀត... ហើយមួយវិញទៀតនោះរដ្ឋបាលសុរិយោដីថ្នាក់ក្រុង ស្រុក ខណ្ឌ ដែលបានទទួលពាក្យសុំចុះបញ្ជីអំពីសិទ្ធិប្រត្យក្សលើអចលនវត្ថុត្រូវផ្ញើរពាក្យសុំនោះ និងឯកសារពាក់ព័ន្ធទៅរដ្ឋបាលសុរិយោដីថ្នាក់រាជធានី-ខេត្ត ដែលអចលនវត្ថុតាំងនៅដោយគ្មានការយឺតយ៉ាវ [១២៥]។

ស្ថាប័នដែលមានសមត្ថកិច្ចចុះបញ្ជី អំពីសិទ្ធិប្រត្យក្សលើអចលនវត្ថុ គឺរដ្ឋបាលសុរិយោដីថ្នាក់

---

[១២២] ប្រការ៩ ប្រកាសអន្តរក្រសួងស្តីពីតួនាទីនិងការទទួលខុសត្រូវរបស់រដ្ឋបាលឃុំ-សង្កាត់ក្នុងការចុះបញ្ជីដីធ្លី។

[១២៣] ប្រការ១២ ប្រកាសអន្តរក្រសួងស្តីពីតួនាទីនិងការទទួលខុសត្រូវរបស់រដ្ឋបាលឃុំ-សង្កាត់ក្នុងការចុះបញ្ជីដីធ្លី។

[១២៤] ប្រការ១៣ ប្រកាសអន្តរក្រសួងស្តីពីតួនាទីនិងការទទួលខុសត្រូវរបស់រដ្ឋបាលឃុំ-សង្កាត់ក្នុងការចុះបញ្ជីដីធ្លី។

[១២៥] ប្រការ២០ កថា.១ នៃប្រកាសអន្តរក្រសួងស្តីពីនីតិវិធីនៃការចុះបញ្ជី អំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី ចុះថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ២០១១។

រាជធានី ខេត្ត ដែលអចលនវត្ថុតាំងនៅ[១២៦] ។ នៅពេលដែលពាក្យសុំត្រូវបានដាក់ទៅរដ្ឋបាលសុរិយោ-ដីថ្នាក់រាជធានី ខេត្តដែលជាស្ថាប័នមានសមត្ថកិច្ចចុះបញ្ជីសិទ្ធិប្រត្យក្សលើអចលនវត្ថុ ត្រូវចុះលេខរៀងទៅតាមលំដាប់នៃការទទួលពាក្យសុំ [១២៧]។ សៀវភៅទទួលពាក្យសុំចុះបញ្ជី អំពីសិទ្ធិប្រត្យក្សលើអចល-នវត្ថុ គឺត្រូវបង្កើតដាច់ដោយឡែកពីសៀវភៅទទួលពាក្យសុំផ្សេងៗទៀត ហេតុដូច្នេះ រដ្ឋបាលសុរិយោដីរាជធានី ខេត្ត ដែលមានសមត្ថកិច្ចចុះបញ្ជី ត្រូវធ្វើការចុះបញ្ជីក្នុងសៀវភៅចុះបញ្ជី ដែលពាក់ព័ន្ធ[១២៨] ។

ហើយបន្ទាប់មក ពិនិត្យឃើញថានីតិវិធីត្រឹមត្រូវហើយ អាជ្ញាធរតម្រូវឲ្យមានការបងពន្ធទៅលើការផ្ទេរហ្នឹង។ អ្នកស្នើសុំឲ្យធ្វើការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុនេះ ត្រូវធ្វើការបង់ពន្ធទៅលើការផ្ទេរកម្មសិទ្ធិលើដីដែលជាកម្មវត្ថុនៃការលក់នេះ[១២៩] ។ ហើយកិច្ចការប្រថាប់ត្រា និងការប្រមូលពន្ធប្រថាប់ត្រា គឺជាសមត្ថកិច្ចរបស់អង្គភាពពន្ធក្រោមការគ្រប់គ្រង និងដឹងនាំផ្ទាល់របស់ក្រសួងហិរញ្ញវត្ថុ[១៣០] ។ មន្ត្រីពន្ធដារាជធានី-ខេត្តធ្វើការពិនិត្យវាយតម្លៃអចលនវត្ថុនោះ ហើយបន្ទាប់មកទៀតត្រូវប្រថាប់ត្រា (បង់ ពន្ធ) ទៅលើការផ្ទេរកម្មសិទ្ធិ ហើយពន្ធដែលត្រូវបង់នោះត្រូវបង់៤%[១៣១] នៃតម្លៃអចលនវត្ថុនោះ ក្រោយ ពីបង់ពន្ធហើយ ខាងពន្ធដារាជធានី-ខេត្តនឹងចេញបង្កាន់ដៃមួយដែលបញ្ជាក់ពីការបង់ពន្ធហ្នឹង ទើប យើងយកបង្កាន់ដៃនោះទៅបង្គ្រប់នីតិវិធីនៅមុខអាជ្ញាធរសុរិយោដី ដែលបន្ទាប់ពីបានឯកសារនោះហើយ រដ្ឋបាលសុរិយោដីរាជធានី-ខេត្តនឹងចារថាអ្នកទិញជាម្ចាស់អចលនវត្ថុចាប់ពីពេលនោះតទៅ[១៣២]។

---

[១២៦] ប្រការ២០ កថា.២ នៃប្រកាសអន្តរក្រសួងស្តីពីនីតិវិធីនៃការចុះបញ្ជី អំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី ចុះថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ២០១១។

[១២៧] ប្រការ៧ កថា.១ នៃប្រកាសអន្តរក្រសួងស្តីពីនីតិវិធីនៃការចុះបញ្ជី អំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី ចុះថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ២០១១។

[១២៨] ប្រការ៦ កថា.៣ នៃប្រកាសអន្តរក្រសួងស្តីពីនីតិវិធីនៃការចុះបញ្ជី អំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី ចុះថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ២០១១។

[១២៩] មាត្រា៩, អនុក្រឹត្យស្តីពីការប្រមូលពន្ធប្រថាប់ត្រា, លេខ២០ អនក្រ/២១កញ្ញា ១៩៩១។

[១៣០] មាត្រា២ ,ច្បាប់ស្តីពីការបង្កើតពន្ធប្រថាប់ត្រា ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ១៩៩១។

[១៣១] ប្រការ៦,នៃប្រកាសស្តីពីការប្រមូលពន្ធប្រថាប់ត្រា ,លេខ៧៣៧ សហវ-ប្រក-អពជ, ចុះថ្ងៃទី ៨ ខែ សីហា ឆ្នាំ២០១៣។

[១៣២] សម្ភីរបស់លោក មេធាវី ប៊ុន យូឌី ដែលធ្វើបទសម្ភាស៍នៅវិទ្យុបារាំងនៅថ្ងៃទី២៣ខែ ឧសភា ២០១៣។

## កថាខណ្ឌទី២ ៖ ការផ្ទេរដីគ្មានប័ណ្ណកម្មសិទ្ធិ

ចំពោះការផ្ទេរដីគ្មានប័ណ្ណកម្មសិទ្ធិ ឬ ហៅថាប្លង់ទន់ គឺមិនមាននីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិនៅរដ្ឋបាលសុរិយោដីដូចដីដែលមានប័ណ្ណកម្មសិទ្ធិនោះទេ ដោយសារតែដីប្រភេទនេះមិនទាន់មានការចុះបញ្ជីនៅក្នុងសៀវភៅគោលបញ្ជីដីនៅឡើយទេ ដូច្នេះចំពោះការលក់ទិញអចលនវត្ថុប្រភេទនេះ ត្រូវបានធ្វើការផ្ទេរសិទ្ធិកាន់កាប់ត្រឹមតែអាជ្ញាធរមូលដ្ឋានដែលអចលនវត្ថុនោះតាំងនៅតែប៉ុណ្ណោះ។ បើយោងតាមក្រមរដ្ឋប្បវេណីមាត្រា២២៩ កថាខណ្ឌទី២,៣,៤ ការផ្ទេរការកាន់កាប់អាចត្រូវបានផ្ទេរ ដោយការព្រមព្រៀងគ្នារវាងគូភាគី។

### ២.១. គូភាគី ឬ ភោគី

ភោគី ឬ អ្នកកាន់កាប់ដីដោយស្របច្បាប់ ក៏មានសិទ្ធិក្នុងការលក់ដីធ្លីរបស់ខ្លួនដែរ ទៅឲ្យអ្នកទិញ ហើយអ្នកដែលទទួលដីធ្លីនោះ គឺទទួលបានត្រឹមតែសិទ្ធិជាភោគីដដែលមិនមែនជាម្ចាស់កម្មសិទ្ធិនោះទេ។ ដូច្នេះភោគី ឬ អ្នកលក់ អាចបង្កើតកិច្ចសន្យាលក់ទិញអចលនវត្ថុជាមួយអ្នកទិញបាន។ បន្ទាប់ពីភាគីជាអ្នកលក់ និងអ្នកទិញបានធ្វើការព្រមព្រៀងគ្នាទាក់ទងទៅនឹងតម្លៃ កម្មវត្ថុនៃកិច្ចសន្យា និងលក្ខខណ្ឌផ្សេងៗរួចរាល់ហើយ ពេលនោះកិច្ចសន្យានៃការលក់ទិញអលចនវត្ថុ (ដីគ្មានប័ណ្ណកម្មសិទ្ធិ) នឹងត្រូវបានបង្កើតឡើង ប៉ុន្តែកិច្ចសន្យានេះមិនមានលក្ខណៈពេញលេញតាមផ្លូវច្បាប់នោះទេ ពីព្រោះមិនមែនជាកិច្ចសន្យាយថាភូតនោះទេ គ្រាន់តែជាកិច្ចសន្យាឯកជនតែប៉ុណ្ណោះ។

នៅក្នុងការផ្ទេរអចលនវត្ថុគ្មានប័ណ្ណកម្មសិទ្ធិ គឺធ្វើត្រឹមតែជាលិខិតផ្ទេរសិទ្ធិកាន់កាប់ដីធ្លីតែប៉ុ-ណ្ណោះ នៅចំពោះមុខអាជ្ញាធរដែនដី។

ក្នុងតំណាក់កាលនៃការផ្ទេរសិទ្ធិកាន់កាប់លើអចលនវត្ថុគ្មានប័ណ្ណភាគីជាអ្នកលក់ និងអ្នកទិញត្រូវមានកាតព្វកិច្ចក្នុងការបង្ហាញឯកសារផ្សេងៗ និងបំពេញនូវលិខិតដែលទាក់ទង និងការផ្ទេរសិទ្ធិនេះនៅចំពោះមុខអាជ្ញាធរមូលដ្ឋាន ។ ឯកសារទាំងនោះមានដូចជា៖

<u>កាតព្វកិច្ចអ្នកលក់</u> :

– ប្រគល់ឯកសារផ្ទេរសិទ្ធិកាន់កាប់អលចនវត្ថុ(ច្បាប់ដើម)

– បង្កាន់ដៃសុំប្រើប្រាស់ដីធ្លី

– លិខិតបញ្ជាក់ប្រវត្តិអចលនវត្ថុ

– ធ្វើលិខិតធានាអះអាងថា អចលនវត្ថុមិនមានជាប់ពាក់ព័ន្ធនឹងការជួល ដាក់បញ្ចាំ ឬ ធ្វើអំណោយទានទៅជនណាមួយទេ ពុំមានពាក់ព័ន្ធនឹងទំនាស់ ឬ ដីការតុលាការ និងពុំមានពាក់ព័ន្ធដីសា

ធារណៈ របស់រដ្ឋឡើយ ។ ព្រមទទួលខុសត្រូវទាំងស្រុងចំពោះមុខច្បាប់ បើសិនមានបញ្ហាកើតឡើង និងផ្តិតមេដៃស្តាំទុកជាភស្តុតាង។

– ថតចំលងអត្តសញ្ញាប័ណ្ណ

– ថតចំលងសៀវភៅគ្រួសារ

– ភ្ជាប់ជាមួយនូវកិច្ចសន្យាលក់ទិញ ។

<u>កាតព្វកិច្ចរបស់អ្នកទិញ</u> :

– ត្រួតពិនិត្យឯកសារដែលពាក់ពាក់ព័ន្ធ

– ថតចំលងអត្តសញ្ញាណប័ណ្ណ

– ថតចំលងសៀវភៅគ្រួសារ ។

### ២.២. អាជ្ញាធរមូលដ្ឋាន

បន្ទាប់ពីភាគីបានបំពេញកាតព្វកិច្ចខាងលើ ហើយភាគីទាំងពីរត្រូវផ្តិតមេដៃលើលិខិតផ្ទេរសិទ្ធិកាន់កាប់នៅចំពោះមុខអាជ្ញាធរមូលដ្ឋានមេឃុំ-ចៅសង្កាត់ដែលមានសាក្សីដឹងឮផងដែរ ។ បន្ទាប់មកអាជ្ញាធរមូលដ្ឋាន និងចុះហត្ថលេខាទៅលើលិខិតនោះដើម្បីបញ្ជាក់ស្នាមមេដៃខាងលើពិតជារបស់ភាគីខាងលើមែន ។ សូមបញ្ជាក់ថា រាល់លិខិតស្នាមខាងលើមិនអាចកោសលុប ឬ សរសេរជាន់បានឡើយ ហើយរាល់លិខិតផ្ទេរសិទ្ធិខាងលើនេះត្រូវតំកល់នៅសាលាខណ្ឌមួយដើម្បីទុកជាឯកសារ បន្ទាប់មករាល់សំណុំឯកសារខាងលើត្រូវតម្កល់នៅសាលាខណ្ឌបន្តទៀត ដើម្បី បន្តនីតិវិធី។

បន្ទាប់ពីមានការធ្វើរបាយការហើយនោះមន្ត្រីជំនាញនឹងបញ្ជូនឯកសារនោះ ទៅកាន់គណៈអភិបាលខណ្ឌដើម្បីធ្វើការផ្ទៀងផ្ទាត់ និងចុះហត្ថលេខាសម្រេចទៅលើលិខិតផ្ទេរសិទ្ធិនោះ ចំពោះលិខិតផ្ទេសិទ្ធិ ដែលបានចុះហត្ថលេខាដោយ គណៈអភិបាលរួចហើយមិនមានការតវ៉ា ឬ មិនយល់ព្រមទេនោះ ត្រូវប្រគល់ជូនទៅអ្នកទិញចំនួនមួយច្បាប់ ហើយរក្សាទុកមួយច្បាប់នៅ គណៈអភិបាលដើម្បី-ទុកជាឯកសារ ។

ការចុះហត្ថលេខារបស់អាជ្ញាធរមូលដ្ឋាន ដែលមានមេឃុំ ចៅសង្កាត់ ឬ អភិបាលស្រុក-ខណ្ឌ (ក្នុងករណីដែលគូភាគីលក់ទិញធ្វើការបន្តនីតិវិធីដល់ថ្នាក់ស្រុកខណ្ឌ) នោះគ្រាន់តែជាការចូលរួមក្នុងការជួយត្រួតពិនិត្យ និងជួយដឹងឮអំពីការផ្ទេរសិទ្ធិកាន់កាប់អចលនវត្ថុនោះតែប៉ុណ្ណោះ ។

## ផ្នែកទី២ ៖ ការផ្ទេរអគារសហកម្មសិទ្ធិ

ការផ្ទេរអគារសហកម្មសិទ្ធិក៏មានលក្ខណៈមិនខុសគ្នាប៉ុន្មាន ទៅនឹងការផ្ទេរដីកម្មសិទ្ធិ និងដីភោគៈដែរ ពីព្រោះតែអគារសហកម្មសិទ្ធិក៏វាស្ថិតនៅក្នុងប្រភេទនៃអចលនវត្ថុមួយដែរ។ នៅពេលមានការលក់ទិញអគារសហកម្មសិទ្ធិ គឺត្រូវតែមានការផ្ទេរនូវកម្មសិទ្ធិ និងសិទ្ធិកាន់កាប់មួយចំនួនទៀតពីអ្នកលក់ទៅអ្នកទិញ។ ហើយជាទូទៅការផ្ទេរអគារសហកម្មសិទ្ធិ (ដោយការលក់ទិញ) គឺធ្វើឡើងនៅពេលដែលអ្នកទិញបានបង់គ្រប់តម្លៃនៃចំណែកឯកជន ឬ ផ្ទះ ឬ បន្ទប់ខុនដូនោះ ទៅឲ្យអ្នកលក់ទើបមានការផ្ទេរកើតឡើង។ ប៉ុន្តែអ្នកទិញអាចធ្វើការស្នាក់នៅបាន ទោះបីជាអ្នកទិញមិនទាន់បង់លុយគ្រប់ក្តីប្រសិនបើអគារនោះបានបញ្ចប់ការសាងសង់ហើយ។

នៅក្នុងការផ្ទេរអគារសហកម្មសិទ្ធិ (ដោយការលក់ទិញ) នៅក្នុងប្រទេសកម្ពុជាបច្ចុប្បន្ននេះ គឺត្រូវបានធ្វើឡើងទៅលើអគាសហកម្មសិទ្ធិខ្លះ មានវិញ្ញាបនបត្រសម្គាល់ម្ចាស់ចំណែកឯកជននៃអគារសហកម្មសិទ្ធិ គឺមានន័យថាអគាសហកម្មសិទ្ធិនោះត្រូវបានម្ចាស់ ឬ បុគ្គលអភិវឌ្ឍអចលនវត្ថុបានធ្វើការបំបែកក្បាលដីនៃអគាសហកម្មសិទ្ធិរបស់ខ្លួន និងធ្វើការចុះបញ្ជីចំណែកឯកជននីមួយៗ នៅក្នុងសៀវភៅគោលបញ្ជីចំណែកឯកជននៃអគារសហកម្មសិទ្ធិរួចរាល់ទៅហើយ មុននឹងធ្វើការផ្ទេរ ឬ លក់បន្តទៅឲ្យសហកម្មសិទ្ធិករថ្មី (កថាខណ្ឌទី១) ។ ហើយការផ្ទេរអគារសហកម្មសិទ្ធិ (ដោយការលក់ទិញ) ខ្លះទៀត គឺបានធ្វើឡើងចំពោះអគារសហកម្មសិទ្ធិ ដែលមិនទាន់មានវិញ្ញាបនបត្រសម្គាល់ម្ចាស់ចំណែកឯកជននៃអគារសហកម្មសិទ្ធិនោះនៅឡើយទេ គឺគ្រាន់តែមានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុតែប៉ុណ្ណោះ (កថាខណ្ឌទី២) ។

### កថាខណ្ឌទី១ ៖ ការផ្ទេរអគារសហកម្មសិទ្ធិមានប័ណ្ណ

នៅក្នុងការផ្ទេរអគារសហកម្មសិទ្ធិមានប័ណ្ណ គឺសំដៅទៅលើការចុះបញ្ជីផ្ទេរសិទ្ធិ (កាត់ឈ្មោះ) ពីអ្នកលក់ ឬ បុគ្គលអភិវឌ្ឍអចលនវត្ថុទៅអ្នកទិញ។ ហើយនៅក្នុងច្បាប់ស្តីពីការផ្តល់សិទ្ធិកម្មសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិដល់ជនបរទេសឆ្នាំ ២០១០ ត្រង់មាត្រា៨ បានចែងថា "ការផ្ទេរសហកម្មសិទ្ធិពិសេសដោយការព្រមព្រៀងមិនមានអានុភាពទេ ប្រសិនបើមិនបានចុះបញ្ជីដោយយោងតាមបញ្ញត្តិ នៃច្បាប់ ឬ បទដ្ឋានគតិយុត្តផ្សេងទៀតស្តីពីការចុះបញ្ជី" ។ ហើយបើយោងតាមអនុក្រឹតស្តីពី ការគ្រប់គ្រង និងប្រើប្រាស់អគារសហកម្មសិទ្ធិត្រង់មាត្រា២០បានចែងថា "រាល់ការផ្ទេរសិទ្ធិតាម

រយៈការលក់ ការដូរ ប្រទាន កម្ម និងការបន្តមរតក សហកម្មសិទ្ធិករ ឬ អ្នកទទួលសិទ្ធិត្រូវស្នើធ្វើចរន្តការនូវរាល់ការប្រែប្រួលនោះ នៅរដ្ឋបាលសុរិយោដី ។ ហើយកិច្ចប្រតិបត្តិការក្នុងការផ្ទេរសិទ្ធិនេះត្រូវប្រើរយៈពេល២០ថ្ងៃនៃថ្ងៃធ្វើការយ៉ាងយូរ ។ ហើយអ្នកទទួលសិទ្ធិបន្តមានសិទ្ធិ និងកាតព្វកិច្ចដូចសហកម្មសិទ្ធិករមុនៗដែរ"[១៣៣] ។ មួយវិញទៀតនោះ រាល់ការផ្ទេរសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិត្រូវបង់ថ្លៃសេវាសុរិយោដី និងបង់ពន្ធប្រថាប់ត្រាជូនរដ្ឋតាមច្បាប់កំណត់"[១៣៤] ។

នៅក្នុងនីតិវិធីនៃការផ្ទេរកម្មសិទ្ធិនេះមន្ត្រីជំនាញសុរិយោដី បានដាក់ឲ្យប្រើប្រាស់ជាផ្លូវការទូទាំងប្រទេសនូវលិខិតសញ្ញាពាក់ព័ន្ធនឹងការផ្ទេរអចលនវត្ថុ[១៣៥] មាន៖ លិខិតលក់ផ្តាច់ លិខិតអំណោយផ្តាច់ និងលិខិតចែកដីក្នុងចំណែកដោយព្រមព្រៀងគ្នា។ ដូចនេះលិខិតយថាភូតដែលពាក់ព័ន្ធនឹងការផ្ទេរអចលនវត្ថុតាមរយៈការលក់ទិញ គឺត្រូវយកលិខិតលក់ផ្តាច់ដើម្បីឲ្យភាគីនៃកិច្ចសន្យាត្រូវផ្តិតមេដៃលើលិខិតនោះ និងបន្ទាប់មកនឹងចាប់ផ្តើមដំណើរការចុះបញ្ជីផ្ទេរកម្មសិទ្ធិ។ ការចុះបញ្ជីនេះ គឺជាលក្ខខណ្ឌបង្កើតអានុភាព និងព្រមទាំងការចុះបញ្ជីនេះ គឺជាលក្ខខណ្ឌតតាំងផងដែរ[១៣៦] ។

សម្រាប់នីតិវិធីនៃការចុះបញ្ជីផ្ទេរអចលនវត្ថុ សម្រាប់អគារសហកម្មសិទ្ធិមានវិញ្ញាបនប័ត្រសម្គាល់អចលនវត្ថុ[១៣៧] មានដូចជា៖ អ្នកស្នើសុំចុះបញ្ជី (១.១) រដ្ឋបាលសុរិយោដី ក្រុង ស្រុក ខណ្ឌ (១.២) មេឃុំ ចៅសង្កាត់ ឬ អភិបាលក្រុង ស្រុក ខណ្ឌ (១.៣) សាខាពន្ធដារាជធានី ខេត្ត(១.៤) និងរដ្ឋបាលសុរិយោដីរាជធានី ខេត្ត (១.៥)។

### ១.១. អ្នកស្នើសុំចុះបញ្ជី

អ្នកស្នើសុំចុះបញ្ជីអាចជាអ្នកលក់ និង/ឬ អ្នកទិញ ត្រូវបំពេញពាក្យសុំចុះបញ្ជីចំនួន ២ច្បាប់តាមគំរូដែលបានកំណត់ដោយមន្ទីសុរិយោដី (ក្នុងករណីនេះមានន័យថា អ្នកស្នើសុំចុះបញ្ជីអាចជាអ្នកលក់ ឬ អ្នកទិញសម្រេចទៅលើការព្រមព្រៀងគ្នារវាងគូភាគីទាំងសងខាង)។ ក្រោយពីបំពេញពាក្យសុំចុះ

---

[១៣៣] មាត្រា២០ អនុក្រឹត្តស្តីពីការគ្រប់គ្រងនិងប្រើប្រាស់អគារសហកម្មសិទ្ធិ លេខ១២៦ ចុះថ្ងៃទី១២ សីហា ២០០៩។

[១៣៤] មាត្រា២១កថាខណ្ឌទី៣,អនុក្រឹត្តស្តីពីការគ្រប់គ្រងនិងប្រើប្រាស់អគារសហកម្មសិទ្ធិលេខ១២៦ចុះថ្ងៃទី១២សីហា២០០៩។

[១៣៥] មាត្រា៣ ប្រកាសស្តីពីការអនុញ្ញាតឲ្យជំនាញសុរិយោដីប្រើប្រាស់លិខិតសញ្ញាពាក់ព័ន្ធនឹងការផ្ទេរអចលនវត្ថុ លេខ២៩៦ ប្រក/កសក។

[១៣៦] មាត្រា១៣៥,ក្រមរដ្ឋប្បវេណី, លេខនស/រកម/១២០៧/០៣០ចុះថ្ងៃទី៨, ធ្នូ, ២០០៧។

[១៣៧] កម្រងឯកសារស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់,ចុះខែមិថុនាឆ្នាំ២០១៣។

បញ្ជីរួចរាល់ហើយអ្នកស្នើសុំដដែល ត្រូវដាក់ពាក្យសុំចុះបញ្ជីនៅរដ្ឋបាលសុរិយោដីក្រុង ស្រុក ខណ្ឌ ឬនៅរដ្ឋបាលសុរិយោដីរាជ ធានី ខេត្ត ដែលអចលនវត្ថុតាំងនៅ។ ផងដែរក៏តម្រូវឲ្យមានសាក្សី ចំនួន ២រូបអមមកជាមួយ ហើយអ្នកស្នើសុំអាចស្នើឲ្យរដ្ឋបាលសុរិយោដីក្រុង ស្រុក ខណ្ឌ ជួយរៀបចំឯក-សារដើម្បីអនុវត្តនីតិវិធីនៃការចុះបញ្ជីបាន (ករណីពុំទាន់មានកិច្ចសន្យាលក់ទិញ ឬ ប្រទានកម្ម ឬដូរដោយលិខិតយថាភូត)។ ដើម្បីឲ្យរឹតតែមានភាពច្បាស់លាស់ និងជាក់លាក់អ្នកស្នើសុំអាចភ្ជាប់មក ជាមួយនូវឯកសារចាំចាច់ដូចជា វិញ្ញាបនបត្រសម្គាល់ម្ចាស់ចំណែកឯកជន និងឯកសារពាក់ព័ន្ធផ្សេងទៀត ប្រសិនបើមានជាដើម។

### ១.២. រដ្ឋបាលសុរិយោដី ក្រុង ស្រុក ខណ្ឌ

បន្ទាប់ពីអ្នកស្នើសុំបានដាក់ពាក្យស្នើសុំចុះបញ្ជីរួចរាល់ហើយ រដ្ឋបាលសុរិយោដីក្រុង ស្រុក ខណ្ឌចាប់ផ្តើមធ្វើការពិនិត្យទៅលើអត្តសញ្ញាណនៃអគារសហកម្មសិទ្ធិ ដែលជាកម្មវត្ថុនៃការផ្ទេរ ថាតើអគារសហកម្មសិទ្ធិ ឬ ចំណែកនៃអគារសហកម្មសិទ្ធិនោះ ពិតជាកម្មសិទ្ធិរបស់ភាគីអ្នកលក់ ឬបុគ្គលអភិវឌ្ឍអចលនវត្ថុប្រាកដឬទេ? មានជាប់បន្ទុកណាមួយទេ។ ពិនិត្យឯកសារយោង និងលិខិតរណបផ្សេងៗ។ ហើយបន្ទាប់មកពិនិត្យប័ណ្ណអគារសហកម្មសិទ្ធិ និងផ្ទៀងផ្ទាត់ជាមួយបញ្ជីឯកសារអគាសហាកម្មសិទ្ធិនោះ។ ហើយចុះពិនិត្យអគារសហកម្មសិទ្ធិនោះ (ករណីចាំបាច់) និងព្រមទាំងចុះវាស់បំបែកក្បាលដី (ករណីផ្ទេរដោយបំបែកក្បាលដី) ។ ហើយបន្ទាប់មកធ្វើការតាក់តែងលិខិតសញ្ញាតាមការព្រមព្រៀងរបស់គូភាគី ។ និងបញ្ជូនសំណុំឯកសារទៅមេឃុំ ចៅសង្កាត់ ឬ អភិបាល ក្រុង ស្រុក ខណ្ឌដើម្បីធ្វើការបញ្ជាក់។

### ១.៣. មេឃុំ ចៅសង្កាត់ ឬ អភិបាលក្រុង ស្រុក ខណ្ឌ

បើយោងតាមមាត្រា ២៣៣ នៃច្បាប់ភូមិបាលឆ្នាំ២០០១បានចែងថា "រដ្ឋបាលសុរិយោដីស្រុក/ខណ្ឌ ត្រូវផ្ញើរច្បាប់ចម្លងនៃសម្រង់ឯកសារសុរិយោដីដល់ឃុំ ឬ សង្កាត់ដែលពាក់ព័ន្ធ។ និងព្រមទាំងចែងថា មេឃុំ ឬ ចៅសង្កាត់ត្រូវអនុញ្ញាតឲ្យជនគ្រប់រូបពិគ្រោះយោបល់ ហើយត្រូវរាយការណ៍ទៅរដ្ឋបាលសុរិយោដីស្រុក/ខណ្ឌនូវរាល់ការផ្លាស់ប្តូរដែលទាក់ទងទៅនឹងស្ថានភាពនៃកម្មសិទ្ធិ និងកម្មសិទ្ធិករក្នុងមូលដ្ឋានរបស់ខ្លួន"។ ដូចនេះមេឃុំ ចៅសង្កាត់ ឬ អភិបាលក្រុង ស្រុក ខណ្ឌធ្វើការពិនិត្យសញ្ញាណរបស់គូភាគី និងសាក្សី។ ពិនិត្យខ្លឹមសារលិខិតសញ្ញា ដែលមន្ត្រីសុរិយោដីតាក់តែងលិខិត

បានបំពេញ។ ធ្វើការបញ្ជាក់ និង បញ្ជូនទៅរដ្ឋបាលសុរិយោដី ក្រុង ស្រុក ខណ្ឌ ដើម្បីបញ្ជូនបន្តទៀតទៅរដ្ឋបាលសុរិយោដី រាជធានី ខេត្ត ពិនិត្យផ្ទៀងផ្ទាត់ឡើងវិញ នូវភាពត្រឹមត្រូវ និងភាពគ្រប់គ្រាន់នៃឯកសារ។ និងមន្ត្រីជំនាញរដ្ឋបាល សុរិយោដីរាជធានី ខេត្ត ឲ្យម្ចាស់សំណើបង់ថ្លៃ សេវាសុរិយោដីតាមការកំណត់ដោយប្រកាសរួមលេខ ៩៩៥ សហវ-ប្រក ចុះថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ ២០១២។ និងព្រមទាំងឲ្យភាគីយកទៅបង់ពន្ធប្រថាប់ត្រា (ករណីត្រឹមត្រូវ និងគ្រប់គ្រាន់)។

### ១.៤. ការបង់ពន្ធប្រថាប់ត្រានៅសាខាពន្ធដារាជធានី-ខេត្ត

កិច្ចការប្រថាប់ត្រា និងការប្រមូលពន្ធប្រថាប់ត្រា គឺជាសមត្ថកិច្ចរបស់អង្គភាពពន្ធក្រោមការគ្រប់គ្រង និងដឹងនាំផ្ទាល់របស់ក្រសួងហិរញ្ញវត្ថុ[១៣៨] ។ អ្នកស្នើសុំឲ្យធ្វើការផ្ទេរអចលនវត្ថុនេះត្រូវធ្វើការបង់ពន្ធទៅលើការផ្ទេរកម្មសិទ្ធិលើដីដែលជាកម្មវត្ថុនៃការលក់នេះ[១៣៩]។

មន្ត្រីពន្ធដារាជធានី-ខេត្តធ្វើការពិនិត្យវាយតម្លៃអគារសហកម្មសិទ្ធិ បន្ទាប់មកទៀតត្រូវប្រថាប់ត្រា (បង់ពន្ធ) លើការផ្ទេរ ហើយពន្ធដែលត្រូវបង់នោះត្រូវបង់៤%នៃតម្លៃអចលនវត្ថុ ឬ ចំណែកនៃអគារសហកម្មសិទ្ធិនោះ និងធ្វើការបញ្ជូនសុំណុំឯកសារត្រឡប់មករដ្ឋបាលសុរិយោដីរាជធានី-ខេត្ត ដើម្បីចុះបញ្ជី។

### ១.៥. រដ្ឋបាលសុរិយោដីរាជធានី-ខេត្ត

ក្រោយពីបានបំពេញលក្ខខណ្ឌចប់សព្វគ្រប់អស់មក មន្ត្រីជំនាញរដ្ឋបាលសុរិយោដីរាជធានីខេត្តធ្វើការចុះបញ្ជីផ្ទេរសិទ្ធិ (ផ្ទេរប្តូរឈ្មោះសហកម្មសិទ្ធិករថ្មី)។ ដោយធ្វើបច្ចុប្បន្នភាពលើទិន្នន័យក្នុងកុំព្យូទ័រ ក្នុងសៀវភៅគោលបញ្ជីចំណែកឯកជននៃអគារសហកម្មសិទ្ធិក្នុងប័ណ្ណ និងក្នុងបញ្ជីឯកសារពាក់ព័ន្ធផ្សេងទៀត។ បន្ទាប់មកមន្ត្រីជំនាញរដ្ឋបាល សុរិយោដីរាជធានី-ខេត្ត រៀបចំទុកដាក់ឯកសារ ហើយធ្វើតារាងសម្រង់អចលនវត្ថុ បញ្ជូនជាមួយឯកសារពាក់ព័ន្ធទៅរដ្ឋបាលសុរិយោដីពីរទៀត ដើម្បីធ្វើលេខាចារិក ចរន្តការ (ធ្វើបច្ចុប្បន្នភាព) ឲ្យបានស្របគ្នា។

---

[១៣៨] មាត្រា៩, អនុក្រឹត្យស្តីពីការប្រមូលពន្ធប្រថាប់ត្រា, លេខ២០ អនក្រ/២១កញ្ញា ១៩៩១។

[១៣៩] មាត្រា២ ,ច្បាប់ស្តីពីការបង្កើតពន្ធប្រថាប់ត្រា ចុះថ្ងៃទី០១ ខែ កុម្ភៈ ឆ្នាំ១៩៩១។

## កថាខណ្ឌទី២ ៖ ការផ្ទេរអគារសហកម្មសិទ្ធិគ្មានប័ណ្ណ

យោងតាមក្រមរដ្ឋប្បវេណីមាត្រា២២៩ កថាខណ្ឌទី២, ៣, ៤ ការផ្ទេរការកាន់កាប់អាចត្រូវបានផ្ទេរដោយការព្រមព្រៀងគ្នារវាងគូភាគី។ ការផ្ទេរអគារសហកម្មសិទ្ធិគ្មានប័ណ្ណ គឺសំដៅទៅលើការផ្ទេរអគារសហកម្មសិទ្ធិ ឬ ចំណែកឯកជននៃអគារសហកម្មសិទ្ធិដែលមានត្រឹមតែប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ ឬ សំដៅទៅលើការផ្ទេរសិទ្ធិកាន់កាប់លើចំណែកឯកជននៃអគារសហកម្មសិទ្ធិ ឬ ហៅថាបន្ទប់ខុនដូ ពីអ្នកលក់ទៅអ្នកទិញ ។ អគារសហកម្មសិទ្ធិប្រភេទនេះ ឬ ចំណែកឯកជននៃអគារសហកម្មសិទ្ធិនេះ មិនទាន់មានការចុះបញ្ជី នៅក្នុងសៀវភៅគោលបញ្ជីចំណែកឯកជននៃអគារសហកម្មសិទ្ធិនៅឡើយទេ។ ដូច្នេះសម្រាប់អគារ សហកម្មសិទ្ធិប្រភេទនេះមិនមាននីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិនៅមុខអាជ្ញាធរសុរិយោដីនោះទេ ពីព្រោះថា មិនទាន់មានវិញ្ញាបនបត្រសម្គាល់ម្ចាស់ចំណែកឯកជននៃគារសហកម្មសិទ្ធិនៅឡើយទេ។

ចំពោះកិច្ចសន្យាលក់ទិញប្រភេទនេះ គឺអាចមានការដឹងឮត្រឹមអាជ្ញាធរមូលដ្ឋានតែប៉ុណ្ណោះ ដោយមិនចាំបាច់ទៅដល់អាជ្ញាធរសុរិយោដីនោះទេ។ នៅក្នុងការអនុវត្តជាក់ស្តែងនៅតំបន់ខ្លះកិច្ចសន្យាលក់ ទិញចំណែកឯកជននៃអគារសហកម្មសិទ្ធិ ឬ បន្ទប់ខុនដូនេះ គេធ្វើឡើងដោយមានការដឹងឮតែពីអាជ្ញាធរឃុំ/សង្កាត់ប៉ុណ្ណោះ។ ក៏ប៉ុន្តែនៅតំបន់ខ្លះទៀត គេធ្វើនៅឃុំ/សង្កាត់ហើយ គេទៅឲ្យអាជ្ញាធរស្រុក /ខណ្ឌ ជួយដឹងឮមួយដំណាក់ទៀតដើម្បីឲ្យកាន់តែមានសុវត្ថិភាព។

ការផ្ទេរសិទ្ធិចំពោះការលក់ទិញអចលនវត្ថុគ្មានប័ណ្ណកម្មសិទ្ធិ គឺជាការផ្ទេរសិទ្ធិតែចំពោះសិទ្ធិកាន់កាប់លើអចលនវត្ថុនោះតែប៉ុណ្ណោះ មិនមែនជាការផ្ទេរកម្មសិទ្ធិផ្ដាច់ ដូចការលក់ទិញអចលនវត្ថុមានប័ណ្ណកម្មសិទ្ធិនោះទេ។ ប៉ុន្តែក្រោយពីអ្នកទិញទទួលបានសិទ្ធិកាន់កាប់ហើយ ប្រសិនបើអ្នកទិញមានបំណងចង់បាន សិទ្ធិកម្មសិទ្ធិលើអចលនវត្ថុរបស់ខ្លួន អ្នកទិញអាចរត់ការដោយខ្លួនឯងបាន ដើម្បីចុះបញ្ជីអចលនវត្ថុរបស់ខ្លួននៅអាជ្ញាធររដ្ឋបាលសុរិយោដីបាន ដើម្បីទទួលបាននូវវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ឬ វិញ្ញាបនបត្រសម្គាល់ចំណែកឯកជននៃអគារសហកម្មសិទ្ធិ។

### ២.១. គូភាគី ឬ អ្នកលក់ និងអ្នកទិញ

ភាគីអ្នកលក់ ឬ បុគ្គលអភិវឌ្ឍអចលនវត្ថុ គឺជាអ្នកកាន់កាប់អគារសហកម្មសិទ្ធិ ឬ បន្ទប់ខុនដូដោយស្របច្បាប់តាមនីតិវិធី ដែលច្បាប់បានកំណត់ ដែលមានសិទ្ធិក្នុងការផ្ទេរសិទ្ធិកាន់កាប់បន្តទៅឲ្យ

អ្នកទិញបាន។ អ្នកលក់ និង អ្នកទិញបន្ទាប់ពីធ្វើការព្រមព្រៀងគ្នាទាក់ទងទៅនឹងតម្លៃ កម្មវត្ថុនៃកិច្ចសន្យា និងលក្ខខណ្ឌផ្សេងៗ រួចរាល់ហើយពេលនោះកិច្ចសន្យានៃការលក់ទិញចំណែកឯកជននៃអគារសហាកម្មសិទ្ធិ ឬ បន្ទប់ខុនដូនឹងត្រូវបានបង្កើតឡើង។ ជាទូទៅកិច្ចសន្យានៃការលក់ទិញ និងលិខិតផ្ទេរសិទ្ធិកាន់កាប់ចំណែកឯកជន ឬ បន្ទប់ខុនដូនេះ គឺអ្នកលក់ ឬ ក្រុមហ៊ុនអភិវឌ្ឍអចលនវត្ថុ ជាអ្នករៀបចំរួចជាស្រេចសម្រាប់អ្នកទិញ។ ចំពោះកិច្ចសន្យាលក់ទិញនេះអ្នកលក់ ឬ ក្រុមហ៊ុនអភិវឌ្ឍអចលនវត្ថុបានរៀបចំឲ្យអ្នកទិញធ្វើការអាន និងយល់ខ្លឹមសារទាំងអស់នៅក្នុងកិច្ចសន្យានេះ ហើយធ្វើការព្រមព្រៀង និងផ្តិតមេដៃជាភស្តុតាងដោយស្មារតីត្រឹមត្រូវ និងគ្មានការគំរាមកំហែង។ ហើយរីឯលិខិតផ្ទេរសិទ្ធិកាន់ កាប់ចំណែកឯកជន ឬ បន្ទប់ខុនដូវិញ អ្នកលក់ ឬ ក្រុមហ៊ុនអភិវឌ្ឍអចលនវត្ថុបានរៀបចំលិខិតនោះ ៤ (បួន) ច្បាប់ដែលមានផ្តិតមេដៃរបស់អ្នកទិញ ហើយធ្វើការរក្សាទុកនៅឃុំ/សង្កាត់នៃអចលនវត្ថុនោះ តាំងនៅ១(មួយ)ច្បាប់ និងស្រុក /ខណ្ឌនៃចលនវត្ថុនោះតាំងនៅ២ (ពីរ) ច្បាប់ និងប្រគល់ឲ្យអ្នកទិញ១ (មួយ)ច្បាប់[១៩០] ។ ហើយជាទូទៅ រាល់សោហ៊ុយចំណាយលើការផ្ទេរសិទ្ធិកាន់កាប់នេះ គឺជាបន្ទុករបស់អ្នកលក់ ឬ ក្រុមហ៊ុនអភិវឌ្ឍអចលនវត្ថុ។

### ២.២. ការដឹងឮពីឃុំ/សង្កាត់ ឬ ស្រុក/ខណ្ឌ

មេឃុំ/ចៅសង្កាត់ ឬ ចៅហ្វាយស្រុក/ខណ្ឌនៃអចលនវត្ថុនោះតាំងនៅ អាចធ្វើជាសាក្សីបញ្ជាក់ថាអចលនវត្ថុនោះពិតជាមានការលក់ទិញពិតប្រាកដមែន ដោយមានការបោះត្រាទទួលស្គាល់ពីសំណាក់លោកមេឃុំ/ចៅសង្កាត់ ឬចៅហ្វាយស្រុក/ខណ្ឌជាដើម និងអមដោយសាក្សីដឹងឮម្នាក់ ឬ២នាក់។

នៅក្នុងករណីដែលភាគីលក់ទិញធ្វើការបន្តនីតិវិធីដល់ថ្នាក់ស្រុក/ខណ្ឌ នោះគឺគ្រាន់តែជាការចូលរួមក្នុងការជួយពិនិត្យ និងជួយដឹងឮអំពីការផ្ទេរសិទ្ធិកាន់កាប់អចលនវត្ថុតែប៉ុណ្ណោះ។ ប៉ុន្តែបើទោះជាការបោះត្រា ឬ ចារឹកលើលិខិតផ្ទេរសិទ្ធិកាន់កាប់អចលនវត្ថុ មិនមានអនុភាពដូចការផ្ទេរសិទ្ធិដោយអាជ្ញាធររដ្ឋបាលសុរិយោដីក៏ដោយ ក៏ការផ្ទេរសិទ្ធិកាន់កាប់ដោយអាជ្ញាធរមូលដ្ឋាននេះមានភាពរឹងមាំ និងទទួលបានសុវត្ថិភាពគ្រប់គ្រាន់ជាងការលក់ទិញដោយពុំមានការដឹងឮសោះពីអាជ្ញាធររបស់ខ្លួន។

[១៩០] បទសម្ភាសកញ្ញា សៀក លី ជាបុគ្គលិករបស់ក្រុមហ៊ុនលក់អចលនវត្ថុមួយនៅរាជធានីភ្នំពេញ នៅថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០១៦។

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវពីដំណាក់កាលនីមួយៗស្តីពី **“ការលក់ទិញអចលនវត្ថុនៅកម្ពុជាបច្ចុប្បន្ន”** រួចមកយើងខ្ញុំអាចសន្និដ្ឋានបានថា ការលក់ទិញអចលនវត្ថុនៅក្នុងប្រទេសកម្ពុជាយើងសព្វថ្ងៃនេះ គឺមានការកើនឡើងយ៉ាងខ្លាំង ហើយការលក់ទិញជាញឹកញាប់ជាងគេ គឺទៅលើអគារសហកម្មសិទ្ធិ (ខុនដូ) ឬបុរី និងដីធ្លី ដែលភាគច្រើនអចលនវត្ថុទាំងនោះ ស្ថិតនៅរាជធានីភ្នំពេញ និង ខេត្តសំខាន់ៗមួយចំនួនទៀតដូចជា ខេត្តកណ្តាល ខេត្តសៀមរាប ខេត្តបាត់ដំបង និងខេត្តព្រះសី-ហនុ ជាដើម។

នៅក្នុងការលក់ទិញអចលនវត្ថុនេះ អ្នកលក់ និងអ្នកទិញមានគោលបំណង់ខុសៗគ្នា ក្នុងការលក់ទិញនេះ អ្នកខ្លះលក់អចលនវត្ថុរបស់ខ្លួនដោយសារ ការផ្លាស់ទីលំនៅ អ្នកខ្លះដើម្បីទទួលបានប្រាក់ចំណេញ ខ្លះទៀតដើម្បីសងបំណុលធនាគារ ឬ អ្នកចងការប្រាក់ឯកជន ខ្លះទៀតធ្វើជាមុខរបរ ឬជំនួញរបស់ខ្លួនជាដើម។ រីឯអ្នកខ្លះទៀតទិញអចលនវត្ថុដើម្បីធ្វើការ លក់បន្ត ឬ ជួលបន្តទៅឲ្យអ្នកផ្សេងទៀត និងដើម្បីបង្កើតជាក្រុមហ៊ុន រោងចក្រ និងសម្រាប់ពាណិជ្ជកម្មរបស់ខ្លួន ឬ ក្រុមខ្លួន និងទៀត ទិញដីធ្លីដើម្បីសាងសង់ជាអគារ បុរី ឬ លំនៅដ្ឋាន សម្រាប់លក់ ជួល ឬ ស្នាក់នៅដោយខ្លួនឯងផ្ទាល់ ជាអាទិ៍។ គោលបំណងទាំងអស់នេះហើយ ដែលវាជំរុញឲ្យការលក់ទិញអចលនវត្ថុមានការកើនឡើង និងវាជាសកម្មភាពដ៏សំខាន់ សម្រាប់បម្រើដល់ជីវភាពរស់នៅ របស់ប្រជាពលរដ្ឋ។

នៅក្នុងការលក់ទិញអចលនវត្ថុនេះ អ្នកលក់អ្នកទិញភាគច្រើនចូលចិត្តធ្វើការលក់ទិញទៅលើអចលនវត្ថុដែលគ្មានប័ណ្ណកម្មសិទ្ធិ (ប្លង់ទន់) ជាងការលក់ទិញអចលនវត្ថុដែលមានប័ណ្ណកម្មសិទ្ធិ (ប្លង់រឹង) ពីព្រោះតែការលក់ទិញអចលនវត្ថុគ្មានប័ណ្ណកម្មសិទ្ធិវាមានលក្ខណៈងាយស្រួលមិនស្មុគស្មាញដូចការលក់ទិញអចលនវត្ថុមានប័ណ្ណកម្មសិទ្ធិ និង មិនត្រូវបានចំណាយលុយក្នុងការបង់ពន្ធជូនរដ្ឋ។ ប៉ុន្តែការលក់ទិញអចលនវត្ថុដែលមិនមានប័ណ្ណកម្មសិទ្ធិនេះ ហានិយភ័យមានខ្ពស់ដល់អ្នកទិញ ពីព្រោះថាអ្នកទិញអាចទិញប៉ះចំដីដែលរដ្ឋសម្បទានសង្គមកិច្ច ឬ ប៉ះចំអចលនវត្ថុរបស់រដ្ឋ ដែលជាកម្មសិទ្ធិរបស់រដ្ឋមិនអាចធ្វើការលក់ដូរបាន។ ហើយបើសិន មានវិវាទនៅថ្ងៃក្រោយ ដែលធ្វើឲ្យអ្នកទិញមិនអាចតតាំង ជាមួយតតិយជនបានទេ ដោយសារខ្លួនមិនទាន់មានសិទ្ធិកម្មសិទ្ធិពេញលេញនៅឡើយទេ។ ហើយមួយវិញទៀតនោះ ការលក់ទិញដីដែលមិនមានការចុះបញ្ជីផ្ទេរកម្មសិទ្ធិ នៅពេលដែលធ្វើលទ្ធកម្មកម្ម សិទ្ធិ ដោយការផ្ទេរនោះ នឹងធ្វើឲ្យបាត់បង់នូវចំណូលពន្ធរបស់រដ្ឋទៀតផង។

ជាចុងក្រោយ ដើម្បីជៀសវាងការខាតបង់ទាំងពេលវេលា និងលុយកាក់ និងកុំឲ្យកើតមាននូវជម្លោះទៅថ្ងៃក្រោយ អ្នកទិញគួរតែធ្វើការត្រួតពិនិត្យឲ្យបានច្បាស់ពីប្រវត្តិអចលនវត្ថុ និងស្ថានភាពទូទៅជុំវិញអចលនវត្ថុ និងលក្ខខណ្ឌនៃការបង្កើតកិច្ចសន្យាលក់ទិញអចលនវត្ថុ និងលក្ខខណ្ឌគតិយុត្តនានាទៀតដែលទាក់ទងទៅនឹងការលក់ទិញអចលនវត្ថុមុននឹងឈានដល់ដំណាក់កាលចុះកិច្ចសន្យា។ លើសពីនេះទៅទៀតដើម្បីឲ្យការលក់ទិញ អចលនវត្ថុនេះស្របតាមច្បាប់ និងដើម្បីជាប្រយោជន៍ដល់ភាគីទាំងពីរ គូភាគីគួរអនុវត្តតាមដំណាក់កាលទាំងអស់ដែលមាននៅក្នុងសារណានេះ។

# អនុសាសន៍

ឆ្លងតាមរយៈការសិក្សាស្រាវជ្រាវទៅលើប្រធានបទ"**ការទិញលក់អចលនវត្ថុនៅកម្ពុជាបច្ចុប្បន្ន**" នេះរួចមក យើងខ្ញុំសង្កេតឃើញថាមានបញ្ហាលំបាកមួយចំនួនកើតមានឡើងកន្លងមក ដែលភាគីអ្នកទិញ និងរដ្ឋាភិបាលគួរតែ៖

– អ្នកទិញដែលទិញអចលនវត្ថុដែលគ្មានប័ណ្ណកម្មសិទ្ធិគួរតែទៅធ្វើការចុះបញ្ជីអចលនវត្ថុរបស់ខ្លួនដើម្បីទទួលបានប័ណ្ណកម្មសិទ្ធិ ឬ វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ និងដើម្បីខ្លួនមានសិទ្ធិពេញលេញក្នុងការតតាំងជាមួយតតិយជន និងជៀសវាងមានវិវាទនៅថ្ងៃក្រោយ។

– រាជរដ្ឋាភិបាលគួរតែពន្លឿននីតិវិធីនៃការចុះបញ្ជីអចលនវត្ថុឲ្យបានឆាប់រហ័ស ចំណាយថវិការតិច និងមិនស្មុគស្មាញព្រមទាំង ទៅដល់មូលដ្ឋានប្រជាពលរដ្ឋរស់នៅ។ ក្នុងករណីដែលអចលនវត្ថុរបស់ប្រជាពលរដ្ឋមានកម្មសិទ្ធិ ឬ បានចុះបញ្ជីត្រឹមត្រូវហើយនោះ បញ្ហាជាច្រើនត្រូវបានដោះស្រាយដូចជា មិនលក់ទិញប៉ះចំដីរដ្ឋ អាចប្រមូលពន្ធពីលទ្ធកម្មកម្មសិទ្ធិដោយការលក់បាន បង្កើនចំណូលរដ្ឋការលក់ទិញមានភាពជឿជាក់អាចតតាំងបានជាមួយតតិយជនពេលមានវិវាទនៅថ្ងៃក្រោយ។

– រាជរដ្ឋាភិបាលគួរតែសម្រួលនីតិវិធីនៃការកាត់ឈ្មោះ ឬ ផ្ទេរកម្មសិទ្ធិ ពីម្ចាស់កម្មសិទ្ធិចាស់ទៅម្ចាស់កម្មសិទ្ធិថ្មីឲ្យបានឆាប់រហ័សមិនចំណាយពេលវេលាយូរ និងលុយកាក់ច្រើន ព្រមទាំងងាយស្រួលផងដែរ។ មួយវិញទៀតនោះរាជរដ្ឋាភិបាលគួរតែយកពន្ធទៅលើការផ្ទេរសិទ្ធិកាន់កាប់ទៅលើអចលនវត្ថុដែលគ្មានប័ណ្ណកម្មសិទ្ធិ នៅតម្លៃពន្ធសមរម្យ ។ ឧទាហរណ៍៖ ចំពោះក្រុមហ៊ុនអភិវឌ្ឍអចលនវត្ថុមួយចំនួនដែលធ្វើការសាងសង់អគារសហកម្មសិទ្ធិ ឬ បុរី ដើម្បីធ្វើការលក់ ដែលមានតែត្រឹមការផ្ទេរសិទ្ធិកាន់កាប់នៅអាជ្ញាធរមូលដ្ឋានតែប៉ុណ្ណោះ ដោយមិនមានការបង់ពន្ធប្រថាប់ត្រាជូនរដ្ឋនោះទេ ពីព្រោះអចលនវត្ថុនោះមិនទាន់បានធ្វើការចុះបញ្ជីនៅឡើយ ដូច្នេះធ្វើឲ្យរដ្ឋបាត់បង់ប្រាក់ពន្ធដែលទទួលបាន ពីបុគ្គលអភិវឌ្ឍអចលនវត្ថុនោះជាច្រើន។

ដូចនេះប្រសិនបើអ្នកទិញ និងរាជរដ្ឋាភិបាលអាចធ្វើតាមអនុសាសន៍ទាំងអស់នេះបាន នោះនឹងធ្វើឲ្យការលក់ទិញអចលនវត្ថុនៅកម្ពុជាមានភាពងាយស្រួល និងល្អប្រសើរ ហើយរដ្ឋក៏អាចប្រមូលពន្ធមួយចំនួនពីការលក់ទិញអចលនវត្ថុនៅកម្ពុជាយើងបាន ដែលនាំឲ្យចំណូលថវិការជាតិមានការកើនឡើង។

# ឯកសារយោង

## ១. ច្បាប់ និងបទដ្ឋានគតិយុត្ត

– ក្រមរដ្ឋប្បវេណី, លេខនស/រកម/១២០៧/០៣០ចុះថ្ងៃទី៨, ធ្នូ, ២០០៧។

– ច្បាប់ភូមិបាល, លេខនស/រកម/០៨០១/១៤, សីហា ២០០១។

– ច្បាប់ស្តីពីការផ្តល់សិទ្ធិកម្មសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិដល់ជនបរទេស, លេខនស/រកម/០៥១០/០០៦, ២៤ ឧសភា ២០១០។

– ច្បាប់ស្តីពីការបង្កើតពន្ធប្រថាប់ត្រា ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ១៩៩១។

– អនុក្រឹត្យស្តីពីការគ្រប់គ្រង និងប្រើប្រាស់អគារសហកម្មសិទ្ធិ, លេខ១២៦អនក្រ.បក, ១២ សីហា ២០០៩។

– ប្រកាសស្តីពីការប្រមូលពន្ធប្រថាប់ត្រាលេខ៧៣៧ ចុះថ្ងៃទី ៨ ខែ សីហា ឆ្នាំ២០១៣។

– ប្រកាសស្តីពីការអនុវត្តគោការណ៍ដីចំណីផ្លូវជាតិ ផ្លូវខេត្ត ផ្លូវឃុំ ផ្លូវរថភ្លើងនៅទូទាំងព្រះរាជាណាចក្រកម្ពុជាលេខ៩៦១ សហវ, ០៦ មេសា ២០០០។

– ប្រកាសអន្តរក្រសួងស្តីពីនីតិវិធីនៃការចុះបញ្ជី អំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណីចុះថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ២០១១។

## ២. សៀវភៅ និងឯកសារផ្សេងៗ

– សៀវភៅរបស់លោកសាស្ត្រាចារ្យ បណ្ឌិត ហាប់ ផល្លី ស្តីពីការលក់ និងទិញនៅកម្ពុជា។

– សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណីភាគ៣ គន្លីទី៥, ឆ្នាំ២០១០។

– កម្រងឯកសារស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់,ចុះខែមិថុនាឆ្នាំ២០១៣។

– សារណាបញ្ចប់ការសិក្សា ស្តីពីការលក់ទិញអគារសហកម្មសិទ្ធិនៅកម្ពុជា របស់និស្សិត ស៊ុន វិជ័យធារី ឆ្នាំ២០១៣

– សារណាបញ្ចប់ការសិក្សា ស្តីពីសុវត្ថិភាពនៃការលក់ទិញអចលនវត្ថុនៅកម្ពុជា របស់និស្សិត ឈីវ អ៊ិចគង់ និងនិស្សិតនៅ ច័ន្ទមិនាសារ ឆ្នាំ២០១៣

– សារណាបញ្ចប់ការសិក្សា ស្តីពីការលក់ទិញអចលនវត្ថុនៃព្រះរាជាណាចក្រកម្ពុជា របស់និស្សិតកញ្ញាម៉ុក ទេវី និងនិស្សិតកញ្ញា ជ្រឹង ស្រីណៃត្រ ឆ្នាំ២០១៥ ។